សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

# របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ភាពលានុវត្តភាព និង បញ្ហាប្រឈមរបស់ ទីផ្សារមូលបត្រកម្ពុជា

កម្មសិក្សាពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ឈ្មោះស្ថាប័ន៖ **គណៈកម្មការមូលបត្រកម្ពុជា**

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **កែ សុភន្និភា**
**ពាង ធីរដ្ឋ**

សាស្ត្រាចារ្យណែនាំ
លោក **ខួន ឃេង**

ថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ
ជំនាន់ទី ១៣

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេររបាយការណ៍ ២០២០

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ កែ សុកន្និកា និង ពាង ធីរដ្ឋ ជានិស្សិតថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ ឆ្នាំទី៤ ក្រុម B4C1 ជំនាន់ទី១៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៦-២០២០ ដែលបានចុះកម្មសិក្សានៅស្ថាប័ន គណៈកម្មការមូលបត្រកម្ពុជា បានបញ្ចប់ការសរសេររបាយការណ៍កម្មសិក្សាទៅលើប្រធានបទ **“កាលានុវត្តភាព និងបញ្ហាប្រឈមរបស់ទីផ្សារមូលបត្រកម្ពុជា”** ដោយមានការជួយជ្រោមជ្រែងពីសំណាក់មជ្ឈដ្ឋានជាច្រើន។ អាស្រ័យហេតុនេះ ក្រុមយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

- លោកឪពុក អ្នកម្តាយ ដែលបានចិញ្ចឹម បីបាច់ ថែរក្សា ដោយក្តីអាណិតស្រលាញ់ ផ្តត់ផ្គង់ទាំងផ្នែកសម្ភារៈ និងកម្លាំងចិត្ត ជាពិសេសបានផ្តល់ឱកាសអោយកូនបានសិក្សារៀនសូត្រដោយមានការជួយជ្រោមជ្រែងជាថវិកា រហូតដល់ចប់ថ្នាក់បរិញ្ញាបត្រ និងបញ្ចប់ការសរសេររបាយការណ៍មួយនេះ។
- ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធានការិយាល័យ លោក លោកស្រីសាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលតែងខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ ចិត្តក្នុងការបង្ហាត់បង្រៀន ណែនាំ ចង្អុលបង្ហាញ ផ្តល់ជាចំណេះដឹង ជួយពង្រឹងទាំងផ្នែកប្រាជ្ញា ស្មារតី អស់រយៈពេល ៤ឆ្នាំកន្លងមក ព្រមទាំងជួយផ្តល់ជាឯកសារផ្សេងៗដល់ពួកយើងខ្ញុំក្នុងការពង្រឹងចំណេះដឹង។
- លោកសាស្ត្រាចារ្យ ងួន ហេង ដែលបានណែនាំ ចង្អុលបង្ហាញ ចែករំលែកនូវចំណេះដឹង បទពិសោធន៍ និងគន្លឹះល្អៗ ដើម្បីជួយសម្រួលដល់ការសរសេររបាយការណ៍ និងកែលំអនូវចំណុចខ្វះខាត ទោះបីមានភាពមមាញឹកក្នុងការបំពេញការងារ តួនាទី និងភារកិច្ចយ៉ាងណាក្តី។
- ឯកឧត្តមអគ្គនាយក អគ្គនាយករង លោក លោកស្រីប្រធាននាយកដ្ឋាន និងប្រធានការិយាល័យរួមទាំងមន្រ្តីទាំងអស់ដែលបំពីការនៅក្នុងស្ថាប័នគណៈកម្មការមូលបត្រកម្ពុជា ដែលបានផ្តល់ឱកាសអនុញ្ញាតអោយក្រុមយើងខ្ញុំបានចុះកម្មសិក្សា ព្រមទាំងជួយជ្រោមជ្រែង ក្នុងការចែករំលែកចំណេះដឹង ឆ្លើយតបរាល់ចម្ងល់ផ្សេងៗទាក់ទងនឹងប្រធានបទ ជួយផ្តល់ជាព័ត៌មាន និងទិន្នន័យដែលត្រូវយកមកវិភាគ ចង្អុលបង្ហាញនៅក្នុងរបាយការណ៍បញ្ចប់ការសិក្សានេះ។ ជាពិសេស លោកស្រី ហ៊ លីគា ជាប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ ហើយរួមជាមួយលោកប្រធានការិយាល័យ និងមន្ត្រី នៅក្នុងនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ ដែលបានផ្តល់នូវ ឯកសារ ដំបូន្មាន គំនិត និង

យោបល់ល្អៗនិងការយកចិត្តទុកដាក់មកលើយើងខ្ញុំ កំឡុងពេលចុះកម្មសិក្សានេះ ដែលធ្វើឲ្យយើងខ្ញុំទទួលបានចំណេះដឹង និងបទពិសោធន៍ការងារជាក់ស្តែងនៅក្នុងវិស័យមូលបត្របន្ថែមទៀត។

- និស្សិតជារៀមច្បងជំនាន់មុនដែលបានបន្សល់ទុកនូវស្នាដៃជាគំរូសៀវភៅសារណា និងរបាយការណ៍ជាច្រើនដែលជាប្រភពឯកសារ សំរាប់ពួកយើងខ្ញុំ និងនិស្សិតជំនាន់ក្រោយទៀតក្នុងការសិក្សាស្រាវជ្រាវ។
- មិត្តរួមជំនាន់ទាំងអស់ដែលបានផ្តល់ជាកម្លាំងចិត្ត និងជួយចែករំលែកចំណេះដឹងដល់ពួកយើងខ្ញុំក្នុងការសរសេររបាយការណ៍មួយនេះ។

ជាបញ្ចប់យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងសូមប្រសិទ្ធិពរជ័យដល់បណ្តាអ្នកមានគុណទាំងអស់ដូចដែលបានរៀបរាប់ខាងលើ អោយជួបតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

ទីផ្សារមូលបត្រជាទីផ្សារមានលក្ខណៈពិសេសដាច់ដោយឡែកខុសពីទីផ្សារទំនិញ និងសេវាទូទៅ គឺទាមទារឲ្យមានការធ្វើនិយ័តកម្ម ដោយមានចែងជាច្បាប់ និងគោលការណ៍ច្បាស់លាស់ដើម្បីដំណើរការបាន។ សំរាប់ប្រទេសកម្ពុជា ទីផ្សារមូលបត្រ ទើបតែបានលេចរូបរាងឡើងដោយមាន **គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.)** ដែលជានិយ័តករមូលបត្រ ដែលត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧។ បន្ទាប់មកទើបមានការបង្កើតស្ថាប័ន **ក្រុមហ៊ុនផ្សារមូល-បត្រកម្ពុជា(ផ.ម.ក.)** ដែលបានបើកឲ្យមានការជួញដូរជាលើកដំបូង នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ តាមរយៈការជួញដូរនូវមូលបត្រកម្មសិទ្ធិ ឬបណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។ យោងតាមតថភាពនាពេលបច្ចុប្បន្ន ទីផ្សារមូលបត្រនៅក្នុងប្រទេសកម្ពុជាមានការរីកចម្រើនជាលំដាប់ ទោះបីមានលក្ខណៈក្មេងខ្ចីនៅឡើយក៏ដោយ ហើយចំពោះការវិនិយោគលើផ្សារមូលបត្រ អាចនិយាយបានថា គឺជាការវិនិយោគថ្មីមួយសម្រាប់ វិនិយោគិនទាំងជាបុគ្គល និងជាស្ថាប័ន ជាពិសេសប្រជាពលរដ្ឋកម្ពុជាទូទៅ។ ដោយមើលឃើញថា វិស័យមូលបត្រមានឥទ្ធិពល និងមានទំនាក់ទំនងយ៉ាងស្អិតរមួត ហើយក៏ជាផ្នែកមួយជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ ស្របពេលដែលវិនិយោគិន ជាពិសេសប្រជាពលរដ្ឋកម្ពុជាភាគច្រើនមិនទាន់យល់ដឹងច្រើនពីវិស័យមូលបត្រ និងបញ្ហាថា តើការវិនិយោគលើមូលបត្រមានឥទ្ធិពលអ្វីខ្លះនោះ ទើបក្រុមយើងខ្ញុំសម្រេចធ្វើការស្រាវជ្រាវ និងចងក្រងជារបាយការណ៍កម្មសិក្សាដោយជ្រើសយកប្រធានបទ **“កាលានុវត្តភាព និងបញ្ហាប្រឈមរបស់ទីផ្សារមូលបត្រកម្ពុជា”** សម្រាប់ការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។ ក្រៅពីបញ្ហាគោលនៅក្នុងរបាយការណ៍ស្រាវជ្រាវនេះដែលធ្វើការបកស្រាយផ្តោតសំខាន់ទៅលើ កត្តាកាលានុវត្តភាព ឬ ឱកាស និងបញ្ហាប្រឈមក្នុងការវិនិយោគលើមូលបត្រនៅលើទីផ្សារមូលបត្រកម្ពុជា យើងខ្ញុំក៏មានការចងក្រងរៀបរាប់ពីទិដ្ឋភាពរបស់មូលបត្រ និងទីផ្សារមូលបត្រទាំងលើពិភពលោក និងក្នុងប្រទេសកម្ពុជា ព្រមទាំងដំណើរការវិនិយោគមូលបត្រនៅកម្ពុជាខ្លះផងដែរ។

យើងខ្ញុំសង្ឃឹមថា របាយការណ៍កម្មសិក្សាមួយនេះ អាចធ្វើជាប្រភពទិន្នន័យ និងអាចផ្តល់ជាចំណេះដឹងបន្ថែមដល់វិនិយោគិនទូទៅដើម្បីជាមូលដ្ឋានក្នុងការពិចារណា ជាពិសេសសិស្ស និស្សិតដែលត្រូវការ និងចង់សិក្សាស្វែងយល់ពីការវិនិយោគលើវិស័យមូលបត្រនៅប្រទេសកម្ពុជា។

# មាតិកា


អក្សរកាត់ ........ vi

បញ្ជីតារាង ........ vii

បញ្ជីក្រាហ្វិក ........ viii

បញ្ជីរូបភាព ........ ix

បញ្ជីឧបសម្ព័ន្ធ ........ x


## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ២

៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ៣

៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣

៦. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៤

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤


## ជំពូកទី១

## រំលឹកទ្រឹស្តី ទីផ្សារមូលបត្រ


១.១. សាវតារបស់ទីផ្សារមូលបត្រ ........ ៦

១.១.១. និយមន័យ ........ ៦

១.១.២. ប្រវត្តិទីផ្សារមូលបត្រ ........ ៦

១.២. តួអង្គសំខាន់ៗក្នុងវិស័យមូលបត្រ ........ ៧

១.២.១. និយ័តករមូលបត្រ (Securities Regulator) ........ ៧

១.២.២. ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ (Listed company or ISSUER) ........ ៨

១.២.៣. ក្រុមហ៊ុនមូលបត្រ (Securities Firm) ........ ៨

ក. ក្រុមហ៊ុនធានាទិញមូលបត្រ (Securities Underwriting) ........ ៩

ខ. ក្រុមហ៊ុនពាណិជ្ជករមូលបត្រ (Securities Dealing, Dealer) ........ ៩

គ. ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ (Securities Brokerage, Broker) ........ ៩

ឃ. ក្រុមហ៊ុនប្រឹក្សាវិនិយោគ (Securities Advisory) ........ ១០
១.២.៤. វិនិយោគិនសាធារណៈ (Public Investors) ........ ១០
១.២.៥. ទីផ្សារមូលបត្រ (Securities Market) ........ ១០
១.២.៦. តួអង្គផ្សេងទៀត ........ ១១
ក. ភ្នាក់ងារបញ្ជិការមូលបត្រ (Securities Registrar Agent) ........ ១១
ខ. ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ (Transfer Agent) ........ ១១
គ. ភ្នាក់ងារទូទាត់ (Paying Agent) ........ ១១
ឃ. ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (Cash Settlement Agent) ........ ១១
ង. ភ្នាក់ងារតំណាងម្ចាស់បំណុល (Bondholder Representatives) ........ ១១
១.៣ ប្រភេទទីផ្សារមូលបត្រ ........ ១២
១.៣.១ ទីផ្សារដំបូង (Primary Market) ........ ១២
១.៣.២ ទីផ្សារបន្ទាប់ (Secondary Market) ........ ១២
១.៤ មូលបត្រ ........ ១៥
១.៤.១ និយមន័យ ........ ១៥
១.៤.២ ប្រភេទមូលបត្រ ........ ១៥
ក. មូលបត្របំណុល ........ ១៥
ខ. មូលបត្រកម្មសិទ្ធិ ........ ១៦
គ. ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវ(Derivative Instrument) ........ ១៧

## ជំពូកទី២

## ទិដ្ឋភាពទូទៅរបស់ផ្សារមូលបត្រកម្ពុជា

២.១. គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ........ ១៨
២.១.១. ប្រវត្តិនៃការបង្កើតគណៈកម្មការមូលបត្រកម្ពុជា ........ ១៨
២.១.២. និយមន័យរបស់គណៈកម្មការមូលបត្រកម្ពុជា ........ ១៨
២.១.៣. ចក្ខុវិស័យ និងបេសកកម្ម ........ ១៩
ក. ចក្ខុវិស័យ ........ ១៩
ខ. បេសកកម្ម ........ ១៩

២.១.៤. តួនាទីរបស់គណៈកម្មការមូលបត្រកម្ពុជា ........................................................ ២០
២.១.៥. ប្រធាន និងសមាជិករបស់ គ.ម.ក. ........................................................ ២១
២.១.៦. រចនាសម្ព័ន្ធអង្គការចាត់តាំងគណៈកម្មការមូលបត្រកម្ពុជា ........................................................ ២២
២.១.៧. រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញារបស់គណៈកម្មការមូលបត្រកម្ពុជា ........................................................ ២៣
ក. រូបសញ្ញា ........................................................ ២៣
ខ. អត្ថន័យនៃរូបសញ្ញា ........................................................ ២៤
គ. មូលហេតុនៃជម្រើសយករូបហង្សពណ៌មាសជានិមិត្តសញ្ញា ........................................................ ២៤
២.១.៨. ព័ត៌មានទំនាក់ទំនងរបស់គណៈកម្មការមូលបត្រកម្ពុជា ........................................................ ២៥
២.២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) ........................................................ ២៥
២.២.១. ប្រវត្តិនៃការបង្កើតក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ........................................................ ២៥
២.២.២. នាមករណ៍ និងផ្លាកសញ្ញារបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ........................................................ ២៦
ក. នាមករណ៍ ........................................................ ២៦
ខ. ផ្លាកសញ្ញា ........................................................ ២៧
២.២.៣. ចក្ខុវិស័យ និងបេសកម្មរបស់ផ្សារមូលបត្រកម្ពុជា ........................................................ ២៧
ក. ចក្ខុវិស័យ ........................................................ ២៧
ខ. បេសកម្ម ........................................................ ២៧
២.២.៤. ព័ត៌មានទំនាក់ទំនងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ........................................................ ២៨
២.២.៥. រចនាសម្ព័ន្ធគ្រប់គ្រងរបស់ផ្សារមូលបត្រកម្ពុជា ........................................................ ២៨

**ជំពូកទី៣**

**ដំណើរការវិនិយោគមូលបត្រនៅកម្ពុជា**

៣.១.និយមន័យ ការវិនិយោគលើមូលបត្រ ........................................................ ២៩
៣.២. លក្ខខណ្ឌដើម្បីក្លាយជាវិនិយោគមូលបត្រ ........................................................ ២៩
៣.២.១. ការស្នើសុំលេខអត្តសញ្ញាណ និងការបើកគណនី ........................................................ ២៩
ក. ការស្នើសុំលេខអត្តសញ្ញាណវិនិយោគ ........................................................ ២៩
ខ. ការបើកគណនី ........................................................ ៣០
៣.៣. ដំណើរការនៃការជួញដូរមូលបត្រ ........................................................ ៣១

៣.៣.១. ការជួញដូរមូលបត្រនៅផ្សារដំបូង និងផ្សារបន្ទាប់ ........ ៣១
ក. ការជួញដូរមូលបត្រនៅផ្សារដំបូង ........ ៣១
ខ. ការជួញដូរមូលបត្រនៅផ្សារបន្ទាប់ ........ ៣២
៣.៣.២. នីតិវិធីនៃការជួញដូរ ........ ៣២
៣.៣.៣. ពេលវេលានៃការជួញដូរ ........ ៣៥
៣.៣.៤. វិធីសាស្ត្រជួញដូរ ........ ៣៥
៣.៤. ការទូទាត់ និងការរក្សាទុកមូលបត្រ ........ ៣៧
៣.៤.១.ការទូទាត់ ........ ៣៧
៣.៤.២. ការរក្សាទុកមូលបត្រ ........ ៣៨

**ជំពូកទី៤**

**កាលានុវត្តភាព និងបញ្ហាប្រឈមរបស់ទីផ្សារមូលបត្រកម្ពុជា**

៤.១.កាលានុវត្តភាពរបស់ទីផ្សារមូលត្រកម្ពុជា ........ ៣៩
៤.១.១. កត្តាសេដ្ឋកិច្ច ........ ៣៩
៤.១.២. ផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់វិស័យមូលបត្រ ........ ៤០
៤.១.៣. ការរីកចម្រើននៃប្រព័ន្ធផ្សព្វផ្សាយ ........ ៤១
៤.១.៤. ការរីកចម្រើននៃប្រព័ន្ធបច្ចេកវិទ្យា ........ ៤២
៤.១.៥ កំណើនទំនោរនៃការវិនិយោគមូលបត្រ ........ ៤៣
៤.១.៦.ទស្សនៈរបស់វិនិយោគិន ........ ៤៣
ក.កត្តាវិទ្យាសាស្ត្រ ........ ៤៣
ខ.កត្តាចិត្តសាស្ត្រ ........ ៤៤
៤.១.៧. ស្ថេរភាពនយោបាយ និង ប្រសិទ្ធិភាពនៃការអនុវត្តច្បាប់ ........ ៤៤
៤.២.បញ្ហាប្រឈមរបស់ទីផ្សារមូលបត្រកម្ពុជា ........ ៤៤
៤.២.១.កំណើនក្រុមហ៊ុនចុះបញ្ជីលើទីផ្សារនៅមានកំរិត ........ ៤៤
៤.២.២.គុណវុឌ្ឍិដើម្បីក្លាយជាក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ........ ៤៥
៤.២.៣.ការយល់ដឹងពីវិស័យមូលបត្រនៅមានកំរិត ........ ៤៦

៤.៣. ការវិភាគទិន្នន័យមូលធនូបនីយកម្មទីផ្សារសរុប (Market Capitalization)របស់ក្រុមហ៊ុនបោះផ្សាយមូលបត្រកម្មសិទ្ធិនីមួយៗពីឆ្នាំ២០១៥-ឆ្នាំ២០១៩............................................................ .៤៦

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ........................................................................................................ ៥១
២. ការផ្តល់អនុសាសន៍ ...................................................................................................... ៥២

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# អក្សរកាត់

| | | |
|---|---|---|
| គ.ម.ក. | : | គណៈកម្មការមូលបត្រកម្ពុជា |
| ផ.ម.ក. | : | ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា |
| SECC | : | Securities and Exchange Commission Cambodia |
| CSX | : | Cambodia Securities Exchange |
| IPO | : | Initial Public Offering |
| Plc. | : | Public Limited Company |
| Co., Ltd | : | Company Limited |
| OTC | : | Over-the-Counter |
| T-Bills | : | Treasury Bills |
| MTS | : | Mobile Trading System |
| Market Cap. | : | Market Capitalization |
| PWAS | : | Phnom Penh Water Supply Authority |
| GTI | : | Grand Twins International (Cambodia) Plc. |
| PPAS | : | Phnom Penh Autonomous Port |
| PPSP | : | Phnom Penh SEZ Plc. |
| PAS | : | Sihanoukville Autonomous Port |
| ABC | : | Acleda Bank Plc. |

# បញ្ជីតារាង

តារាងទី១៖ ពេលវេលានៃការជួញដូរមូលបត្រ..........................................................................៣៥
តារាងទី២៖ របៀបជួញដូរតាមវិធីសាស្ត្រដេញថ្លៃ....................................................................................៣៦
តារាងទី៣៖ ទិន្នន័យមូលធនូបនីយកម្មទីផ្សារសរុប (Market Cap.) ...............................................៤៧

# បញ្ជីក្រាហ្វិក

ក្រាហ្វិកទី១៖ ក្រាហ្វិកសសរមូលធនទូបនីយកម្មពីឆ្នាំ ២០១៥-២០១៩............................................៤៧
ក្រាហ្វិកទី២៖ ក្រាហ្វិកខ្សែក្រាបមូលធនទូបនីយកម្មពីឆ្នាំ ២០១៥-២០១៩..........................................៤៨

# បញ្ជីរូបភាព

រូបភាពទី១៖ ឯកឧត្តមកិត្តិបរិក្សបណ្ឌិត គាត ឈន់ ក្នុងពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការនៃគ.ម.ក. ក្នុងឆ្នាំ២០១៩......១៨

រូបភាពទី២៖ ឯកឧត្តម ស៊ូ សុជាតិ អគ្គនាយក នៃគណៈកម្មការមូលបត្រកម្ពុជា ...... ១៩

រូបភាពទី៣៖ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុន្នីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ជាប្រធាន គ.ម.ក. ......២២

រូបភាពទី៤៖ រូបសញ្ញារបស់គណៈកម្មការមូលបត្រកម្ពុជា......២៤

រូបភាពទី៥៖ ផ្លាកសញ្ញារបស់ផ្សារមូលបត្រ ......២៧

រូបភាពទី៦៖ គំនូសតាងដំណើរការជួញដូរមូលបត្រនៅផ្សារមូលបត្រកម្ពុជា......៣៤

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ ច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន

ឧបសម្ព័ន្ធទី២៖ ច្បាប់ស្តីពីមូលបត្ររដ្ឋ

ឧបសម្ព័ន្ធទី៣៖ អនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ

ឧបសម្ព័ន្ធទី៤៖ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ ២០១៦-២០២៥

ឧបសម្ព័ន្ធទី៥៖ ពុទ្ធិមូលបត្រ លេខ៤៦ ចេញផ្សាយឆ្នាំ ២០២០

ឧបសម្ព័ន្ធទី៦៖ ទម្រង់ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិនសម្រាប់នីតិបុគ្គល

ឧបសម្ព័ន្ធទី៧៖ ទម្រង់ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិនសម្រាប់រូបវន្តបុគ្គល

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ក្នុងសតវត្សទី២១នេះ ទីផ្សារមូលបត្រ ឬការវិនិយោគលើមូលបត្រនៅលើពិភពលោក ជាវិស័យមួយកំពុងមានការរីកលូតលាស់ និងមានការអភិវឌ្ឍន៍គួរអោយកត់សម្គាល់ ជាពិសេសនៅតាមបណ្តាប្រទេសអភិវឌ្ឍន៍ដូចជា សហរដ្ឋអាមេរិក អង់គ្លេស ជប៉ុន ដែលសុទ្ធសឹងជាប្រទេសនាំមុខលើវិស័យមូលបត្រ។ សំរាប់ប្រទេសកម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍន៍មួយ ទីផ្សារមូលបត្រទើបតែបានកកើតឡើង ដោយមានបង្កើតជាស្ថាប័នជួញដូរមូលបត្រដំបូងបំផុតនៅកម្ពុជានោះគឺ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា(ផ.ម.ក.) ដែលបានបង្កើតឡើងនៅឆ្នាំ២០១១ និងប្រកាសបើកការជួញដូរជាលើកដំបូងនៅ ថ្ងៃទី១៨ ខែមេសា ឆ្នាំ ២០១២ តាមរយៈការបោះផ្សាយមូលបត្រកម្មសិទ្ធរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានតួនាទីជាប្រតិបត្តិករទីផ្សារមូលបត្រ ដោយមាន **គណៈកម្មការមូលបត្រកម្ពុជា** ហៅកាត់ថា គ.ម.ក.[1]ជានិយ័តករគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍន៍ទីផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា។

វិស័យមូលបត្រ និងវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ មានទំនាក់ទំនង និងដំណើរការបំពេញគ្នាទៅវិញទៅមកក្នុងការអភិវឌ្ឍ និងពង្រឹងប្រព័ន្ធហិរញ្ញវត្ថុទាំងមូលនៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងសេដ្ឋកិច្ចជាតិ និងដើម្បីធានាការប្រកួតប្រជែងរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងបរិបថសាកលភាវូបនីយកម្មផងដែរ។ ស្របតាម យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥ របស់រាជរដ្ឋាភិបាល អាទិភាពចម្បងចំពោះមុខគឺ ការអភិវឌ្ឍទីផ្សារមូលបត្រ និងការវិនិយោគមូលបត្រនៅកម្ពុជា។ ការវិនិយោគលើមូលបត្រកំពុងទទួលបានការចាប់អារម្មណ៍ច្រើនឡើងពីសំណាក់វិនិយោគិនដែលមានមូលធន និងមានបំណងវិនិយោគពីគ្រប់មជ្ឈដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដោយសារភាពក្មេងខ្ចីរបស់វិស័យមូលបត្រនៅកម្ពុជា មានវិនិយោគិនជាច្រើន ព្រមទាំងប្រជាពលរដ្ឋទូទៅផងដែរ មិនហ៊ានធ្វើការសម្រេចចិត្តថាតើគួរវិនិយោគលើមូលបត្រដែរទេ ដោយហេតុថា ពួកគេមិនទាន់មានការយល់ដឹង ឬយល់ដឹងតិចតួចពីវិស័យមូលបត្រនេះ ជាពិសេសថាតើការវិនិយោគលើមូលបត្រ ផ្តល់ផលចំណេញ ឬ ឱកាសអ្វីខ្លះ និងមានហានិភ័យអ្វីខ្លះ អាចផ្តល់ទំនុកចិត្ត និងសុវត្ថិភាពបានដែរទេ? ដែលសុទ្ធសឹងជាចំណុចដែលវិនិយោគិនទូទៅត្រូវសិក្សា ស្វែងយល់ ដើម្បីជាមូលដ្ឋានក្នុងការសម្រេចចិត្តនាំទៅរកការវិនិយោគ និងជួយធ្វើអោយវិស័យមូលបត្រនៅកម្ពុជារឹតតែមានភាពរីកចម្រើន។

[1] http://www.csx.com.kh/, ទិដ្ឋភាពទូទៅរបស់ ផ.ម.ក., ប្រវត្តិ ផ.ម.ក.

អាស្រ័យហេតុនេះហើយ ទើបក្រុមយើងខ្ញុំសម្រេចជ្រើសយកប្រធានបទស្តីពី "កាលានុវត្តភាព និង បញ្ហាប្រឈមរបស់ទីផ្សារមូលបត្រកម្ពុជា" ជាប្រធានបទរបាយការណ៍បញ្ចប់ឆ្នាំសិក្សាដើម្បីជួយផ្តល់ជាឯកសារ និងជាព័ត៌មានបន្ថែមដល់អ្នកដែលចង់សិក្សាស្វែងយល់ និងវិនិយោគលើវិស័យមូលបត្រ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ទីផ្សារមូលបត្រជាផ្នែកមួយយ៉ាងសំខាន់ ក្នុងការជួយជំរុញសេដ្ឋកិច្ចជាតិទាំងមូល ឬអាចនិយាយបានថា ទីផ្សារមូលបត្រជាតថភាពឆ្លុះបញ្ចាំងពីស្ថានភាពសេដ្ឋកិច្ច។ ប្រសិនបើការវិនិយោគនៅលើទីផ្សារមូលបត្រមានការរីកចម្រើន នោះសេដ្ឋកិច្ចជាតិក៏មានការរីកចម្រើនទៅតាមនោះដែរ ក៏ប៉ុន្តែដើម្បីអោយទីផ្សារមូលបត្រមានសកម្មភាពខ្លាំងខ្លា រីកចម្រើនជាលំដាប់ លុះត្រាតែមានសកម្មភាពនៃការវិនិយោគនៅលើទីផ្សារមូលបត្រកាន់តែច្រើនឡើងដែរ។ តួយ៉ាងប្រទេសកម្ពុជា ដែលការរីកចម្រើនរបស់ទីផ្សារមូលបត្រនៅមានកម្រិតនៅឡើយនោះ ដោយសារកង្វះខាតនូវចំណេះដឹងរបស់វិនិយោគិនជាកត្តាចម្បងផង ទើបប្រធានបទមួយនេះនឹងផ្តោតទៅលើបញ្ហាមួយចំនួនដូចខាងក្រោម៖

- តើទីផ្សារមូលបត្រ និងមូលបត្រមានលក្ខណៈយ៉ាងដូចម្តេចខ្លះ?
- តើទីផ្សារមូលបត្រកម្ពុជាមានទិដ្ឋភាពទូទៅដូចម្តេចខ្លះ?
- តើដំណើរការវិនិយោគ ឬជួញដូរមូលបត្រនៅផ្សារមូលបត្រកម្ពុជាមានលក្ខណៈដូចម្តេច?
- បង្ហាញពីកាលានុវត្តភាព និងបញ្ហាប្រឈមរបស់ទីផ្សារមូលបត្រកម្ពុជា។

## ៣. គោលបំណងនៃការស្រាវជ្រាវ

សម្រាប់របាយការណ៍កម្មសិក្សាក្រោមប្រធានបទ " កាលានុវត្តភាព និងបញ្ហាប្រឈមរបស់ទីផ្សារមូលបត្រកម្ពុជា " មួយនេះ ធ្វើឡើងក្នុងគោលបំណងសិក្សាស្វែងយល់ និងទុកជាប្រភពឯកសារ ឬព័ត៌មានសម្រាប់អ្នកដែលចង់បំពេញបន្ថែមនូវចំណេះដឹងពាក់ព័ន្ធនឹងវិស័យមូលបត្រ ជាពិសេសទីផ្សារមូលបត្រកម្ពុជាលើចំណុចមួយចំនួនដូចខាងក្រោម៖

- ស្វែងយល់ពីទិដ្ឋភាពទូទៅរបស់ទីផ្សារមូលបត្រ មានដូចជា សារតា តួអង្គចូលរួម ប្រភេទទីផ្សារមូលបត្រ និងមូលបត្រ
- ស្វែងយល់ពីទិដ្ឋភាពរបស់ទីផ្សារមូលបត្រកម្ពុជា រួមមាន គណៈកម្មការមូលបត្រកម្ពុជា និង ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ស្វែងយល់ជាមូលដ្ឋានពីដំណើរការវិនិយោគមូលបត្រនៅកម្ពុជា
- សិក្សាស្វែងយល់ពីកាលានុវត្តភាព និងបញ្ហាប្រឈមរបស់ទីផ្សារមូលបត្រកម្ពុជា និងធ្វើការប្រៀបធៀប។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ដែនកំណត់ និងវិសាលភាពរបស់សំណេររបាយការណ៍កម្មសិក្សាមួយនេះ គឺផ្តោតសំខាន់លើការបង្ហាញពីកាលានុវត្តភាព និង បញ្ហាប្រឈមរបស់ទីផ្សារមូលបត្រកម្ពុជា និងធ្វើការប្រៀបធៀបទិន្នន័យមូលធនូបនីយកម្មរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិទាំងអស់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩ ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីប្រមូលទិន្នន័យសំរាប់ការសរសេររបាយការណ៍កម្មសិក្សានេះ ក្រុមយើងខ្ញុំជ្រើសយកវិធីសាស្ត្រដូចខាងក្រោម៖

- ទិន្នន័យចម្បង
  - ការសម្ភាសន៍ដោយផ្ទាល់ជាមួយ លោកស្រី ហ៊ា លីគា ជាប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះ-បណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ ហើយរួមជាមួយលោកប្រធានការិយាល័យ និងមន្ត្រី នៅក្នុងនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ ដែលបានផ្តល់នូវ ឯកសារ ដំបូន្មាន គំនិត និងយោបល់ល្អៗ និងការយកចិត្តទុកដាក់មកលើយើងខ្ញុំ កំឡុងពេលចុះកម្មសិក្សា។
  - ច្បាប់ស្តីពីការបោះផ្សាយ និងការជួយដូរមូលបត្រមហាជន និង ច្បាប់ស្តីពីមូលបត្ររដ្ឋ ដែលគេបានកត់ត្រារួចរាល់ និងបានចងក្រង ហើយក្រុមយើងខ្ញុំបានយកមកជាឯកសារគោល។
- ទិន្នន័យបន្ទាប់បន្សំ
  - ឯកសារ ទាំងជាសៀវភៅ និងអេឡិចត្រូនិច ដែលទទួលបានពីការចុះកម្មសិក្សានៅ គ.ម.ក.មានដូចជា សៀវភៅ ច្បាប់ អនុក្រឹត ព្រឹត្តបត្រវិនិយោគ។
  - ទិន្នន័យជារបាយការណ៍ មានតារាង ក្រាហ្វិក ដែលបង្ហាញពីបញ្ហាស្ទួលរបស់មូលបត្រ។
  - ឯកសារពីការស្វែងរកតាមប្រព័ន្ធអិនធើណិត មានដូចជា Websites, E-Book , channel YouTube របស់ CSX Cambodia។
  - របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា “ការជួញដូរមូលបត្រនៅផ្សារមូលបត្រកម្ពុជា” របស់និស្សិតឈ្មោះ គឹម ច័ន្ទសុវណ្ណាលក្ខណា ឆ្នាំ២០១៧ និង សារណាបញ្ចប់ការសិក្សា “ដំណើរការជួញដូរមូលបត្រលើទីផ្សារមូលបត្រកម្ពុជា” របស់និស្សិតឈ្មោះ លឹម វិភា ឆ្នាំ ២០១៨ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការចងក្រងនូវរបាយការណ៍កម្មសិក្សាមួយនេះ ក្រុមយើងខ្ញុំរំពឹងថានឹងផ្តល់នូវអត្ថប្រយោជន៍ដូចជា៖

- **ចំពោះក្រុមយើងខ្ញុំ**

ការសរសេររបាយការណ៍នេះអាចជួយអោយយើងខ្ញុំយល់កាន់តែច្បាស់ពីវិស័យមូលបត្រ ពិសេសនៅប្រទេសកម្ពុជា និងទទួលបាននូវចំណេះដឹង បទពិសោធន៍ថ្មីៗតាមរយៈការអនុវត្តន៍កម្មសិក្សាផ្ទាល់នៅស្ថាប័នគណៈកម្មការមូលបត្រកម្ពុជា ជាពិសេសទទួលបានការស្វាគមន៍យ៉ាងកក់ក្តៅពីសំណាក់រៀមច្បងនៅទីនោះ។ ពួកគាត់បានតម្រែតម្រង់ផ្លូវក្រុមយើងខ្ញុំឲ្យយល់ដឹងអំពីប្រតិបត្តិការមូលបត្រ និងសកម្មភាពនានាក្នុងការងារមូលបត្រ។

- **ចំពោះគណៈកម្មការមូលបត្រកម្ពុជា**

អាចជួយផ្តល់ជាទិន្នន័យក្នុងការពិចារណាដល់គណៈកម្មការមូលបត្រកម្ពុជា តាមរយៈការវិភាគប្រៀបធៀប ពីស្ថានភាពវិនិយោគមូលបត្រនៅកម្ពុជារបស់របាយការណ៍ និងដៅពីចំណុចវិជ្ជមាន និងអវិជ្ជមានដើម្បីធ្វើអោយវិស័យមូលបត្រនៅកម្ពុជាកាន់តែមានភាពប្រសើរឡើង។

- **ចំពោះសិស្ស និស្សិត និងអ្នកសិក្សាស្រាវជ្រាវ**

របាយការណ៍នេះ អាចធ្វើជាប្រភពទិន្នន័យមួយផ្នែកសំរាប់សិស្ស និស្សិត និងអ្នកស្រាវជ្រាវដែលចង់សិក្សា ស្វែងយល់ពីមូលបត្រ និងទីផ្សារមូលបត្រ ជាទូទៅ និងនៅប្រទេសកម្ពុជា រួមមាន សារតា តួអង្គចូលរួម ។ល។ ជាពិសេសអាចទទួលបានទិន្នន័យជាក់លាក់របស់ប្រធានបទ។

- **ចំពោះវិនិយោគិន និងមហាជនទូទៅ**

របាយការណ៍នេះ ជួយអោយមហាជនទូទៅ វិនិយោគិន ជាពិសេសអ្នកដែលមានការយល់ដឹងតិចលើវិស័យមូលបត្រ អាចទទួលបាននូវចំណេះដឹងបន្ថែម លើចំណុចមួយចំនួនដូចជា អ្វីជាមូលបត្រ និងទីផ្សារមូលបត្រ ដំណើរការវិនិយោគមូលបត្រនៅកម្ពុជា ស្ថានភាព និងឥទ្ធិពលពីការវិនិយោគមូលបត្រចំពោះសេដ្ឋកិច្ច ដើម្បីជាមូលដ្ឋានក្នុងការសម្រេចចិត្តមុនឈានដល់ការវិនិយោគ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីអោយការសរសេររបាយការណ៍កម្មសិក្សាមួយនេះ អាចសម្រេចទៅបានដោយរលូន និងចំចំណុចគោលដៅនៃប្រធានបទ ក្រុមយើងខ្ញុំបានបង្កើតជាប្លង់គំរូដូចខាងក្រោម៖

- សេចក្តីផ្តើម៖ មានលំនាំបញ្ហា ចំណោទបញ្ហា គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ វិធីសាស្ត្រស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ

- ជំពូកទី១៖ រំលឹកទ្រឹស្តី ទីផ្សារមូលបត្រ
- ជំពូកទី២៖ ទិដ្ឋភាពទូទៅរបស់ទីផ្សារមូលបត្រកម្ពុជា
- ជំពូកទី៣៖ ដំណើរការវិនិយោគមូលបត្រនៅកម្ពុជា
- ជំពូកទី៤៖ កាលានុវត្តភាព និងបញ្ហាប្រឈមរបស់ទីផ្សារមូលបត្រកម្ពុជា
- សេចក្តីសន្និដ្ឋាន និងអនុសាសន៍។

**គំនូសតាងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ**



# ជំពូកទី១
# រំលឹកទ្រឹស្តី ទីផ្សារមូលបត្រ

## ១.១. សាវតារបស់ទីផ្សារមូលបត្រ

### ១.១.១. និយមន័យ

យោងទៅតាមការស្រាវជ្រាវទីផ្សារមូលបត្រ បានមកពីបន្សំរវាងពាក្យ ទីផ្សារ និង មូលបត្រ។ ទីផ្សារ សំដៅដល់ទីកន្លែងសម្រាប់ទិញ លក់ទំនិញ និង សេវា រវាងអ្នកលក់ និង អ្នកទិញក្នុងតម្លៃមួយដែលបានព្រមព្រៀងគ្នា។ ចំណែកពាក្យ មូលបត្រ សំដៅលើគំរូបណ្ណពិសេស ដែលមានលក្ខខណ្ឌគ្រប់គ្រាន់អាចដាក់អោយធ្វើការជួញដូរលើទីផ្សារមូលបត្របាន។

និយមន័យទូទៅ ទីផ្សារមូលបត្រ គឺជាផ្នែកមួយនៃទីផ្សារហិរញ្ញវត្ថុ ដែលជាទីកន្លែង ឬ ជាប្រព័ន្ធអេឡិចត្រូនិចសម្រាប់ជួញដូរមូលបត្រ និង ឧបករណ៍ហិរញ្ញវត្ថុដទៃទៀត ដែលមានដូចជា បណ្ណកម្មសិទ្ធិ ឬ បណ្ណភាគហ៊ុន និង សញ្ញាបណ្ណ ព្រមទាំងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត។

សំរាប់ប្រទេសកម្ពុជា តាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ទីផ្សារមូលបត្រ សំដៅលើ ទីផ្សារ ឬទីកន្លែងជួញដូរមូលបត្រ ឬជាប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើរលក់ ផ្ទេរ ឬ ធ្វើការទិញ/លក់មូលបត្រ។

### ១.១.២ ប្រវត្តិទីផ្សារមូលបត្រ

ទស្សនៈសម័យទំនើប នៃការបង្កើតទីផ្សារភាគហ៊ុនបានចាប់តាំងពីចុងសតវត្សទី១៦។ ទីផ្សារភាគហ៊ុនត្រូវបានចាប់ផ្តើមនៅពេលបណ្តាប្រទេសនៅក្នុងទ្វីបអាមេរិក (The New World) បានចាប់ផ្តើមធ្វើពាណិជ្ជកម្មជាមួយប្រទេសដទៃទៀតដែលមានដូចជា ហូឡង់ អេស្ប៉ាញ និង ព័រទុយហ្គាល់។ ខណៈពេលដែលឈ្មួញធំៗនៅអឺរ៉ុប មានបំណងចាប់ផ្តើមអាជីវកម្មទំហំធំដែលទាមទារឲ្យមានចំនួនទឹកប្រាក់ច្រើន ពុំមានឈ្មួញណាម្នាក់ មានប្រាក់ច្រើនសន្ធឹកសន្ធាប់សម្រាប់ចាប់ផ្តើមអាជីវកម្មដ៏ធំ បានតែម្នាក់ឯងនោះទេ។ ជាលទ្ធផល វិនិយោគិន បានយកប្រាក់សន្សំរបស់ពួកគេទៅដាក់ទុនរួម ហើយបានក្លាយជាដៃគូអាជីវកម្ម និងជាសហកម្មសិទ្ធិជាមួយនឹងចំណែកភាគហ៊ុនរបស់ខ្លួន នៅក្នុងអាជីវកម្មមួយដែលមានទម្រង់រួមទុន។ ក្រុមហ៊ុនរួមទុន ដែលមានដើមកំណើតនៅប្រទេសហូឡង់ បានក្លាយជាគំរូអាជីវកម្មមួយសម្រាប់អាជីវកម្មដទៃដែលកំពុងជួបការលំបាកផ្នែកហិរញ្ញវត្ថុ។ នៅក្នុងឆ្នាំ១៦០២ ក្រុមហ៊ុន ឌឺ ឌាចហ៍ អីស ឥណ្ឌា (The Dutch East India Co.)បានបោះផ្សាយក្រដាសតំណាងភាគហ៊ុនជាលើកដំបូង។ ឧបករណ៍ដែលអាចជួញដូរបាននេះ អនុញ្ញាតឲ្យភាគហ៊ុនិក មានភាពងាយស្រួលក្នុងការទិញ/លក់ និងធ្វើការជួញដូរភាគហ៊ុនរបស់ខ្លួន

ជាមួយនឹងម្ចាស់ភាគហ៊ុនផ្សេងៗ និង វិនិយោគិនដទៃទៀត។

គំនិតនេះទទួលបានជោគជ័យ ដោយការលក់ភាគហ៊ុនបានរីករាលដាល ដល់ប្រទេសមហាអំណាចដែនសមុទ្រផ្សេងទៀតដូចជា ប្រទេសព័រទុយហ្គាល់ អេស្ប៉ាញ និងបារាំង។ នៅទីបំផុតការអនុវត្តគំនិតនេះក៏បានរីករាលដាលដល់ចក្រភពអង់គ្លេស។ ឧស្សាហកម្មដទៃទៀត ក្នុងកំឡុងពេលបដិវត្តន៍ឧស្សាហកម្ម បានចាប់ផ្តើម ប្រើការលក់ភាគហ៊ុនជាវិធីដើម្បីប្រមូលមូលធនសម្រាប់ធ្វើការអាជីវកម្ម។ ការហូរចូលនៃមូលធននេះបានបន្តឲ្យមានការរកឃើញ និងការអភិវឌ្ឍនៃពិភពលោកថ្មី (The New World) និងការរីកលូតលាស់នៃឧស្សាហកម្មសម័យទំនើប។ ការកើនឡើងនូវបរិមាណជួញដូរភាគហ៊ុន បានជំរុញឲ្យមានការបង្កើតទីកន្លែងច្បាស់លាស់មួយសម្រាប់ជួញដូរ។ ជាលទ្ធផលពាណិជ្ជករភាគហ៊ុន បានសម្រេចជួបគ្នា នៅហាងកាហ្វេមួយនៅទីក្រុងឡុងដ៍។ ក្រោយមកហាងកាហ្វេនោះត្រូវបានពាណិជ្ជករភាគហ៊ុនទិញយក ហើយប្រែឈ្មោះក្លាយជាទីផ្សារភាគហ៊ុនដែលមានការរៀបចំ និងគ្រប់គ្រងត្រឹមត្រូវនៅក្នុងឆ្នាំ១៧៧៣។

ទីផ្សារភាគហ៊ុនទីក្រុងឡុងដ៍ (The London Stock Exchange) ជាទីផ្សារភាគហ៊ុនផ្លូវការដំបូងគេ។ គំនិតនៃការរៀបចំបែបនេះ ក៏បានហូរចូលទៅក្នុងប្រទេសអាមេរិក ហើយក៏បានចាប់ផ្តើមនៅទីក្រុង ភីឡាដែលភីយ៉ា (Philadelphia) ក្នុងឆ្នាំ ១៧៩០[2]។

## ១.២ តួអង្គសំខាន់ៗក្នុងវិស័យមូលបត្រ

ទីផ្សារមួយអាចដំណើរការទៅបានលុះត្រាតែមានអ្នកលក់ និងអ្នកទិញដើម្បីធ្វើការទិញ លក់ ទំនិញ ឬសេវាដែលបានដាក់លក់នៅលើទីផ្សារ។ ទីផ្សារមូលបត្រ ក៏ដូចជាទីផ្សារទូទៅដែរ នៅយុគសម័យវិស័យមូលបត្រមិនទាន់មានការរីកចម្រើន តួអង្គសំខាន់ៗនៅក្នុងវិស័យនេះ មាន ក្រុមហ៊ុនបោះផ្សាយ អ្នកទិញ លក់មូលបត្រ ឬអាចហៅថាជា វិនិយោគិនមូលបត្រទូទៅ និង ទីផ្សារដែលជាកន្លែងសម្រាប់ធ្វើការជួញដូរមូលបត្រ។ សម្រាប់វិស័យមូលបត្រតាមបែបទំនើបនាពេលបច្ចុប្បន្ន តួអង្គ ឬអ្នកចូលរួមសំខាន់ៗមានដូចជា៖

### ១.២.១ និយ័តករមូលបត្រ ( Securities Regulator )

វិស័យមូលបត្រមានឥទ្ធិពលយ៉ាងខ្លាំងទៅលើវិស័យសេដ្ឋកិច្ច ឬអាចនិយាយបានថា វាជាវិស័យដែលមានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយសេដ្ឋកិច្ចប្រទេសមួយ ព្រមទាំងពិភពលោកទាំងមូល។ ហេតុដូចនេះហើយទើបទីផ្សារមូលបត្រនៅតាមបណ្តាប្រទេសនីមួយៗ តែងមានស្ថាប័នមួយដើម្បីត្រួតពិនិត្យ និង ធានាប្រសិទ្ធិភាពនៃដំណើរការវិស័យមូលបត្រទាំងមូល នោះគឺ **និយ័តករមូលបត្រ**។ ដូចជា នៅសហរដ្ឋអាមេរិកមាននិយ័តករមូលបត្រ ហៅកាត់ថា SEC (Securities and exchange Commission) នៅប្រទេសអង់គ្លេសគឺ

[2] ប្រវត្តិទីផ្សារភាគហ៊ុន ព្រឹត្តិបត្រមូលបត្រ ចេញផ្សាយ លេខ២ ខែមករា ឆ្នាំ២០១៧

Financial Service Authority (FSA) នៅជប៉ុន Financial Service Agency (FSA) និង ប្រទេសកម្ពុជាគឺមាន គណៈកម្មការមូលបត្រកម្ពុជា (SECC)។

**និយ័តករមូលបត្រ** ជាស្ថាប័នរដ្ឋាភិបាលដែលមានសមត្ថកិច្ចជាអ្នករៀបចំនូវច្បាប់ បទបញ្ញត្តិ និង គោលនយោបាយនានា ពាក់ព័ន្ធនឹងវិស័យមូលបត្រ ព្រមទាំងជាអ្នកត្រួតពិនិត្យការអនុវត្តន៍ និងដំណើរការ របស់ទីផ្សារ ក្រុមហ៊ុន និងស្ថាប័នដែលបានធ្វើសកម្មភាពក្នុងវិស័យមូលបត្រ អោយមានប្រសិទ្ធិភាព ប្រសិទ្ធិផល និងអភិវឌ្ឍន៍ វិស័យមូលបត្រអោយកាន់តែមានភាពរីកចម្រើន។

ទីផ្សារមូលបត្រទាំងមូលអាចដំណើរការទៅបាន គឺស្ថិតក្រោមច្បាប់ និងបទបញ្ញត្តិនានាដែលរៀបចំ និង អនុម័តដោយអាជ្ញាធរមូលបត្រ ឬនិយ័តករមូលបត្ររបស់ប្រទេសនីមួយៗ។ ច្បាប់ និងបទបញ្ញត្តិ នៅតាម ប្រទេសនីមួយៗ អាចខុសៗគ្នាទៅតាមគោលនយោបាយរបស់ប្រទេស ប៉ុន្តែជាទូទៅ ច្បាប់ បទបញ្ញត្តិ ព្រម ទាំងគោលនយោបាយនានាដែលបានតាក់តែងឡើង គឺមានគោលដៅដើម្បីធានាប្រព័ន្ធទីផ្សារមូលបត្រទាំងមូល មានសុក្រឹតភាព តម្លាភាព ជាពិសេសផ្នែកព័ត៌មាន របាយការណ៍ហិរញ្ញវត្ថុ និងអភិបាលកិច្ចនៅក្នុងក្រុមហ៊ុន សហគ្រាស ព្រមទាំងការពារ វិនិយោគិន និងគ្រប់គ្រងហានិភ័យក្នុងវិស័យមូលបត្រនេះផងដែរ[3]។

### ១.២.២ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ( Listed company or ISSUER )

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ អាចជាក្រុមហ៊ុនឯកជន ឬ ស្ថាប័នរដ្ឋដែលបានចុះបញ្ជីរ ហើយធ្វើ ការបោះផ្សាយលក់មូលបត្រ ដូចជា សញ្ញាបណ្ណ និង បណ្ណភាគហ៊ុន ដើម្បីប្រមូលមូលធនបន្ថែមយកទៅប្រើ ប្រាស់ក្នុងដំណើរការអាជីវកម្ម ឬផែនការរបស់ស្ថាប័ន។ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ជាក្រុមហ៊ុនដែល មានការទទួលស្គាល់ពីសាធារណៈជនទូទៅ មានស្ថានភាពហិរញ្ញវត្ថុរឹងមាំ ពិសេសគឺតម្រូវអោយធ្វើការបង្ហាញ នូវព័ត៌មាននានា ព្រមទាំងបំពេញតាមលក្ខខណ្ឌផ្សេងៗដែលបានចែងស្របច្បាប់មូលបត្រ។

មិនមានបុគ្គល ឬស្ថាប័នណាមួយអាចបោះផ្សាយ និងលក់មូលបត្រជាសាធារណៈបានទេលើកលែង តែស្ថាប័ននោះទទួលបានការអនុញ្ញាតពី គ.ម.ក.។ នៅប្រទេសកម្ពុជា ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ជា ប្រភេទក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត (Public Limited Company) ដែលបានចុះបញ្ជីពាណិជ្ជកម្ម ឬនីតិបុគ្គលប្រតិស្រុត (Permitted Entity) ដែលត្រូវបានកំណត់ស្របតាមច្បាប់ និងលិខិតបទដ្ឋាននានា[4]។

### ១.២.៣ ក្រុមហ៊ុនមូលបត្រ ( Securities Firm )

នៅក្នុងប្រព័ន្ធជួញដូររបស់ទីផ្សារមូលបត្រ ជាទូទៅមូលបត្រដែលបានបោះផ្សាយរួច ជាពិសេសមូលបត្រ

[3] បៀន សាំង “មូលដ្ឋានគ្រឹះទីផ្សារមូលបត្រ” បោះពុម្ពលើកទី១ ឆ្នាំ២០១១ ទំព័រ៣

[4] ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

ដែលបោះផ្សាយជាលើកដំបូង ឬហៅថា IPO(Initial Public Offering) អាចជួញដូរបានពីភាគីវិនិយោគិនមួយទៅវិនិយោគិនមួយ តាមរយៈក្រុមហ៊ុនមូលបត្រ ព្រោះមានភាពងាយស្រួល និងមានហានិភ័យទាបជាងការជួញដូរផ្ទាល់ជាមួយក្រុមហ៊ុនបោះផ្សាយ។ ក្រុមហ៊ុនមូលបត្រអាចហៅបានថាជា **អន្តរការីមូលបត្រ ឬ អន្តរការីទីផ្សារ (Securities Intermediaries)** អាចជាធនាគារវិនិយោគ ក្រុមហ៊ុនប្រឹក្សាវិនិយោគ និងឈ្មួញជើងសាមូលបត្រដែលផ្តល់សេវាប្រឹក្សា និងស្វែងរកទីផ្សារ ឬលក់មូលបត្រពីក្រុមហ៊ុន ស្ថាប័នបោះផ្សាយទៅកាន់វិនិយោគិនសាធារណៈ ព្រមទាំងជាអន្តរការីជួយវិនិយោគិនទិញ/លក់មូលបត្រនៅផ្សារបន្ទាប់។

**ក. ក្រុមហ៊ុនធានាទិញមូលបត្រ (Securities Underwriting)**

ក្រុមហ៊ុនធានាទិញមូលបត្រ ជាស្ថាប័នដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការទិញលក់ និងផ្សព្វផ្សាយមូលបត្រជាសាធារណៈពីក្រុមហ៊ុនបោះផ្សាយ។ តួនាទីស្នូលរបស់ក្រុមហ៊ុននេះ គឺជួយក្រុមហ៊ុនចុះបញ្ជីបោះ-ផ្សាយលក់ភាគហ៊ុនលើកដំបូង (IPO) ជាសារធារណៈក្នុងទីផ្សារដំបូង(Primary market) និងមានមុខងារជាអ្នកផ្តល់ប្រឹក្សាពីនីតិវិធីនៃការបោះផ្សាយ ការដាក់តម្លៃមូលបត្រ(Pricing) ការកំណត់ទំហំទឹកប្រាក់(Issue Amount) ការកំណត់ពេលវេលានៃការបោះផ្សាយ (Distribution Timely) និងចំនួនមូលបត្រដែលត្រូវបោះផ្សាយ(Number to be Issue)។ លើសពីនេះទៅទៀត ក្រុមហ៊ុននេះក៏ធានាទិញមូលបត្រមួយផ្នែក ឬទាំងអស់ពីក្រុមហ៊ុនបោះផ្សាយក្នុងគោលដៅចែកចាយ និងលក់បន្តទៅកាន់វិនិយោគិនទូទៅនៅលើទីផ្សារ។ ក្រុមហ៊ុនធានាទិញមូលបត្រដែលទទួលបានអាជ្ញាបណ្ណ អាចធ្វើសកម្មភាពអាជីវកម្មមូលបត្រ ដូចជា អាជីវកម្មធានាទិញមូលបត្រ អាជីវកម្មជួញដូរមូលបត្រ អាជីវកម្មជើងសាមូលបត្រ និងអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ។

**ខ. ក្រុមហ៊ុនពាណិជ្ជករមូលបត្រ (Securities Dealing, Dealer)**

ក្រុមហ៊ុនពាណិជ្ជករមូលបត្រ ឬអាជីវកម្មជួញដូរមូលបត្រ មានមុខងារជាអ្នកទិញមូលបត្របន្តពីក្រុមហ៊ុនធានាទិញមូលបត្រ ហើយធ្វើការជួញដូរលើគណនីផ្ទាល់ខ្លួន ព្រមទាំងរ៉ាប់រងហានិភ័យដោយខ្លួនឯង មានន័យថាក្រុមហ៊ុនពាណិជ្ជករមូលបត្រនេះ ជួញដូរមូលបត្រដោយខ្លួនឯង និងទទួលខុសត្រូវលើផលចំណេញ និងការខាតបង់ពីការជួញដូរ។ ក្រុមហ៊ុនពាណិជ្ជករមូលបត្រ ឬអាជីវកម្មជួញដូរមូលបត្រអាចធ្វើសកម្មភាពជាក្រុមហ៊ុនជួញដូរមូលបត្រ ក្រុមហ៊ុនជើងសារមូលបត្រ និងក្រុមហ៊ុនផ្តល់សេវាប្រឹក្សាវិនិយោគ។

**គ. ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ (Securities Brokerage, Broker)**

ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ ឬអាជីវកម្មជើងសាមូលបត្រ ធ្វើការទិញ លក់មូលបត្រក្នុងនាម និងតាមបញ្ជារបស់អតិថិជន ដោយទទួលបានកម្រៃជើងសា (Commission) ព្រមទាំងអាចធ្វើសកម្មភាពជាក្រុមហ៊ុនប្រឹក្សាវិនិយោគផងដែរ។

**ឃ. ក្រុមហ៊ុនប្រឹក្សាវិនិយោគ** ( Securities Advisory )

ក្រុមហ៊ុនប្រឹក្សាវិនិយោគ (អាចហៅបានថាជា Investment Advisor)ជាក្រុមហ៊ុនផ្តល់សេវាជាអ្នកប្រឹក្សាជាមួយវិនិយោគិនដែលចង់វិនិយោគលើវិស័យណាមួយ ពិសេសវិស័យមូលបត្រ និងជាអ្នកផ្តល់ព័ត៌មានវិនិយោគផងដែរ។ ក្រុមហ៊ុនប្រឹក្សាវិនិយោគ មានតួនាទីចម្បង២ គឺៈ

- ផ្តល់ប្រឹក្សាអំពីការវិនិយោគលើមូលបត្រដល់វិនិយោគិនសាធារណៈ ដោយទទួលបានកម្រៃសេវា
- បោះពុម្ពផ្សាយសេចក្តីវិភាគអំពីការវិនិយោគលើមូលបត្រជូនដល់វិនិយោគិនសាធារណៈ ការបោះពុម្ពផ្សាយនេះមានដូចជា ព្រឹត្តិបត្រវិភាគប្រចាំសប្តាហ៍ ឬទស្សនាវដ្តីវិភាគប្រចាំខែ ដោយមានបង្ហាញពីទិដ្ឋភាពទូទៅរបស់សេដ្ឋកិច្ច ស្ថានភាពទូទៅរបស់ទីផ្សារមូលបត្រ វិស័យវិនិយោគណាដែលមានសក្តានុពល និងវិស័យវិនិយោគដែលមានហានិភ័យ។ល។

**១.២.៤ វិនិយោគិនសាធារណៈ** ( Public Investors )

នៅក្នុងវិស័យមូលបត្រ វិនិយោគិនសំដៅដល់ សាធារណៈជនដែលបានទិញ កាន់កាប់ និងជួញដូរមូលបត្រ ដោយរំពឹងថានឹងទទួលបានចំណូលហិរញ្ញវត្ថុនាពេលអនាគត ដូចជា ភាគលាភ និងការប្រាក់។ វិនិយោគិនសាធារណៈចែកជា ២ប្រភេទដោយផ្អែកទៅតាមចំណាត់ថ្នាក់ផ្សេងគ្នាគឺៈ

- ចំណាត់ថ្នាក់វិនិយោគិនតាមបុគ្គល
  - វិនិយោគិនជារូបវ័ន្តបុគ្គល ឬសាធារណៈជនទូទៅ(Individual investors)
  - វិនិយោគិនជានីតិបុគ្គល ឬជាស្ថាប័ន(Institutional investors)
- ចំណាត់ថ្នាក់វិនិយោគិនតាមអត្តចរិត
  - វិនិយោគិនរយៈពេលវែង
  - វិនិយោគិនរយៈពេលខ្លី

**១.២.៥ ទីផ្សារមូលបត្រ** ( Securities Market )

ទីផ្សារមូលបត្រ តាមនិយមន័យទូទៅ គឺជាកន្លែងដែលប្រមូលផ្តុំទៅដោយវិនិយោគិន អន្តរការីមូលបត្រដើម្បីធ្វើប្រតិបត្តិការទិញ/លក់មូលបត្រ។ ទីផ្សារមូលបត្រអាចជាស្ថាប័នដែលមានទីកន្លែងពិតប្រាកដ ដូចជា New York Stock Exchange(NYSE), Bombay Stock Exchange(India) ឬជាប្រព័ន្ធអេឡិចត្រូនិច ដែលធ្វើប្រតិបត្តិការជួញដូរមូលបត្រដូចជា NASDAQ ដែលជាទីផ្សារជួញដូរតាមប្រព័ន្ធអេឡិត្រូនិចធំជាងគេនៅសហរដ្ឋអាមេរិក។ សំរាប់ទីផ្សារមូលបត្រនៅក្នុងប្រទេសអភិវឌ្ឍន៍តួយ៉ាងសហរដ្ឋអាមេរិក ទំហំនៃការជួញដូរលើមូលបត្រពិសេសគឺ បណ្ណភាគហ៊ុនគិតជាទឹកប្រាក់ (Market capitalization) មានចំនួនយ៉ាងច្រើនសន្ធឹក

សន្ទាប់ ជាក់ស្តែង NYSE ទំហំនៃការជួញដូរមានចំនួនដល់ទៅ ២២,៩០០ សែនកោដិដុល្លារ(22.9 trillion) នៅឆ្នាំ២០១៩ ចំណែក ទីផ្សាររបស់ NASDAQ ទំហំភាគហ៊ុនដែលបានជួញដូរមានទំនោរប្រែប្រួលកើនឡើងជាលំដាប់គឺ ៩៣ាន់លានដុល្លារ នៅឆ្នាំ២០១៥ និង ១៩ពាន់លានដុល្លារក្នុង ខែកុម្ភៈ ឆ្នាំ២០២០ (ប៉ុន្តែមានការធ្លាក់ចុះដល់ ១៣.២៧ ពាន់លានដុល្លារនៅខែមិនា ដោយសារវិបត្តិជំងឺឆ្លងនៅលើពិភពលោក ហើយមានការកើនឡើងវិញដល់ ១៨.៣៤ ពាន់លានដុល្លារនៅ ខែមេសា)[5]។

### ១.២.៦ តួអង្គផ្សេងទៀត

**ក. ភ្នាក់ងារបញ្ជិការមូលបត្រ** (Securities Registrar Agent)

ភ្នាក់ងារបញ្ជិកាមូលបត្រមានមុខងារ គ្រប់គ្រងនូវដំណើរការនៃការធ្វើបរិវិសកម្ម និងការបែងចែងមូលបត្រកត់ត្រាបញ្ជីរកម្មសិទ្ធិករមូលបត្រ ធ្វើរបាយការណ៍ស្តីពីការបញ្ចប់ និងជោគជ័យនៃការរក្សាទុកមូលបត្រ។

**ខ. ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ** (Transfer Agent)

មានតួនាទី រក្សា និងគ្រប់គ្រងបញ្ជីកម្មសិទ្ធិករមូលបត្រ, ធ្វើរដ្ឋបាលកិច្ចពាក់ព័ន្ធនឹងការផ្លាស់ប្តូរកម្មសិទ្ធិ ធ្វើរបាយការណ៍ ស្ថិតិ , រៀបចំការជូនដំណឹងអំពីការបែងចែកភាគលាភ និងការបង់ប្រាក់។ល។

**គ. ភ្នាក់ងារទូទាត់** (Paying Agent)

មានមុខងារ គណនាភាគលាភ ការប្រាក់ និងប្រាក់ដើម ធ្វើការទូទាត់ជូនកម្មសិទ្ធិករ ឬភាគីពាក់ព័ន្ធក្នុងនាមក្រុមហ៊ុនបោះផ្សាយ បញ្ជូនព័ត៌មានចាំបាច់ដែលពាក់ព័ន្ធនឹងការទូទាត់ ឬព័ត៌មានផ្សេងទៀតដល់កម្មសិទ្ធិករមូលបត្រ ក្រុមហ៊ុនបោះផ្សាយ និង គ.ម.ក. តាមការចាំបាច់។

**ឃ. ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ** (Cash Settlement Agent)

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ មានតួនាទី៖

- ធ្វើការគ្រប់គ្រងគណនីសាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដូចជាការផ្ទេរ ឬការបង្វិលសាច់ប្រាក់រវាងភាគីជួញដូរ
- ធានាប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រប្រកបដោយសុវត្ថិភាព
- បំពេញប្រតិបត្តិដាច់ដោយឡែកពីមុខងារប្រតិបត្តិការធនាគារ

**ង. ភ្នាក់ងារតំណាងម្ចាស់បំណុល** (Bondholder Representatives)

ភ្នាក់ងារតំណាងម្ចាស់បំណុលមានក្រុមហ៊ុនចូលរួមដូចជា៖

- ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់(Law firms)

[5] https://www.macrotrends.net/stocks/charts/NDAQ/nasdaq/market-cap

- ក្រុមហ៊ុនគណនេយ្យជំនាញ (Professional Accounting Firms)៖ មានមុខងារធ្វើសវនកម្មរបាយ-ការណ៍ហិរញ្ញវត្ថុ តាមស្តង់ដារដែលបានកំណត់។
- ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ (Valuation Companies)៖ មានមុខងារវាយតម្លៃទ្រព្យសកម្មរបស់ស្ថាប័នដែលធ្វើធុរកិច្ចក្នុងវិស័យមូលបត្រ ទៅតាមស្តង់ដារដែលបានកំណត់។
- ក្រុមហ៊ុនផ្តល់សេវាបកប្រែ (Translation Service Company)៖ មានមុខងារ បកប្រែឯកសារពាក់ព័ន្ធនឹងIPO អោយបានត្រឹមត្រូវតាមន័យដើម។
- ក្រុមហ៊ុនផ្តល់សេវាបោះពុម្ព (Printing Service Company)
- ក្រុមហ៊ុនសារព័ត៌មាន (Media Company)
- ភ្នាក់ងារវាយតម្លៃលទ្ធភាពសងបំណុល៖ មានមុខងារ វាយតម្លៃពីលទ្ធភាពសងរបស់ក្រុមហ៊ុន ឬស្ថាប័នបោះផ្សាយ និងភាគីពាក់ព័ន្ធផ្សេងទៀត។

## ១.៣ ប្រភេទទីផ្សារមូលបត្រ

### ១.៣.១ ទីផ្សារដំបូង ( Primary Market )

ទីផ្សារដំបូង ជាកន្លែងសំរាប់ជួញដូរមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយដែលធ្វើការបោះផ្សាយលក់ជាលើកដំបូងនៅលើទីផ្សារទៅកាន់វិនិយោគិនជាសាធារណៈ។

ការជួញដូរនៅលើទីផ្សារដំបូង ត្រូវឆ្លងកាត់អន្តរការីមូលបត្រ ឬក្រុមហ៊ុនធានាទិញមូលបត្ររួមមានធនាគារវិនិយោគ ដែលជាភាគីកណ្តាលជួយសម្រួលដល់ការទិញ-លក់មូលបត្ររវាងក្រុមហ៊ុនបោះផ្សាយ និងវិនិយោគិន ព្រមទាំងធ្វើការដាក់តម្លៃដេញថ្លៃដំបូង និង កាលបរិច្ឆេទនៃការជួញដូរ។ ដំណើរការលក់ភាគហ៊ុនទៅកាន់សាធារណៈជនជាលើកដំបូងហៅថា "ការនាំក្រុមហ៊ុនទៅកាន់សាធារណៈ" (Taking Company Public)។ នៅក្នុងប្រទេសមួយចំនួនដែលធ្លាប់ជាអតីតរដ្ឋរបស់សហភាពសូវៀត និង ប្រទេសកុម្មុយនីសមួយចំនួនប្រើពាក្យថា "Taking the Company Private" ជំនួសវិញ។ ប្រសិនបើក្រុមហ៊ុនបោះផ្សាយត្រូវការមូលធនបន្ថែមទៀត ហើយសម្រេចធ្វើការបោះផ្សាយមូលបត្រជាលើកទីពីរ ឬលើកក្រោយៗទៀត ការបោះផ្សាយនោះមិនមែនជាការបោះផ្សាយមូលបត្រជាលើកដំបូងឬ IPOទេ ការបោះផ្សាយនោះ ហៅថា**Seasoned Equity Issue**។

### ១.៣.២ ទីផ្សារបន្ទាប់ (Secondary Market)

ទីផ្សារបន្ទាប់ ជាទីផ្សារដែលជួញដូរមូលបត្រ បន្ទាប់ពីផ្សារដំបូង មានន័យថា ក្រោយពីមូលបត្រដែលទើបបោះផ្សាយរួចត្រូវបានលក់ចេញពីក្រុមហ៊ុនបោះផ្សាយទៅកាន់វិនិយោគិនសាធារណៈ។ នៅទីផ្សារបន្ទាប់

ការជួញដូរមូលបត្រកើតមានជាប្រចាំរវាងវិនិយោគិន បន្ទាប់ពីបានទិញមូលបត្រពីក្រុមហ៊ុនបោះផ្សាយ មានក្រុមហ៊ុនសាជីវកម្ម និងស្ថាប័នរដ្ឋាភិបាល ពីទីផ្សារដំបូង។ ទីផ្សារបន្ទាប់អាចហៅថាជាផ្សារភាគហ៊ុន ដែលមានជាអាទិ៍ NYSE ដែលចាប់ផ្តើមបើកការជួញដូរនៅឆ្នាំ 1792, London stock exchange, NASDAQ (ប្រព័ន្ធជួញដូរនេះ បង្កើតឡើងនៅឆ្នាំ 1971), the DAX នៅប្រទេសអាល្លឺម៉ង់ ដែលសុទ្ធតែជាទីផ្សារធំៗនៅលើពិភពលោក។

នៅសហរដ្ឋអាមេរិក មូលបត្រ ឬភាគហ៊ុនដែលបានចរាចរជួញដូរ មិនមែនសុទ្ធតែចុះបញ្ជីដើម្បីជួញដូរនៅស្ថាប័នទីផ្សារមូលបត្រ (NYSE) ឬ NASDAQ ទាំងអស់នោះទេ។ ក្រុមហ៊ុនបោះផ្សាយមួយចំនួនចុះបញ្ជីលក់មូលបត្រនៅទីផ្សារក្នុងតំបន់ (Regional Exchange) ដូចជានៅទីក្រុង ភីឡាឌែលភីយ៉ា (Philadelphia) ការចុះបញ្ជីដើម្បីជួញដូរមូលបត្រមានភាពងាយស្រួលជាង NYSE។ ជាឧទាហរណ៍៖ មូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុន Microsoft មិនបានចុះបញ្ជីលក់នៅស្ថាប័នទីផ្សារមូលបត្រល្បីណាមួយឡើយ ប៉ុន្តែមូលបត្រកម្មសិទ្ធិរបស់ ក្រុមហ៊ុន Microsoft មានទំហំជួញដូរសរុប 251 ពាន់លានដុល្លារ នៅចុងឆ្នាំ2010[6]។ ចាប់តាំងពីភាពរីកចម្រើននៃបច្ចេកវិទ្យាទំនើបមក ការជួញដូរមូលបត្រនៅស្ថាប័នទីផ្សារមូលបត្រ មានការរួមបញ្ចូលទាំងការជួញដូរនៅទីកន្លែងក្នុងផ្សារមូលបត្រ (An open-outcry auction model) និងការជួញដូរតាមប្រព័ន្ធអេឡិចត្រូនិច ឬ ប្រព័ន្ធកុំព្យូទ័រ (Electronic Trading) ហើយជាក់ស្តែងការជួញដូរតាមប្រព័ន្ធអេឡិចត្រូនិចនេះមានសកម្មភាពល្អផងដែរ។ ជាឧទាហរណ៍៖ ទីផ្សារភាគហ៊ុននៅក្រុង Toronto ប្រទេសកាណាដា (The Toronto Stock Exchange) បានលុបចោលទីកន្លែងជួញដូរ (Exchange Floor) របស់ខ្លួន។ ក្រុមហ៊ុនបោះផ្សាយមិនទទួលបានផលចំណេញហិរញ្ញវត្ថុពីការជួញដូរនៅផ្សារបន្ទាប់ទេ ព្រោះមូលបត្រនោះបានផ្ទេរកម្មសិទ្ធិទៅកាន់វិនិយោគិនដែលបានទិញមូលបត្រពីក្រុមហ៊ុនបោះផ្សាយរួចហើយ។ មូលបត្រដែលជួញដូរនៅផ្សារបន្ទាប់អាចត្រូវបានជួញដូរនៅក្នុង **ស្ថាប័នទីផ្សារមូលបត្រ (Organized Exchange)** ឬ ក្រៅផ្សារមូលបត្រ ដែលហៅថា **ទីផ្សាររំលងបញ្ជារ (Over-the-Counter)**។

ភាពខុសគ្នារវាងស្ថាប័នទីផ្សារមូលបត្រ (Organized Exchange) និង ទីផ្សាររំលងបញ្ជារ (Over-the-Counter) គឺ ទីផ្សារមូលបត្រមានទីកន្លែងជួញដូរជាក់លាក់ មានវិធានការ និងប្រព័ន្ធគ្រប់គ្រងដំណើរការជួញដូរ។ ចំណែកទីផ្សាររំលងបញ្ជារ ឬ OTC ការជួញដូរមូលបត្រធ្វើឡើងតាមរយៈ ការភ្ជាប់ប្រព័ន្ធកុំព្យូទ័រ ឬ ទូរស័ព្ទ អ៊ីម៉ែល ឬប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនណាមួយ ដោយធ្វើការចចាររវាងវិនិយោគិន និងមិនធ្វើឡើងតាមប្រព័ន្ធទីផ្សារមូលបត្រទេ។

---

[6] Financial Markets and Institutions, Frederic S. Miskin • Stanley G. Eakins 9th edition, 2018

បច្ចុប្បន្ន នៅប្រទេសកម្ពុជាមានផ្សារមូលបត្រ(Organized Exchange) តែមួយគត់ដែលដំណើរការជួញដូរមូលបត្រ គឺក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា(CSX) និងពុំទាន់មានទីផ្សារក្រៅប្រព័ន្ធ OTC នៅឡើយទេ ដូចនេះវិនិយោគិនមិនអាចទិញ/លក់មូលបត្រដោយផ្ទាល់បាននោះទេ។ ជាសរុបទីផ្សារមូលបត្រអាចបែងចែកជាប្រភេទផ្សេងៗទៀត ទៅតាមមូលដ្ឋានខុសៗគ្នា៖

- **មូលដ្ឋានតាមរចនាសម្ព័ន្ធទីផ្សារ**
  - ស្ថាប័នផ្សារមូលបត្រ (Organized Exchange)
  - ទីផ្សាររំលងបញ្ជារ (Over-the-Counter)
- **មូលដ្ឋានតាមដំណាក់កាលនៃការបោះផ្សាយ និងការជួញដូរ**
  - ទីផ្សារដំបូង (Primary Market)
  - ទីផ្សារបន្ទាប់ (Secondary Market)
- **មូលដ្ឋានតាមការិយបរិច្ឆេទ**
  - ផ្សាររូបិយវត្ថុ ( Money market) ជាទីផ្សារសំរាប់វិនិយោគលើមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុរយៈពេលខ្លី(<1ឆ្នាំ) ហើយភាគច្រើនជាមូលបត្របំណុល ឬជាបណ្ណបំណុលសាជីវកម្មរយៈពេលខ្លី (Commercial paper) បណ្ណរតនាគាររយៈពេលខ្លី (T-Bills)។ នៅកម្ពុជាមានការចរាចរនូវមូលបត្រអាចជួញដូរបាន (Negotiable Certificate of Deposits) ដែលចេញដោយធនាគារជាតិនៃកម្ពុជា[7]។
  - ផ្សារមូលធន (Capital Market) ជាទីផ្សារជួញដូរមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុរយៈពេលវែង ឬផ្សារវិនិយោគរយៈពេលវែង (លើសពី១ឆ្នាំ)។ មូលបត្រដែលជួញដូរនៅលើផ្សារមូលធនភាគច្រើនជាសញ្ញាបណ្ណ ដូចជា បណ្ណរតនាគាររយៈពេលវែង (Treasury Notes and Bonds) សញ្ញាបណ្ណសាជីវកម្ម(Corporate Bonds) និងមូលបត្រកម្មសិទ្ធិ (Stock) ជាដើម[8]។ ផ្សារមូលធនចែកជា២ គឺ៖ ផ្សារសញ្ញាបណ្ណ(Bond Market) និងផ្សារភាគហ៊ុន(Stock Market)។
- **មូលដ្ឋានតាមប្រភេទប្រតិបត្តិការ**
  - ទីផ្សារសាច់ប្រាក់ (Cash Market)
  - ទីផ្សារដេរីវេទីវ (Derivatives Market)

[7] https://www.nbc.org.kh/monetary_policy/ncds_overview.php

[8] Financial Markets and Institutions, Frederic S. Miskin • Stanley G. Eakins 9th edition, 2018, *Bond market page 308*

- **មូលដ្ឋានតាមប្រភេទអ្នកបោះផ្សាយ**
  - ទីផ្សារមូលបត្ររដ្ឋ (Government securities market)
  - ទីផ្សារមូលបត្រសារជីវកម្ម (Corporate securities market)

## ១.៤ មូលបត្រ

### ១.៤.១ និយមន័យ

កាលពីវិស័យវិនិយោគលើមូលបត្រមិនទាន់មានការរីកចម្រើន មូលបត្រគ្រាន់តែជាសន្លឹកបណ្ណ ឬជាឯកសារយោងសម្រាប់បញ្ជាក់ពីការវិនិយោគប៉ុណ្ណោះ។ នៅក្នុងទីផ្សារហិរញ្ញវត្ថុបច្ចុប្បន្ន ការស្វែងយល់ឲ្យច្បាស់ពីពាក្យ មូលបត្រ ឬ Stocks និង ភាគហ៊ុន (Shares) ហាក់មានភាពស្រពិចស្រពិលនៅក្នុងចំណោមមហាជនភាគច្រើន។ ជាទូទៅ ពាក្យទាំងពីរនេះត្រូវបានប្រើប្រាស់ ជំនួសគ្នាបានដែលសំដៅលើក្រដាសមួយសន្លឹកដែលប្រកាសភាពជាកម្មសិទ្ធិស្របច្បាប់នៅក្នុងក្រុមហ៊ុនណាមួយ ដែលឲ្យឈ្មោះថា វិញ្ញាបនបត្រទិញភាគហ៊ុន (Stock Certificates)។ យ៉ាងណាមិញនិយាយឲ្យត្រឹមត្រូវតាមបច្ចេកទេស ពាក្យទាំងពីរនេះមានន័យខុសគ្នា។ ពាក្យថា ភាគហ៊ុន ឬ Shares គ្រាន់តែជាផ្នែកមួយនៃមូលបត្រប៉ុណ្ណោះ។ នេះមានន័យថាក្រៅពីភាគហ៊ុននៅមានប្រភេទមូលបត្រផ្សេងៗជាច្រើនទៀតដែលគេយកមកធ្វើការទិញលក់ នៅក្នុងទីផ្សារមូល-បត្រដែរ ដូចជា មូលបត្របំណុល ឬជាឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត។

មូលបត្រ ត្រូវបានអោយនិយមន័យជាក់លាក់ទៅតាមច្បាប់ និងបទបញ្ញត្តិរបស់ប្រទេសនីមួយៗ និងប្រភេទមូលបត្រផងដែរ។ ជាទូទៅ **មូលបត្រ** គឺជា វិញ្ញាបនបត្រ ឬឧបករណ៍ហិរញ្ញវត្ថុដែលបញ្ជាក់ពីតម្លៃនៃការវិនិយោគ និងអាចជួញដូរបាន។

### ១.៤.២ ប្រភេទមូលបត្រ

#### ក. មូលបត្របំណុល

តាមន័យទូទៅ មូលបត្របំណុល (Debt Securities) ជាប្រភេទបណ្ណ ឬវិញ្ញាបនបត្រចេញដោយក្រុមហ៊ុនបោះផ្សាយ ដែលបញ្ជាក់ពីបំណុល ពោលគឺក្រុមហ៊ុន ឬស្ថាប័នបោះផ្សាយ ត្រូវការមូលធនបន្ថែមហើយធ្វើការប្រមូលមូលធនដោយបោះចេញជាប័ណ្ណបំណុល លក់ទៅឲ្យវិនិយោគិនសាធារណៈ ជំនួសដោយការទទួលបានមូលធនមកវិញ។ មូលបត្របំណុល (Debt Securities) សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុដែលបោះផ្សាយដោយបុគ្គលណាមួយ ដោយបញ្ជាក់ ឬទទួលស្គាល់នូវបំណុលរបស់ខ្លួនចំពោះបុគ្គលមួយទៀតដែលអោយប្រាក់ខ្ចី ឬ ដាក់ជាប្រាក់បញ្ញើរជាមួយបុគ្គលនោះ ឬ បុគ្គលនោះជំពាក់តាមវិធីផ្សេងពីនេះ ហើយ

ទោះបីជាមាន ឬ គ្មានទ្រព្យដាក់ធានាក្តី[9]។

ការវិនិយោគលើមូលបត្របំណុល មានជាអាទិ៍ សញ្ញាប័ណ្ណ(Bond)មានហានិភ័យទាបជាងការវិនិយោគលើភាគហ៊ុន ឬ គ្មានហានិភ័យ ( Zero Default Risk) ចំពោះបណ្ណរតនាគាររយៈពេលខ្លី (T-Bills) ជាដើម។ លក្ខណៈវិនិយោគលើមូលបត្របំណុលគឺ៖

- អ្នកទិញមូលបត្រក្លាយជាម្ចាស់បំណុល ជំនួសការទូទាត់មូលធនទៅភាគីស្ថាប័នបោះផ្សាយ
- ក្រុមហ៊ុន ឬស្ថាប័នបោះផ្សាយ ក្លាយជាកូនបំណុលដែលមានកាតព្វកិច្ចបង់ការប្រាក់ (Coupon) ទៅតាមគ្រានីមួយៗដែលបានកំណត់ និងសងប្រាក់ដើមទៅអ្នកដែលបានទិញមូលបត្រនៅកាលបរិច្ឆេទកំណត់សង (Maturity Date)។

មូលបត្របំណុល មានច្រើនប្រភេទដូចជា៖

- ➢ សញ្ញាបណ្ណសាជីវកម្ម(Corporate Bonds) មាន ផលបត្រពាណិជ្ជកម្ម (Commercial Paper), Unsecured bonds or Debentures , Secured Bonds, Junk Bonds
- ➢ សញ្ញាបណ្ណរដ្ឋ(State Issued Bonds)មាន Municipal Bonds , State Government Bonds
- ➢ បណ្ណរតនាគារ(Treasury)មាន T-Bills, T-Notes, T-Bonds។

**ខ. មូលបត្រកម្មសិទ្ធិ**

តាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន មូលបត្រកម្មសិទ្ធិ (Equity Securities) សំដៅដល់ផលប្រយោជន៍ ឬសិទ្ធិស្របច្បាប់លើមូលបត្រនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលបរទេសប្រហាក់ប្រហែល ហើយរាប់បញ្ចូលទាំងភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត និងគ្មានសិទ្ធិបោះឆ្នោត ភាគហ៊ុនមិនបង់ថ្លៃគ្រប់ និងភាគហ៊ុនបុរិមា។ តាមន័យទូទៅ មូលបត្រកម្មសិទ្ធិ (Equity Securities) ប្រភេទបណ្ណ ឬវិញ្ញាបនបត្រចេញដោយក្រុមហ៊ុនសាធារណៈ (Public Company) ដែលបញ្ជាក់ពីកម្មសិទ្ធិ ដើម្បីកៀរគរមូលធនពីសាធារណៈជន។ លក្ខណៈវិនិយោគលើមូលបត្រកម្មសិទ្ធិគឺ៖

- អ្នកទិញមូលបត្រកម្មសិទ្ធិ ក្លាយជាម្ចាស់ក្រុមហ៊ុនតាមសមាមាត្រចំនួនមូលបត្រដែលបានទិញ
- អ្នកកាន់កាប់មូលបត្រកម្មសិទ្ធិ ទទួលបានផលចំណេញ ឬការខាតបង់មូលធន (Capital Gain/Loss) ពីការឡើងចុះតម្លៃភាគហ៊ុន, ភាគលាភ (Dividend) ជាប្រចាំ (ឆមាស ឬឆ្នាំ) ទៅតាមលក្ខខណ្ឌដែលបានកំណត់

[9] ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

- មានសិទ្ធិសម្រេច (បោះឆ្នោត) នៅក្នុងក្រុមហ៊ុន តាមសមាមាត្រចំនួនមូលបត្រដែលបានទិញ លើកលែងភាគហ៊ុនបុរិមា។

មូលបត្រកម្មសិទ្ធិមានដូចជា៖

- ភាគហ៊ុនធម្មតា (Common Stock/Ordinary Shares)
- ភាគហ៊ុនបុរិមា(Preferred Stock)។

**គ. ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវ**( Derivative Instrument )

តាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជននៃប្រទេសកម្ពុជា ឧបករណ៍និស្សន្ទ ជាកិច្ចសន្យាដែលផ្តល់សិទ្ធិ ឬកាតព្វកិច្ចនៃមូលបត្រដើមទៅអោយបុគ្គលណាមួយដោយរាប់បញ្ចូលទាំងសិទ្ធិ ឬ កាតព្វកិច្ចទិញ លក់ ឬ ដាក់ពាក្យ សុំទិញមូលបត្រក្នុងពេលអនាគត ដោយមិនគិតថាបុគ្គលនេះមានបំណងប្រើសិទ្ធិ ឬ មិនប្រើសិទ្ធប្រើប្រាស់នេះក៏ដោយ។ ន័យមួយទៀត ឧបករណ៍និស្សន្ទ ជាកិច្ចសន្យារវាងភាគីវិនិយោគ ដើម្បីកំណត់តម្លៃមូលបត្រទុកជាមុនតាមការចចារ ចៀសវាងការប្រែប្រួលថ្លៃមូលបត្រនាពេលអនាគត។ ជំនួសអោយការទិញ និងកាន់កាប់មូលបត្រ វិនិយោគិនធ្វើការទិញនូវសិទ្ធិទិញ-លក់មូលបត្រ តាមរយៈកិច្ចសន្យា ដោយបង់តម្លៃបន្ថែម (Premium) លើតម្លៃមូលបត្រដែលបានកំណត់។ ការជួញដូរឧបករណ៍និស្សន្ទនេះមិនតម្រូវអោយបង់ប្រាក់ភ្លាមៗទេ មានន័យថា អាចទូទាត់នៅពេលទិញ ឬលក់មូលបត្រនាពេលអនាគតបានដោយធ្វើការទូទាត់ពីមូលធនដែលបានពីការទិញ ឬលក់មូលបត្រ។

ឧបករណ៍និស្សន្ទមាន៖

- Option: សិទ្ធិទិញ (Call Option), សិទ្ធិលក់ (Put Option)
- Future
- Swap/Exchange
- Forward

# ជំពូកទី២

# ទិដ្ឋភាពទូទៅរបស់ផ្សារមូលបត្រកម្ពុជា

## ២.១. គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.)

### ២.១.១. ប្រវត្តិនៃការបង្កើតគណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**) ដែលជានិយ័តករមូលបត្រ ត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ។ **គ.ម.ក.** ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមកិត្តិបរិក្ស-បណ្ឌិត **គាត ឈន់** អតីតរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រធាន **គ.ម.ក.** លុះដល់ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី អូន ព័ន្ធមុន្នីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានតែងតាំងជាប្រធាន **គ.ម.ក.** រហូតដល់បច្ចុប្បន្ន។



រូបភាពទី១៖ ឯកឧត្តមកិត្តិបរិក្សបណ្ឌិត គាត ឈន់ ក្នុងពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការនៃ គ.ម.ក. ក្នុងឆ្នាំ២០០៩

### ២.១.២. និយមន័យរបស់គណៈកម្មការមូលបត្រកម្ពុជា

**គ.ម.ក. គឺជាអ្វី?** **គ.ម.ក.** គឺជាអាជ្ញាធរគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍន៍វិស័យមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមាន **ឯកឧត្តម ស៊ូ សុជាតិ** ជាអគ្គនាយក។ ក្នុងនាមជានិយ័តករមូលបត្រ **គ.ម.ក.** បានដើរតួយ៉ាងសំខាន់ក្នុងការជំរុញ និងការអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជា តាមរយៈការបង្កើតច្បាប់ និងបទប្បញ្ញត្តិ ក៏ដូចជាគោលនយោបាយ និងគោលការណ៍ណែនាំនានា និងការធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងមូលបត្រ ក្នុងគោលបំណងគ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រ ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងកិច្ចគាំពារវិនិយោគិនសាធារណៈផងដែរ។




រូបភាពទី២៖ ឯកឧត្តម ស៊ូ សុជាតិ អគ្គនាយក នៃគណៈកម្មការមូលបត្រកម្ពុជា

## ២.១.៣. ចក្ខុវិស័យ និងបេសកកម្ម

### ក. ចក្ខុវិស័យ

គ.ម.ក. មានគោលដៅគ្រប់គ្រងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងចូលរួមចំណែក ដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គម តាមរយៈការកៀរគរមូលធនពី សាធារណជន ឬអ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅ កម្ពុជា[10]។

### ខ. បេសកកម្ម

- បង្កើត និងរក្សាឲ្យមានទំនុកចិត្តពីអ្នកវិនិយោគ នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការការពារសិទ្ធិស្របច្បាប់របស់វិនិយោគិន និងធានាឲ្យមានការបោះផ្សាយ និងការជួញដូរមូលបត្រប្រកបដោយសណ្ដាប់ធ្នាប់ និងត្រឹមត្រូវ។
- លើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រឲ្យមានប្រសិទ្ធភាព និងជំរុញការអភិវឌ្ឍទីផ្សារនេះឲ្យមានសណ្ដាប់ធ្នាប់ និងរបៀបរៀបរយ។
- ជំរុញឲ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ជ័យ តាមរយៈការទិញមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត។
- ជំរុញឲ្យមានការធ្វើវិនិយោគទុនពីបរទេស និងការចូលរួមក្នុងទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

[10] គណៈកម្មការមូលបត្រកម្ពុជា, ចក្ខុវិស័យ និង បេសកកម្ម

### ២.១.៤. តួនាទីរបស់គណៈកម្មការមូលបត្រកម្ពុជា

**គ.ម.ក.** បាននិងកំពុងបង្កើតឡើងនូវផលិតផលហិរញ្ញវត្ថុថ្មីៗជាប្រចាំ (ផលិតផលហិរញ្ញវត្ថុមានស្រាប់នៅលើទីផ្សារបច្ចុប្បន្នមានដូចជា មូលបត្រកម្មសិទ្ធិ មូលបត្របំណុល គម្រោងវិនិយោគរួម និងឧបករណ៍និស្សន្ទជាដើម) ដើម្បីជាជម្រើសក្នុងការវិនិយោគសម្រាប់សាធារណជនទូទៅ និងវិនិយោគិនបរទេស ព្រមទាំងជាជម្រើសសម្រាប់ក្រុមហ៊ុនក្នុងការពិនិត្យ និងពិចារណាលើការបោះផ្សាយនូវផលិតផលហិរញ្ញវត្ថុណាមួយទៅតាមតម្រូវការជាក់ស្តែងរបស់ក្រុមហ៊ុន និងទីផ្សារ។

- **ការផ្តល់, បន្ត និងលុបចោលនូវអាជ្ញាបណ្ណ/ការទទួលស្គាល់/ការអនុញ្ញាត៖**

លើសពីនេះទៀតសោត **គ.ម.ក.** មានតួនាទីផ្តល់, បន្ត និងលុបចោលនូវអាជ្ញាបណ្ណ/ការទទួលស្គាល់/ការអនុញ្ញាត ដល់អ្នកចូលរួមក្នុងទីផ្សារ មានជាអាទិ៍ ប្រតិបត្តិករទីផ្សារមូលបត្រ (CSX) អន្តរការីមូលបត្រ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់ ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ក្រុមហ៊ុនផ្តល់សេវាបកប្រែ និងក្រុមហ៊ុនផ្តល់សេវាសវនកម្មជាដើម។ **គ.ម.ក.** ក៏នៅតែបន្តត្រួតពិនិត្យក្រុមហ៊ុនដែលទទួលបាននូវអាជ្ញាបណ្ណ/ការទទួលស្គាល់/ការអនុញ្ញាតទាំងនោះ ដើម្បីឱ្យប្រាកដថាក្រុមហ៊ុនទាំងអស់នោះ មានអនុលោមភាព និងគោរពទៅតាមលក្ខខណ្ឌតម្រូវនានា បន្ទាប់ពីបានទទួលអាជ្ញាបណ្ណ/ការទទួលស្គាល់/ការអនុញ្ញាត ក្នុងគោលបំណងពង្រឹងការអនុវត្តច្បាប់ និងការការពារវិនិយោគិនទូទៅ។

- **ការផ្តល់ការអនុញ្ញាតដល់ក្រុមហ៊ុនបោះផ្សាយ៖**

**គ.ម.ក.** ក៏មានតួនាទីក្នុងការផ្តល់ការអនុញ្ញាតដល់ក្រុមហ៊ុនទាំងឡាយណាដែលមានបំណងបោះ-ផ្សាយលក់មូលបត្រជាសាធារណៈ ដោយបំពេញទៅតាមលក្ខខណ្ឌតម្រូវដូចដែលបានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមានសម្រាប់ក្រុមហ៊ុន និងសហគ្រាសសាធារណៈ ដែលបច្ចុប្បន្នមានក្រុមហ៊ុនចំនួន ៦ ដែលបានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និងក្រុមហ៊ុនចំនួន ៦ ដែលបានបោះផ្សាយលក់សញ្ញាបណ្ណសាជីវកម្ម និងបានចុះបញ្ជីនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (CSX)។

- **ការលើកកម្ពស់ការយល់ដឹង៖**

តួនាទីសំខាន់មួយទៀតរបស់ គ.ម.ក. គឺការលើកកម្ពស់ការយល់ដឹងដល់អ្នកចូលរួមទីផ្សារតាមរយៈការរៀបចំជាវគ្គបណ្តុះបណ្តាល និងការប្រឡងសម្រាប់បុគ្គលត្រូវទទួលគុណវុឌ្ឍិ ដែលបម្រើការងារនៅក្នុងវិស័យមូលបត្រដែលកន្លងមក គ.ម.ក. បានផ្តល់វគ្គបណ្តុះបណ្តាលចំនួន ១៧ លើក និងមានអ្នកចូលរួមសរុបជាង ១,២០០ រូប។ បន្ថែមលើសពីនេះទៀត គ.ម.ក. ក៏មានតួនាទីក្នុងការផ្សព្វផ្សាយ និងជំរុញការយល់ដឹងពាក់ព័ន្ធ

នឹងមូលបត្រដល់សាធារណជនទូទៅ សិស្ស និស្សិត អ្នកសារព័ត៌មាន និងក្រុមហ៊ុន/សហគ្រាសសក្តានុពល តាមរយៈការរៀបចំជាសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានាផងដែរ។

- **ការផ្សះផ្សាវិវាទ និងដោះស្រាយវិវាទ៖**

តួនាទីមួយទៀតដែលវិនិយោគិនសាធារណជន ក៏ដូចជាអ្នកចូលរួមក្នុងទីផ្សារ មិនសូវចាប់អារម្មណ៍ គឺ គ.ម.ក. ជាអ្នកធ្វើការផ្សះផ្សាវិវាទ (Mediation) និងដោះស្រាយវិវាទ (Adjudication) ដល់ភាគីជម្លោះពាក់ព័ន្ធនឹងវិស័យមូលបត្រផងដែរ។ ភាគីជម្លោះ អាចស្នើដល់ គ.ម.ក. ដើម្បីធ្វើជាអ្នកផ្សះផ្សាវិវាទ និងដោះស្រាយវិវាទ ដែលនីតិវិធីនៃការផ្សះផ្សា និងដោះស្រាយវិវាទ មានភាពងាយស្រួល ចំណាយពេលខ្លី មានភាពសាមញ្ញ មានភាពបត់បែន ចំណាយតិច ការរក្សាការសម្ងាត់ និងអ្នកផ្សះផ្សា និងអ្នកដោះស្រាយវិវាទមានជំនាញ និងក្រមសីលធម៌ខ្ពស់ក្នុងការបំពេញមុខងារ។

### ២.១.៥. ប្រធាន និងសមាជិករបស់ គ.ម.ក.

គណៈកម្មការមូលបត្រកម្ពុជា មានប្រធាន ១រូប និងសមាជិកចំនួន ៨រូប។ ប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ គ.ម.ក. មានសមាជិក៨រូបដូចខាងក្រោម៖

១. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១រូប

២. តំណាងធនាគារជាតិកម្ពុជា ០១រូប

៣. តំណាងក្រសួងពាណិជ្ជកម្ម ០១រូប

៤. តំណាងក្រសួងយុត្តិធម៌ ០១រូប

៥. តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ០១រូប

៦. អគ្គនាយកនៃ គ.ម.ក ០១រូប

៧. អ្នកជំនាញដែលមានបទពិសោធន៍វិស័យមូលបត្រ ០២រូប

សមាជិក គ.ម.ក. ក្នុងមួយអាណត្តិមានរយៈពេល ៥ ឆ្នាំ និងអាចបន្ត ឬបញ្ចប់អាណត្តិទៅតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។



រូបភាពទី៣៖ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន គ.ម.ក.

## ២.១.៦. រចនាសម្ព័ន្ធអង្គភាពចាត់តាំងគណៈកម្មការមូលបត្រកម្ពុជា

គ.ម.ក. ដឹកនាំដោយអគ្គនាយកមួយរូប ដែលមានឋានៈ និងបុព្វសិទ្ធិស្មើនឹងរដ្ឋលេខាធិការ និងមានអគ្គនាយករងមួយចំនួនជាជំនួយការ។

គ.ម.ក.មាននាយកដ្ឋានចំណុះចំនួន០៦ មានដូចខាងក្រោម៖

១. នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

២.នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ

៣. នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ

៤.នាយកដ្ឋានកិច្ចការគតិយុត្ត គ.ម.ក.មានអង្គភាពសវនកម្មផ្ទៃក្នុង ដែលស្ថិតនៅក្រោមការដឹកនាំ និងគ្រប់គ្រងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ គ.ម.ក

៥.នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ

៦.នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ។




## ២.១.៧. រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញារបស់គណៈកម្មការមូលបត្រកម្ពុជា

### ក. រូបសញ្ញា

- រូបបាហង្សពណ៌មាស
- រូបភាពស្លឹកឈើផ្នែកខាងឆ្វេងមានរំលេចស្រមោលពណ៌មាស ហើយខាងស្តាំរំលេចស្រមោលពណ៌ប្រផេះ
- រូបរង្វង់ថាសដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ
- ព័ទ្ធជុំវិញជារង្វង់នៅផ្នែកខាងលើដោយអក្សរខ្មែរថា "**គណៈកម្មការមូលបត្រកម្ពុជា**" និងព័ទ្ធរង្វង់នៅផ្នែកខាងក្រោមដោយអក្សរអង់គ្លេសថា **"SECURITIES AND EXCHANGE COMMISSION OF CAMBODIA"** ។

រូបភាពទី៤៖ រូបសញ្ញារបស់គណៈកម្មការមូលបត្រកម្ពុជា

**ខ. អត្ថន័យនៃរូបសញ្ញា**

- រូបហង្សមានពណ៌មាស តំណាងឱ្យអាជ្ញាធរហិរញ្ញវត្ថុ ដែលជាអ្នកត្រួតពិនិត្យ និងគ្រប់គ្រងប្រតិបត្តិការមូលបត្រ និងធានាឱ្យដំណើរការទីផ្សារមូលបត្រប្រកបដោយប្រសិទ្ធភាព សណ្តាប់ធ្នាប់ និងតម្លាភាព
- រូបរង្វង់ថាសដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ ដែលតំណាងឱ្យភាពចំណេញខាត ឬភាពឡើងចុះនៃដំណើរការទីផ្សារ
- រូបហង្សពណ៌មាសឈរលើរង្វង់ថាសដែលមានជើងម្ខាងជាន់លើផ្ទៃពណ៌មាស និងជើងម្ខាងទៀតជាន់លើផ្ទៃពណ៌ប្រផេះ ចង់បង្ហាញថាភាពចំណេញខាត ឬភាពឡើងចុះនៃកិច្ចដំណើរការទីផ្សារស្ថិតនៅក្រោមការត្រួតពិនិត្យ និងគ្រប់គ្រងរបស់អាជ្ញាធរជាគណៈកម្មការមូលបត្រកម្ពុជាប្រកបដោយប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និង តម្លាភាព
- រូបស្លឹកឈើ តំណាងឱ្យលទ្ធផលជាផ្លែផ្កានៃការចូលរួមចំណែករបស់វិស័យមូលបត្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

**គ. មូលហេតុនៃជម្រើសយករូបហង្សពណ៌មាសជានិមិត្តសញ្ញា**

- រូបហង្សពណ៌មាសជាប់ពាក់ព័ន្ធទៅនឹងដំណើរការវិវឌ្ឍនៃរូបិយវត្ថុរបស់ខ្មែរ ដោយរូបនេះត្រូវបានប្រើប្រាស់ជាលើកដំបូងនៅលើ **ប្រាក់ប្រាសាទ** ក្នុងរជ្ជកាលព្រះបាទអង្គឌួង ដើម្បីរំលឹកដល់លោក **សំអាង ហង្ស** ដែលព្រះបាទអង្គឌួងបញ្ជូនឱ្យទៅសិក្សាវិជ្ជាបោះផ្សាយប្រាក់នៅបរទេស ហើយលោកបានរួមចំណែកយ៉ាងខ្លាំងក្នុងការធ្វើឱ្យរូបិយវត្ថុខ្មែរមានអត្តសញ្ញាណច្បាស់លាស់និងដាក់ឱ្យចរាចរក្នុងសេដ្ឋកិច្ច។

- រូបហង្សពណ៌មាសនេះ ជារូបសញ្ញាតំណាងឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នាសម័យ-សង្គមរាស្ត្រនិយម សម័យសាធារណរដ្ឋ និងក្នុងសម័យព្រះរាជាណាចក្រកម្ពុជាទី២ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលការណ៍នេះត្រូវនឹងគណៈកម្មការមូលបត្រកម្ពុជា ដែលជាអាជ្ញាធរហិរញ្ញវត្ថុមួយ ហើយមានប្រធានជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺ ឯកឧត្តមឧបនាយក-រដ្ឋមន្ត្រី គាត ឈន់។

### ២.១.៨. ព័ត៌មានទំនាក់ទំនងរបស់គណៈកម្មការមូលបត្រកម្ពុជា

- អាសយដ្ឋានៈ អគារ១៦៨F ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ ភ្នំពេញ រាជធានីភ្នំពេញ
- ទូរស័ព្ទលេខៈ (៨៥៥) ២៣ ៨៨៥ ៦១១ / (៨៥៥) ១៦ ៨១៩ ៩៩១ (វិចិត្រ-admin) / (៨៥៥) ០១៧៧៦ ៧៨៥ (តី-webmaster)
- ទូរសារៈ (៨៥៥) ២៣ ៨៨៥ ៦២២
- អ៊ីម៉ែលៈ INFO@SECC.GOV.KH

## ២.២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.)

### ២.២.១. ប្រវត្តិនៃការបង្កើតក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រទេសកម្ពុជាដោយឈរលើគោលដៅក្នុងការជំរុញកំណើនសេដ្ឋកិច្ចតាមរយៈលំហូរមូលធន ការវិនិយោគ និងការវិភាជន៍ជាថ្មីនូវមូលធនតាមយន្តការទីផ្សារមូលធន នៅខែវិច្ឆិកា ឆ្នាំ២០០៦ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និង ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានចុះហត្ថលេខាលើ អនុស្សរណៈយោគយល់ ស្តីអំពី "ការអភិវឌ្ឍផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា"។ ដោយផ្អែកលើអនុស្សរណៈយោគយល់នេះ សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជា-ណាចក្រកម្ពុជា បានប្រកាសបើកអោយដំណើរការគម្រោងបង្កើតទីផ្សារមូលបត្រនៅប្រទេសកម្ពុជា នៅខែកញ្ញា ឆ្នាំ២០០៧។ នៅឆ្នាំ២០០៨ អនុស្សរណៈយោគយល់មួយទៀតស្តីអំពី "ការបង្កើតផ្សារមូលបត្រនៅព្រះរាជា-ណាចក្រកម្ពុជា" ត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និង ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។

នៅខែមីនា ឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ បានចុះកិច្ចព្រមព្រៀង ក្រុមហ៊ុនចំរុះ (Joint Venture) ដើម្បីបង្កើតផ្សារមូលបត្រ "ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា" ស្របតាមច្បាប់ស្តីអំពីសហគ្រាសសាធារណៈ។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

បានចុះក្នុងបញ្ជីពាណិជ្ជកម្មនៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១០។ ស្របតាមកិច្ចព្រមព្រៀង ក្រុមហ៊ុនចំរុះ (Joint Venture) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កាន់កាប់ភាគហ៊ុនចំនួន ៥៥% នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ហើយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េកាន់កាប់ភាគហ៊ុនចំនួន ៤៥% នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានទទួលអាជ្ញាបណ្ណជា ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិកររក្សាទុកមូលបត្រ ពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ស្របតាមច្បាប់ស្តីអំពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន[11]។

ការសង្ខេបខ្លីៗអំពីប្រវត្តិ ផ.ម.ក. មានដូចខាងក្រោម៖

- **នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២** ពិធីប្រកាសបើកការជួញដូរមូលបត្រ នៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- **នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១** ការទទួលបានការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ ពី គ.ម.ក
- **នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១** ចុះបញ្ជីពាណិជ្ជកម្ម
- **នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៩** កិច្ចព្រមព្រៀង **"ក្រុមហ៊ុនចំរុះ"** រវាងរាជរដ្ឋាភិបាលកម្ពុជាតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ
- **នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០០៨** អនុស្សរណៈយោគយល់អំពីការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា
- **នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៧** ការដាក់អោយដំណើរការគម្រោងបង្កើតផ្សារមូលបត្រនៅកម្ពុជា
- **នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៦** អនុស្សរណៈយោគយល់អំពី ការអភិវឌ្ឍផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា។

### ២.២.២. នាមករណ៍ និងផ្លាកសញ្ញារបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

#### ក. នាមករណ៍

នាមករណ៍របស់ក្រុមហ៊ុនមាននាមជាភាសាខ្មែរថា **ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា** ដែលហៅកាត់ថា **(ផ.ម.ក.)** និងជាភាសាអង់គ្លេសថា **Cambodia Securities Exchange** ដែលហៅកាត់ថា (CSX)។

[11] www.csx.com.kh អំពីផ.ម.ក., ទិដ្ឋភាពទូទៅរបស់ ផ.ម.ក., ប្រវត្តិ ផ.ម.ក.

**ខ. ផ្លាកសញ្ញា**

រូបភាពទី៥៖ ផ្លាកសញ្ញារបស់ផ្សារមូលបត្រ

ផ្លាកសញ្ញារបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាមានអត្ថសញ្ញាណដូចខាងក្រោម៖ ផ្នែកខាងលើ មានសរសេរអក្សរពណ៌ខៀវថា ផ្សារមូលបត្រកម្ពុជា ដែលជាឈ្មោះតំណាងរបស់ក្រុមហ៊ុន។ រីឯនៅផ្នែកខាងស្តាំមានរូបហង្សពណ៌មាសមួយ ដែលឈរបែរមុខទៅខាងស្តាំ។ ចំណែកនៅពីក្រោមអក្សរផ្នែកខាងឆ្វេង មានឈ្មោះរបស់ក្រុមហ៊ុនផ្សារមូលបត្រជាអក្សរកាត់ភាសាអង់គ្លេសដែលមានពណ៌ខៀវដូចនឹងឈ្មោះខាងលើដែរ។

### ២.២.៣. ចក្ខុវិស័យ និងបេសកកម្មរបស់ផ្សារមូលបត្រកម្ពុជា

**ក. ចក្ខុវិស័យ**

ដើម្បីធ្វើអោយក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា មានដំណើរការល្អ និងការរីកចម្រើន នៅលើមាគ៌ាមួយដ៏ត្រឹមត្រូវ ក្រុមហ៊ុនបានកំណត់គោលការណ៍យ៉ាងច្បាស់លាស់ ទៅលើចក្ខុវិស័យរបស់ខ្លួនគឺ ដើម្បីកសាងនូវ "មហាវិថី" ហិរញ្ញវត្ថុសម្រាប់កម្ពុជា ក្នុងគោលបំណងផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការជួញដូរមូលបត្រ។

**ខ. បេសកកម្ម**

ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើ ក្រុមហ៊ុនផ្សារមូលបត្របានដាក់ចេញនូវបេសកម្មមួយចំនួនដូចជា៖

- ជួយសម្រួលក្នុងការកៀរគរមូលធនរបស់ក្រុមហ៊ុននៅកម្ពុជា
- បង្កើតនូវបរិយាកាសជួញដូរមូលបត្រដែលអំណោយផលដល់អ្នកវិនិយោគិនទាំងក្នុងនិងក្រៅប្រទេស
- បង្កើននូវផលិតផលនិងសេវាកម្មដ៏ទំនើបជាច្រើនប្រភេទសម្រាប់អ្នកចូលរួមទីផ្សារទាំងអស់
- ជួយដាក់ឱ្យដំណើរការនូវសហគ្រាសសាធារណៈមួយដែលមានស្វ័យចិរភាពក្រោមមគ្គុទេសដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

### ២.២.៤. ព័ត៌មានទំនាក់ទំនងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

- អាសយដ្ឋាន : អគារ ផ.ម.ក. វិថីព្រះមហាក្សត្រីយានី កុសុមៈ (ផ្លូវ១០៦) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
- ទូរស័ព្ទ : (៨៥៥) ២៣ ៩៥៨ ៨៨៨
- ទូរសារ : (៨៥៥) ២៣ ៩៥៥ ៥៥៥
- ក្រសួង និងស្ថាប័នពាក់ព័ន្ធ : info@csx.com.kh
- គេហទំព័រ : www.csx.com.kh

### ២.២.៥. រចនាសម្ព័ន្ធគ្រប់គ្រងរបស់ផ្សារមូលបត្រកម្ពុជា



# ជំពូកទី៣

# ដំណើរការវិនិយោគមូលបត្រនៅកម្ពុជា

## ៣.១.និយមន័យ ការវិនិយោគលើមូលបត្រ

ដើម្បីងាយស្រួលស្វែងយល់ និងបកស្រាយនិយមន័យ ការវិនិយោគលើមូលបត្រនេះ យើងខ្ញុំសូមធ្វើការបកស្រាយនិយមន័យនៃពាក្យនីមួយៗជាមុនសិន៖

- ការវិនិយោគ ៖ គឺជាសកម្មភាពនៃការប្រើប្រាស់មូលធន មានជាទ្រព្យ ឬសាច់ប្រាក់ ដើម្បីទទួលបានផលចំណេញនាពេលអនាគត។

ចំណែកការកំណត់និយមន័យមូលបត្រ អាចមានភាពខុសគ្នាខ្លះ ទៅតាមស្ថានភាពទីផ្សារ ច្បាប់ និងបទបញ្ញត្តិរបស់ប្រទេសនីមួយៗ ប៉ុន្តែនិយមន័យមូលបត្រ អាចកំណត់ជាទូទៅបាន។

- មូលបត្រ ៖ សម្រាប់ន័យវិនិយោគ មូលបត្រត្រូវបានអោយនិយមន័យជារួម គឺសំដៅលើឧបករណ៍ ឬបណ្ណកិច្ចសន្យាហិរញ្ញវត្ថុទាំងឡាយណាដែលមានតម្លៃរូបិយវត្ថុ (Monetary Value) និងអាចជួញដូរបានដូចជា បណ្ណភាគហ៊ុន(Stocks/Shares) សញ្ញាបណ្ណ(Bonds) មូលនិធិសង្គហៈ(Mutual Funds) និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ដោយការជួញដូរនេះដែរ ធ្វើឡើងរវាងភាគីពីរ ឬច្រើន[12]។

ជាសរុប **ការវិនិយោគលើមូលបត្រ** គឺជាសកម្មភាពនៃការប្រើប្រាស់មូលធន មានសាច់ប្រាក់ជាដើម ទៅលើឧបករណ៍ហិរញ្ញវត្ថុ មានដូចជា បណ្ណកម្មសិទ្ធិ សញ្ញាបណ្ណ និង ឧបករណ៍ហិរញ្ញវត្ថុដទៃទៀត ដែលមានតម្លៃជារូបិយវត្ថុ (អាចដូរ/បម្លែងជាសាច់ប្រាក់បាន) ក្នុងការជួញដូរដើម្បីទទួលបានផលចំណេញនាពេលអនាគត។

## ៣.២. លក្ខខណ្ឌដើម្បីក្លាយជាវិនិយោគមូលបត្រ

### ៣.២.១. ការស្នើសុំលេខអត្តសញ្ញាណ និងការបើកគណនី

#### ក. ការស្នើសុំលេខអត្តសញ្ញាណវិនិយោគ

ដើម្បីជួញដូរមូលបត្របាន វិនិយោគិនត្រូវមានលេខអត្តសញ្ញាណវិនិយោគិន (Investors Identification) ដោយត្រូវស្នើសុំទៅកាន់ គ.ម.ក. មុននឹងធ្វើសកម្មភាពជួញដូរ។ វិនិយោគិនអាចស្នើសុំដោយផ្ទាល់ពី គ.ម.ក. ឬតាមរយៈក្រុមហ៊ុនមូលបត្រទាំង ១០ ដែលបានទទួលអាជ្ញាបណ្ណពី គ.ម.ក.។ ទម្រង់ពាក្យស្នើសុំលេខអត្តសញ្ញាណនេះ ត្រូវយោងតាមប្រភេទវិនិយោគិន ជានីតិបុគ្គល ឬ រូបវន្តបុគ្គល និងអាចទាញយកពីគេហទំព័ររបស់ គ.ម.ក. ឬតំណរភ្ជាប់ http:www.secc.gov.kh/khmer/m45.php?pn=5 ។

[12] https://www.northwesternmutual.com/life-and-money/investing-101-what-is-a-security/, 2018

***<u>សូមបញ្ជាក់ថា</u>*** *វិនិយោគិនម្នាក់អាចទទួលបានលេខអត្តសញ្ញាណតែមួយគត់។*

**ខ. ការបើកគណនី**

បន្ទាប់ពីទទួលបានលេខអត្តសញ្ញាណពី គ.ម.ក.រួច វិនិយោគិនត្រូវមានគណនី២ គឺ គណនីផ្ទាល់ខ្លួន ឬគណនីសាច់ប្រាក់នៅក្រុមហ៊ុនមូលបត្ររបស់ខ្លួន និងគណនីមួយទៀតដែលវិនិយោគិនត្រូវបង្កើត គឺគណនីជួញដូរនៅផ្សារមូលបត្រ ។

– គណនីសាច់ប្រាក់៖ ត្រូវដាក់តម្កល់សាច់ប្រាក់យ៉ាងហោចណាស់ ១០០% នៃថ្លៃមូលបត្រដែលចង់ទិញ បូករួមនឹងថ្លៃសេវានានា។ ក្រុមហ៊ុនមូលបត្រត្រូវយកសាច់ប្រាក់ដែលវិនិយោគិនបានតម្កល់នេះ ដាក់ចូលក្នុងគណនីសាច់ប្រាក់អតិថិជន (Client money account) នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA)។

– គណនីមូលបត្រ៖ សម្រាប់រក្សាទុកមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ។ មូលបត្ររបស់វិនិយោគិនត្រូវបានរក្សាទុកនៅប្រតិបត្តិកររក្សាទុកមូលបត្រដាច់ដោយឡែកពីទ្រព្យក្រុមហ៊ុនមូលបត្រ។

វិនិយោគិនអាចបើកគណនីជួញដូរមូលបត្រមួយ នៅក្រុមហ៊ុនមូលបត្រមួយ មានន័យថាវិនិយោគិនអាចបើកគណនីជួញដូរលើសពីមួយ នៅក្រុមហ៊ុនមូលបត្រផ្សេងគ្នា។ ឧទាហរណ៍៖ បច្ចុប្បន្នក្រុមហ៊ុនមូលបត្រដែលបានចុះបញ្ជីមានចំនួន១៣ ដូចនេះវិនិយោគិនអាចបើកគណនីជួញដូរជាអតិបរមាចំនួន១៣។

- ➢ នីតិវិធីក្នុងការបើកគណនីជួញដូរនៅទីផ្សារមូលបត្រមាន៖
- • ជ្រើសរើសក្រុមហ៊ុនមូលបត្រ

វិនិយោគិនត្រូវជ្រើសរើសក្រុមហ៊ុនមូលបត្រមួយក្នុងចំណោមក្រុមហ៊ុនទាំង១០ដែលជាសមាជិករបស់ ផ.ម.ក. ហើយក្រុមហ៊ុនមូលបត្រនោះនឹងជួយវិនិយោគិនក្នុងការបើកគណនីជួញដូរ[13]។

- • បើកគណនីជួញដូរនៅក្រុមហ៊ុនមូលបត្រដែលបានជ្រើសរើស
- ➢ ឯកសារតម្រូវដើម្បីបើកគណនីជួញដូររួមមាន៖

១. អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន(សម្រាប់ជនបរទេស) ភ្ជាប់ជាមួយរូបថត៤×៦មួយសន្លឹក

២. លេខអត្តសញ្ញាណវិនិយោគិន (ក្រុមហ៊ុនមូលបត្រអាចជួយធ្វើការស្នើសុំពី គ.ម.ក.)

\+ តើវិនិយោគិនអាចជួញដូរបាននៅពេលណា?

យ៉ាងហោចណាស់មួយថ្ងៃបន្ទាប់ពីបើកគណនីជួញដូររួច ទើបវិនិយោគិនអាចដាក់បញ្ជាទៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក.បាន។

[13] www.csx.com.kh, ប្រតិបត្តិការរបស់ផមក, ទិដ្ឋភាពទូទៅនៃការជួញដូរ, នីតិវិធីក្នុងការបើកកណនី, 2020

## ៣.៣. ដំណើរការនៃការជួញដូរមូលបត្រ

### ៣.៣.១. ការជួញដូរមូលបត្រនៅផ្សារដំបូង និងផ្សារបន្ទាប់

#### ក. ការជួញដូរមូលបត្រនៅផ្សារដំបូង

ក្នុងទីផ្សារដំបូង(Primary market) វិនិយោគិនធ្វើការទិញមូលបត្រដោយផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយតាមរយៈក្រុមហ៊ុនមូលបត្រជាអ្នកជួយសម្របសម្រួលដល់វិនិយោគិនក្នុងការទិញមូលបត្រ ហើយប្រតិបត្តិការមិនធ្វើឡើងនៅផ្សារមូលបត្រ(ផ.ម.ក.)ទេ។ មានពីរដំណាក់កាលសម្រាប់វិនិយោគិនចូលរួមទិញភាគហ៊ុននៅ IPO (ទីផ្សារដំបូង) គឺ ដំណាក់កាលប៊ុកបៀលឌីង (Book-Building) និង បរិវិសកម្ម (Subscription)។ ដំណាក់កាលប៊ុកបៀលឌីង គឺវិនិយោគិនត្រូវបានអនុញ្ញាតឲ្យចូលរួមដេញថ្លៃមូលបត្រក្នុងចន្លោះថ្លៃ (Price Range) ដែលត្រូវបានកំណត់ដោយក្រុមហ៊ុនធានាទិញមូលបត្រ។ វិនិយោគិននឹងត្រូវស្នើឱ្យជ្រើសរើសយកថ្លៃមួយនៅចន្លោះថ្លៃដែលបានកំណត់ទុកជាមុន រួមជាមួយនឹងបរិមាណនៃភាគហ៊ុនដែលវិនិយោគិនចង់ស្នើទិញ។ នៅក្នុងដំណាក់កាលនេះ វិនិយោគិននឹងតម្រូវឱ្យដាក់តម្កល់សាច់ប្រាក់ចំនួន១០% នៃតម្លៃសរុបដែលបានដាក់ស្នើ ( ថ្លៃ x បរិមាណ)។ ប៉ុន្មានថ្ងៃក្រោយការធ្វើប៊ុកបៀលឌីង នឹងមានការផ្សព្វផ្សាយពីថ្លៃភាគហ៊ុនដែលបានកំណត់តាមរូបមន្តមធ្យមទម្ងន់(Weighted-average) ដោយផ្អែកលើព័ត៌មានថ្លៃ និងបរិមាណទាំងអស់ដែលប្រមូលបាន ឬអាចនិយាយក្នុងន័យមួយទៀតថា បន្ទាប់ពីទទួលបានសំណើរដេញថ្លៃពីអ្នកចូលរួមទាំងអស់ ក្រុមហ៊ុនធានាទិញមូលបត្រនឹងកំណត់យកថ្លៃចុងក្រោយមួយ ហៅថាថ្លៃ IPO។ ពេលនោះអ្នកដែលចូលរួមដំណើរការប៊ុកបៀលឌីង អាចស្នើទិញមូលបត្រនោះនៅថ្លៃIPOបាន ដំណាក់កាលនេះហៅថា ការធ្វើបរិវិសកម្ម។ បន្ទាប់ពីបែងចែកទៅឲ្យអ្នកដែលចូលរួមដំណើរការប៊ុកបៀលឌីងរួចរាល់ហើយ នៅមានមូលបត្រនៅសល់ សាធារណជនអាចស្នើទិញមូលបត្រនោះនៅថ្លៃ IPO ដែរទោះបីជាមិនបានចូលរួមក្នុងដំណើរការធ្វើប៊ុកបៀលឌីងក៏ដោយ។

ក្នុងការទិញភាគហ៊ុននៅ IPO លោកអ្នកអាចរំលងដំណាក់កាលប៊ុកបៀលឌីងបាន ប៉ុន្តែត្រូវចុះឈ្មោះទិញភាគហ៊ុនក្នុងដំណើរការបរិវិសកម្ម នៅថ្ងៃដែលបានកំណត់រួចនៅប៊ុកបៀលឌីង។ ប៉ុន្តែវិនិយោគិនដែលទទួលជោគជ័យក្នុងប៊ុកបៀលឌីង (ជាអ្នកដែលបានដាក់ស្នើថ្លៃខ្ពស់ជាង ឬស្មើនឹងថ្លៃដែលបានប្រកាស) មានអាទិភាពទទួលបានបរិមាណភាគហ៊ុនច្រើនជាង។ នៅពេលដែលភាគហ៊ុននៅ IPO ត្រូវបានបែងចែករួចរាល់ជាផ្លូវការ វិនិយោគិនត្រូវបង់ប្រាក់ពេញ ១០០% តាមចំនួនភាគហ៊ុនដែលបានធ្វើបរិវិសកម្មដោយជោគជ័យ។

សូមកត់ចំណាំថា នៅកម្ពុជាវិនិយោគិនអាចជួញដូរមូលបត្របានទាំងនៅទីផ្សារដំបូង និងទីផ្សារបន្ទាប់ ត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនមូលបត្រ ដើម្បីជួយដល់សម្រួលការជួញដូរ ប្រឹក្សាយោបល់ និង

បំពេញឯកសាររដ្ឋបាលនានា ។

ប៊ុកបៀលឌីង គឺជាដំណើរការស្ទាបស្ទង់ថ្លៃទីផ្សារពីវិនិយោគិន មុននឹងឈានដល់ការកំណត់ថ្លៃលក់មូលបត្រជាសាធារណៈ។

បរិវិសកម្ម គឺជាការសុំចុះឈ្មោះទិញមូលបត្រនៅពេលក្រុមហ៊ុនធ្វើសំណើរលក់ជាសាធារណៈ។

**ខ. ការជួញដូរមូលបត្រនៅផ្សារបន្ទាប់**

ក្នុងទីផ្សារបន្ទាប់(Secondary market) ក្រុមហ៊ុនបោះផ្សាយនឹងយកមូលបត្ររបស់ខ្លួនមកចុះបញ្ជីនៅផ្សារមូលបត្រ (Stock Exchange)។ បន្ទាប់ពីចុះបញ្ជីរួចរាល់ហើយ វិនិយោគិនអាចដាក់ស្នើទិញមូលបត្រនោះបាន ហើយវិនិយោគិនដែលបានទិញមូលបត្រនោះក្នុងទីផ្សារដំបូង អាចដាក់បញ្ជាលក់បានផងដែរ។ ទីផ្សារបន្ទាប់បង្កើតឲ្យមានទីផ្សារសម្រាប់មូលបត្រដែលត្រូវបានទិញក្នុងទីផ្សារដំបូង ដោយមានការជួញដូររវាងវិនិយោគិន និងវិនិយោគិន ហើយក្រុមហ៊ុនបោះផ្សាយមិនទទួលបានផលចំណេញហិរញ្ញវត្ថុពីការជួញដូរនៅផ្សារបន្ទាប់ឡើយ គឺត្រូវបានទៅលើវិនិយោគិនដែលកាន់កាប់មូលបត្រ។ ការជួញដូរនៅផ្សារបន្ទាប់ប្រព្រឹត្តទៅនៅក្នុង ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) ដែលជាប្រតិបត្តិករទីផ្សារមូលបត្រតែមួយគត់ដែលទទួលបានការអនុញ្ញាតពី គ.ម.ក. ដើម្បីផ្តល់ទីកន្លែង សេវា និងប្រព័ន្ធជួញដូរសម្រាប់វិនិយោគិន។

អាចនិយាយឲ្យខ្លីបានថា ទីផ្សារដំបូងជាការទិញមូលបត្រពីក្រុមហ៊ុនបោះផ្សាយដោយផ្ទាល់ និងមិនប្រព្រឹត្តទៅក្នុងផ្សារមូលបត្រកម្ពុជាទេ។

ទីផ្សារបន្ទាប់ ជាការទិញ/លក់មូលបត្ររវាងវិនិយោគិន និងវិនិយោគិនបន្ទាប់ពីបានទិញមូលបត្រ IPO ហើយប្រតិបត្តិការប្រព្រឹត្តទៅក្នុងផ្សារមូលបត្រ (Stock Exchange)។

**៣.៣.២. នីតិវិធីនៃការជួញដូរ**

នីតិវិធីនៃការជួញដូរមូលបត្រ ជាគោលការណ៍មាន ៩ ដំណាក់កាលដូចខាងក្រោម៖

១. វិនិយោគិនបើកគណនីជួញដូរ (គណនីមូលបត្រ និងគណនីសាច់ប្រាក់) នៅក្រុមហ៊ុនមូលបត្រនៅថ្ងៃ T-1។ ក្រុមហ៊ុនមូលបត្រ នឹងធ្វើការស្នើសុំលេខអត្តសញ្ញាណវិនិយោគិនជូនអតិថិជនរបស់ខ្លួនពីគណៈកម្មការមូលបត្រកម្ពុជា។

២. វិនិយោគិនដាក់បញ្ជាទិញ ឬលក់នៅថ្ងៃ T+0 តាមប្រព័ន្ធជួញដូរចល័ត **Mobile Trading System (MTS)** ឬក្រុមហ៊ុនមូលបត្រជាលាយលក្ខណ៍អក្សរ ជាពាក្យសម្តី (ត្រូវបានថតទុកដោយអ្នកតំណាងនៅក្នុងទីផ្សារ) ឬមធ្យោបាយអេឡិចត្រូនិចនានា។

៣. បន្ទាប់ពីដាក់បញ្ជាមកក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. នៅថ្ងៃ T+0 បានជោគជ័យដោយមានមូលបត្រ និងសាច់ប្រាក់គ្រប់គ្រាន់ នៅក្នុងគណនីរបស់វិនិយោគិន (សាច់ប្រាក់ ឬបរិមាណមូលបត្រមួយរយភាគរយដែលពាក់ព័ន្ធនឹងបញ្ជានោះ) សាច់ប្រាក់ ឬមូលបត្រនឹងត្រូវបានបង្កកទុកសម្រាប់ទូទាត់នៅថ្ងៃ T+2។

៤. ការបញ្ជាទាំងឡាយត្រូវបានផ្គូរផ្គងនៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. ទៅតាមគោលការណ៍ដេញថ្លៃដែលបានកំណត់ទុកជាមុន។

៥. ផ.ម.ក. ជូនដំណឹងអំពីលទ្ធផលនៃការជួញដូរនៅថ្ងៃ T+0។

៦. ក្រុមហ៊ុនមូលបត្របញ្ជាក់លទ្ធផលនៃការជួញដូរដែលពាក់ព័ន្ធជាមួយអតិថិជននីមួយៗរបស់ខ្លួននៅថ្ងៃ T+0។

៧. ក្នុងករណីមានកំហុសឆ្គងដែលបង្កឡើងដោយក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនមូលបត្រនោះត្រូវដាក់ពាក្យស្នើសុំមកកាន់ផ.ម.ក. ដើម្បីកែតម្រូវឲ្យបានមុនថ្ងៃត្រង់នៃថ្ងៃ T+1។ បន្ទាប់ពីកំហុសឆ្គងត្រូវបានកែតម្រូវហើយ ដំណើរការក្នុងចំណុចទី៥ និងទី៦ នឹងត្រូវអនុវត្តម្តងទៀត។

៨. វិនិយោគិនបង់ប្រាក់ ឬបញ្ជូនមូលបត្រតាមរយៈក្រុមហ៊ុនមូលបត្រនៅថ្ងៃ T+2។

៩. ក្រុមហ៊ុនមូលបត្រទូទាត់ការជួញដូរក្នុងនាមជាវិនិយោគិននៅ ផ.ម.ក.។

- **Mobile Trading System (MTS)** ជាការអភិវឌ្ឍប្រព័ន្ធជួញដូរបែបថ្មី ឬជាប្រព័ន្ធជួញដូរតាមបែបអេឡិចត្រូនិច ដែលបានបង្កើត និងគ្រប់គ្រងដោយផ្សារមូលបត្រកម្ពុជា ដើម្បីជួយអោយវិនិយោគិនធ្វើការជួញដូរបានកាន់តែមានប្រសិទ្ធិភាព សុវត្ថិភាព និងទំនុកចិត្ត។




រូបភាពទី៦៖ គំនូសតាងដំណើរការជួញដូរមូលបត្រនៅផ្សារមូលបត្រកម្ពុជា

វិនិយោគិនអាចដាក់បញ្ជាបានលុះត្រាតែមានសាច់ប្រាក់យ៉ាងហោចមួយរយភាគរយ (សម្រាប់បញ្ជាទិញ) ដែលរួមបញ្ចូលទាំងថ្លៃសេវាឈ្មួញជើងសារមូលបត្រ ឬបរិមាណមូលបត្រយ៉ាងហោចមួយរយភាគរយ (សម្រាប់បញ្ជាលក់)។ ពេលបញ្ជាត្រូវបានបញ្ជូនចេញ សាច់ប្រាក់និងមូលបត្រទាំងនេះនឹងត្រូវបានបង្កកទុកដោយសមាជិក ក្នុងគោលបំណងដើម្បីទូទាត់ឬបង្កកទុករហូតដល់ពេលបញ្ជានោះអស់សុពលភាព[14]។

នៅពេលបើកគណនីជួញដូររួចរាល់ជាមួយក្រុមហ៊ុនមូលបត្រណាមួយ (List of CSX's Members) អ្នកអាចបង្គាប់ឈ្មួញជើងសានោះឱ្យដាក់បញ្ជាទិញឬលក់ តាមរយៈមធ្យោបាយណាមួយដូចខាងក្រោម៖

- ឯកសារជាលាយលក្ខណ៍អក្សរ
- ទូរសព្ទ
- សារអេឡិចត្រូនិច
- មធ្យោបាយអេឡិចត្រូនិចដទៃទៀត ដែលស្នើដោយឈ្មួញជើងសាមូលបត្រ

ជំនួសឲ្យមធ្យោបាយខាងលើ លោកអ្នកអាចដាក់បញ្ជាទិញឬលក់ដោយខ្លួនឯងតាមរយៈប្រព័ន្ធជួញដូរចល័ត(MTS) បន្ទាប់ពីលោកអ្នកបានស្នើដំណើរការគណនីMTSរបស់លោកអ្នកបានជោគជ័យ។

សូមកត់ចំណាំថាបច្ចុប្បន្ននេះ ប្រព័ន្ធជួញដូរចល័ត (MTS) ត្រូវបានដាក់ឲ្យដំណើរការសម្រាប់តែការ

[14] www.csx.com.kh, ប្រតិបត្តិការរបស់ផមក, ទិដ្ឋភាពទូទៅនៃការជួញដូរ, នីតិវិធីនៃការជួញដូរ

ជួញដូរភាគហ៊ុនតែប៉ុណ្ណោះ។ ចំពោះការជួញដូរមូលបត្របំណុល លោកអ្នកត្រូវដាក់បញ្ជាទិញឬលក់តាមរយៈឈ្មួញជើងសាតាមមធ្យោបាយដែលបានបរិយាយខាងលើ។

### ៣.៣.៣. ពេលវេលានៃការជួញដូរ

ការជួញដូរមូលបត្រចាប់ផ្តើមពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ លើកលែងថ្ងៃឈប់សម្រាកជាសាធារណៈ។ ម៉ោងជួញដូរត្រូវកំណត់តាមវិធីសាស្ត្រជួញដូរដូចខាងក្រោម៖

ម៉ោងជួញដូរចាប់ផ្តើមពីម៉ោង ៨:០០ព្រឹក ដល់ម៉ោង ៣:០០រសៀល ដែលបែងចែកទៅតាមវគ្គដូចខាងក្រោម៖

| វគ្គ | ម៉ោងទទួលបញ្ជា | ម៉ោងជួញដូរ | វិធីសាស្ត្រដេញថ្លៃ |
|---|---|---|---|
| វគ្គបើក | ៨:០០ - ៩:០០ | ៩:០០ | ដេញថ្លៃដោយយកថ្លៃតែមួយ |
| វគ្គនិរន្តរ៍ | ៩:០០ - ២:៥០ | | ដេញថ្លៃដោយយកថ្លៃច្រើន |
| វគ្គបិទ | ២:៥០ - ៣០០ | ៣:០០ | ដេញថ្លៃដោយយកថ្លៃតែមួយ |

តារាងទី១៖ ពេលវេលានៃការជួញដូរ

✦ចំណាំ៖ ប្រសិនបើគ្មានការផ្គូផ្គងបញ្ជានៅម៉ោង៩:០០នាទីព្រឹកទេ នោះវគ្គបើកនឹងត្រូវពន្យាររហូតដល់មានការផ្គូផ្គងនៅក្នុងថ្ងៃដដែល។

➢ វិធីសាស្ត្រជួញដូរតាមការចរចា

ចំពោះវិធីសាស្ត្រជួញដូរតាមការចរចា ម៉ោងជួញដូរគឺចាប់ពីម៉ោង៩:០០នាទីព្រឹក ដល់ម៉ោង៣:០០នាទីរសៀល។

### ៣.៣.៤. វិធីសាស្ត្រជួញដូរ

រាល់ការជួញដូរត្រូវធ្វើឡើងតាមវិធីសាស្ត្រដេញថ្លៃ (ATM) ឬវិធីសាស្ត្រជួញដូរតាមការចរចា (NTM)។

➢ **ការជួញដូរតាមវិធីសាស្ត្រដេញថ្លៃ**

រាល់ការជួញដូរត្រូវធ្វើឡើងតាមវិធីសាស្ត្រដេញថ្លៃ(ATM) ឬវិធីសាស្ត្រជួញដូរតាមការចរចា (NTM)។

គោលការណ៍ដេញថ្លៃ៖ រាល់ការជួញដូរត្រូវបានអនុវត្តតាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ ឬវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន យោងទៅតាមអាទិភាពថ្លៃ និងអាទិភាពពេលវេលា។

- អាទិភាពថ្លៃ

បញ្ជាលក់ដែលមានថ្លៃទាបជាងមានអាទិភាពលើបញ្ជាលក់ដែលមានថ្លៃខ្ពស់ជាង និង បញ្ជាទិញដែលមានថ្លៃខ្ពស់ជាងមានអាទិភាពលើបញ្ជាទិញដែលមានថ្លៃទាបជាង។

- អាទិភាពពេលវេលា

ក្នុងករណីបញ្ជាមានថ្លៃដូចគ្នាបញ្ជាដែលទទួលបានមុនមានអាទិភាពលើបញ្ជាដែលទទួលបានក្រោយ។

ឧទាហរណ៍៖

| បរិមាណលក់ | ថ្លៃ | បរិមាណទិញ |
|---|---|---|
| | : | |
| | ៦.៥០០ | ① ៥០០(បញ្ជាទិញដែលមានថ្លៃខ្ពស់ជាង) |
| | ៦.៤៨០ | ② ១០០ ③ ២០០ |
| | ៦.៤៦០ | |
| ③ ៣០០② ២០០ | ៦.៤២០ | |
| (បញ្ជាលក់ដែលមានថ្លៃទាបជាង) ①៤៥០ | ៦.៤០០ | |
| | : | |

តារាងទី២៖ របៀបជួញដូរតាមវិធីសាស្ត្រដេញថ្លៃ

- ដូចដែលបានបង្ហាញនៅក្នុងតារាងខាងលើ បញ្ជាទិញ ① និងបញ្ជាលក់ ① ត្រូវអនុវត្តការជួញដូរមុនយោងទៅតាមអាទិភាពថ្លៃ។
- ក្នុងចំណោមបញ្ជាដែលមានថ្លៃដូចគ្នា បញ្ជា ② ដែលទទួលបានមុន នឹងត្រូវអនុវត្តការជួញដូរមុនបញ្ជា ②។

➢ **វិធីសាស្ត្រជួញដូរតាមការចរចា**

វិធីសាស្ត្រជួញដូរតាមការចរចា ជាវិធីសាស្ត្រផ្គូផ្គងបញ្ជាតាមការចរចាទិញនិងលក់មួយគូ បន្ទាប់ពីអ្នកទិញនិងអ្នកលក់បានចរចា និងព្រមព្រៀងលើលក្ខខណ្ឌទាំងឡាយនៃការជួញដូរ។ ដើម្បីផ្គូផ្គងបញ្ជាទិញ និងលក់តាមការចរចាមួយគូបាន ចាំបាច់ត្រូវមានព័ត៌មានលម្អិតដូចគ្នាទាំងស្រុងចំនួន៤គឺ ឈ្មោះមូលបត្រ, ថ្លៃ , បរិមាណ និងលេខកូដជួញដូរតាមការចរចា។

លក្ខណៈសំខាន់ៗនៃវិធីសាស្ត្រជួញដូរតាមការចរចារ៖

- បញ្ជាអប្បបរមា៖ បញ្ជាតាមការចរចាត្រូវមានបរិមាណយ៉ាងហោច ៥០.០០០ភាគហ៊ុន ឬតម្លៃជួញដូរ២០០.០០០.០០០រៀល (យកមួយណាដែលតូចជាង)។

- ឯកតាគម្លាតថ្លៃ៖ ១រៀល។
- ដែនកំណត់ថ្លៃប្រចាំថ្ងៃ៖ មិនអនុវត្តចំពោះការជួញដូរតាមវិធីសាស្ត្រជួញដូរតាមការចរចា។
- ការលុបចោលបញ្ជា៖ ដរាបណាបញ្ជាមិនទាន់អនុវត្តការជួញដូរ នោះបញ្ជាតាមការចរចាអាចលុបបាន តែពុំអាចកែប្រែបានឡើយ។

## ៣.៤. ការទូទាត់ និងការរក្សាទុកមូលបត្រ

### ៣.៤.១.ការទូទាត់

ការទូទាត់គឺជាការបញ្ចប់ប្រតិបត្តិការ ដែលអ្នកលក់ផ្ទេរមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុទៅឲ្យអ្នកទិញ ហើយអ្នកទិញផ្ទេរសាច់ប្រាក់ទៅឲ្យអ្នកលក់។




❖ **លក្ខណៈនៃការទូទាត់របស់ ផ.ម.ក.៖**

- វិធីសាស្ត្រនៃការទូទាត់៖ DVP3 (ការប្រគល់មូលបត្រ ថ្នូរនឹងសាច់ប្រាក់គំរូទី៣)

DVP3 ជាដំណើរការនៃការប្រគល់មូលបត្រ ដែលត្រូវបានធ្វើឡើងក្នុងពេលដំណាលគ្នានៃការប្រគល់សាច់ប្រាក់ ដោយផ្អែកលើមូលដ្ឋានបន្សុទ្ធ (បន្សុទ្ធមូលបត្រ និង បន្សុទ្ធសាច់ប្រាក់) ។ វាត្រូវបានកើតឡើងនៅចុងគ្រានៃវដ្តដំណើរការប្រតិបត្តិការ។

- ពេលវេលានៃការទូទាត់៖ ម៉ោង ៨:៣០ នាទីព្រឹក (T+2)

សមាជិកត្រូវផ្ទេរមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ទៅគណនីរបស់ ផ.ម.ក. នៅមុនម៉ោង ៨:៣០ព្រឹក នៅកាលបរិច្ឆេទទូទាត់ ហើយផ.ម.ក. ត្រូវទូទាត់មូលបត្រ និងសាច់ប្រាក់បន្តទៅឲ្យសមាជិកដែលត្រូវទទួលការទូទាត់ បន្ទាប់ពីម៉ោង ៨:៣០ព្រឹក នៅថ្ងៃដដែលនៃកាលបរិច្ឆេទទូទាត់។

- ភ្នាក់ងារទូទាត់សាច់ប្រាក់ (ធនាគារអេស៊ីលីដា ធនាគារកាណាឌីយ៉ា និង ធនាគារ BIDC) មានតួនាទីបំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។

### ៣.៤.២. ការរក្សាទុកមូលបត្រ

ប្រតិបត្តិកររក្សាទុកមូលបត្រសំដៅដល់កន្លែងសម្រាប់ដាក់ផ្ញើមូលបត្រ។ការដាក់ផ្ញើមូលបត្រគឺជាដំណើរការនៃការផ្ទេរកម្មសិទ្ធិករមូលបត្រ តាមរយៈការផ្ទេររវាងគណនី (Book Entry) (ការកត់ត្រាឥណទាន/ឥណពន្ធ ក្នុងសៀវភៅគណនីរបស់សមាជិក និងអ្នកចូលរួម) ដោយគ្មានចរន្តនៃការផ្ទេរមូលបត្ររូបវ័ន្ត។

❖ អត្ថប្រយោជន៍នៃការជួញដូរមូលបត្រ

នៅពេលមូលបត្រមានការជួញដូររវាងវិនិយោគិន ប្រតិបត្តិកររក្សាទុកមូលបត្រធ្វើការទូទាត់នូវប្រតិបត្តិការទាំងនោះតាមរយៈការផ្ទេររវាងគណនី (Book Entry) ដោយគ្មានការផ្ទេរមូលបត្ររូបវ័ន្ត។ ដូច្នេះហានិភ័យចំពោះការបាត់ និងការលួចមូលបត្រត្រូវបានចៀសវាងទាំងស្រុង។ សមាជិក អ្នកចូលរួម និងអតិថិជន ដែលបានដាក់ផ្ញើមូលបត្រនៅ ផ.ម.ក. មិនចាំបាច់ដកមូលបត្រទៅវិញ នៅពេលដែលត្រូវអនុវត្តសិទ្ធិកម្មសិទ្ធិករឡើយ។

❖ ការបើកគណនី

បុគ្គលដែលអាចបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្ររួមមាន ក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ។ បុគ្គលដែលមានបំណងបើកគណនីមូលបត្រត្រូវបំពេញបែបបទបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ។ គ្រប់គណនីមូលបត្រទាំងអស់ រួមមានគណនីមូលបត្ររបស់សមាជិក ឬ អតិថិជនត្រូវបានបង្កើតឡើងក្នុង ប្រព័ន្ធ Ledger (ledger system) របស់ ផ.ម.ក. ដែលផ្ទុកផងដែរនូវទិន្នន័យលម្អិតនៃប្រតិបត្តិការរបស់សមាជិក និងអតិថិជន ព្រមទាំងទិន្នន័យលម្អិតនៃបញ្ជីភាគហ៊ុនិក។

❖ ការដាក់ផ្ញើមូលបត្រ

ដើម្បីដាក់ផ្ញើមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ បុគ្គលដែលដាក់ផ្ញើត្រូវផ្តល់ព័ត៌មានដូចខាងក្រោមដល់ប្រតិបត្តិកររក្សាទុកមូលបត្រ៖

- ប្រភេទមូលបត្រ
- ចំនួននៃការបោះផ្សាយ
- ឈ្មោះមូលបត្រ
- អក្សរកូដ
- ចំនួនមូលបត្រសរុប
- កាលបរិច្ឆេទបោះផ្សាយ
- កាលបរិច្ឆេទចុះបញ្ជី
- ព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងកម្មសិទ្ធិភាពមូលបត្រ។

# ជំពូកទី៤

# ការលូតលាស់ និងបញ្ហាប្រឈមរបស់ទីផ្សារមូលបត្រកម្ពុជា

## ៤.១.ការលូតលាស់របស់ទីផ្សារមូលបត្រកម្ពុជា

### ៤.១.១. កត្តាសេដ្ឋកិច្ច

ទីផ្សារមូលបត្រ និងសេដ្ឋកិច្ចមានឥទ្ធិពល និងទំនាក់ទំនងគ្នាទៅវិញទៅមក។ រយៈពេលជិតមួយទសវត្សកន្លងមកនេះ ទីផ្សារមូលបត្រមានការវិវឌ្ឍបន្តិចម្តងៗ ស្របតាមកំណើនសេដ្ឋកិច្ចជាតិ និងពិភពលោក។ កាលណាមានកំណើនសេដ្ឋកិច្ច នោះចំណូល ក៏ដូចជាចំណេញសុទ្ធ (Net Income) មិនថាជាក្រុមហ៊ុន ឬស្ថាប័នអាជីវកម្មផ្សេងៗ ព្រមទាំងបុគ្គលទូទៅមានការកើនឡើងទៅតាមនោះដែរ ជាហេតុធ្វើអោយទីផ្សារមូលបត្រមានសកម្មភាពកាន់តែខ្លាំងក្លាថែមទៀត។ ពាក្យថាសេដ្ឋកិច្ចមានវិសាលភាពគ្របសណ្តប់កត្តាជាច្រើនដូចជា៖

- **កំណើនតម្រូវការ និងផ្គត់ផ្គង់លើទីផ្សារ**

នៅពេលមានកំណើនសេដ្ឋកិច្ច ក្រុមហ៊ុនបោះផ្សាយអាចពង្រីកសកម្មភាពអាជីវកម្មតាមរយៈកំណើនតម្រូវការទំនិញ និងសេវារបស់អតិថិជន។ ក្នុងស្ថានភាពនេះ ក្រុមហ៊ុនអាចនឹងត្រូវការពង្រីកទំហំអាជីវកម្មបន្ថែមទៀត ហើយបន្តបោះផ្សាយមូលបត្របន្ថែម ដើម្បីកៀរគរមូលធនពីមជ្ឈដ្ឋានខាងក្រៅ។ ចំណែកវិនិយោគិនវិញ ក៏មានកំណើនមូលធនក្នុងការទិញមូលបត្របន្ថែមទៀតផងដែរ។

- **អត្រាការប្រាក់**

កាលណាអត្រាការប្រាក់ នៅធនាគារមានការកើនឡើង ធ្វើអោយក្រុមហ៊ុន និងស្ថាប័ននានាងាកមកបោះផ្សាយលក់មូលបត្រជំនួសការជ្រើសរើសកម្ចីពីធនាគារ ពីព្រោះពួកគេទទួលបានការវិនិយោគ (កម្ចី)រយៈពេលវែង (ចំពោះ សញ្ញាបណ្ណ) និងមិនមានកាតព្វកិច្ចសងការប្រាក់(ចំពោះភាគហ៊ុន) ជាប្រចាំ ព្រមទាំងអាចទទួលបានផលចំណេញច្រើនទៀតផងដែរ។

- **លំហូរប្រព័ន្ធហិរញ្ញវត្ថុ**

ប្រព័ន្ធហិរញ្ញវត្ថុប្រៀបដូចជាសរសៃឈាមនៃសេដ្ឋកិច្ច កាលណាប្រព័ន្ធហិរញ្ញវត្ថុ មានជាអាទិ៍ប្រព័ន្ធធនាគារមានភាពកាន់តែប្រសើរឡើង ធ្វើអោយប្រតិបត្តិការទីផ្សារមូលបត្រកាន់តែមានភាពរលូនទៅតាមនោះដែរ ដោយសាររាល់ប្រតិបត្តិការ ជាពិសេសដំណាក់ការផាត់ទាត់ និងទូទាត់មូលបត្រត្រូវមានប្រព័ន្ធទូទាត់មួយដែលមានប្រសិទ្ធិភាព សុវត្ថិភាព និងផ្តល់ភាពងាយស្រួលជាចាំបាច់ក្នុងការជួយសម្រួលដល់ការបំពេញប្រតិបត្តិការជួញដូរ។

### ៤.១.២. ផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់វិស័យមូលបត្រ

ចំពោះវិស័យមូលបត្រ រាជរដ្ឋាភិបាល បាននិងកំពុងលើកកម្ពស់ដោយចាត់ចូលជា គោលដៅសំខាន់មួយក្នុងចំណោមគោលដៅសំខាន់ផ្សេងទៀត។ រាជរដ្ឋាភិបាលបានរៀបចំផែនការយុទ្ធសាស្ត្រទៅតាមដំណាក់កាល ដើម្បីបង្កើនវឌ្ឍនភាព និងការចុះបញ្ជីនៅទីផ្សារ។ ការបង្កើនចំនួនក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រនៅលើទីផ្សារត្រូវបានផ្តោតការយកចិត្តទុកដាក់ខ្ពស់តាមរយៈការអភិវឌ្ឍន៍ និងការអនុវត្តផែនការជំរុញការចុះបញ្ជីនៅលើទីផ្សារ ការផ្តល់ការលើកទឹកចិត្តនានាដល់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ នៅលើទីផ្សារ ដូចជា ការលើកទឹកចិត្តផ្នែកពន្ធដារក្នុងវិស័យមូលបត្រ ត្រូវបានដាក់ឲ្យអនុម័ត និងផ្សព្វផ្សាយព្រមជាមួយនឹងការដាក់ឲ្យអនុវត្តកម្មវិធីជំរុញការយល់ដឹងជាសាធារណៈ។ ការសម្របសម្រួលដើម្បីជំរុញកំណើនក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រកាន់ច្រើននៅលើទីផ្សារ ត្រូវបានធ្វើឡើងប្រកបដោយកិច្ចខិតខំប្រឹងប្រែងខ្ពស់។ វិធាននិងប្រព័ន្ធសម្រាប់ជួញដូរត្រូវបានអភិវឌ្ឍន៍ឲ្យប្រសើរឡើងនៅក្នុង ខែវិច្ឆិកា ឆ្នាំ២០១៤ ដើម្បីជួយសម្រួលដល់ការជួញដូរជានិរន្តរ៍ បន្ថែមទៅលើការជួញដូរថ្ងៃតែមួយ និងការជួញដូរមុនការទូទាត់។ គណៈកម្មការមូលបត្រកម្ពុជាបានធ្វើវិសោធនកម្មបទប្បញ្ញត្តិ នៅក្នុង ខែកញ្ញា ឆ្នាំ២០១៥ ដើម្បីលើកទឹកចិត្តដល់ក្រុមហ៊ុនក្នុងការចុះបញ្ជីលក់មូលបត្រនៅលើទីផ្សារដោយធ្វើការបែងចែកទីផ្សារជាពីរប្រភេទគឺ ទីផ្សារគោល (Main Board) សម្រាប់សហគ្រាសធុនធំ និងទីផ្សារកំណើន (Growth Board) សម្រាប់សហគ្រាស ធុនតូច និងមធ្យម តាមរយៈការផ្តល់ភាពងាយស្រួល ក្នុងការចូលរួមក្នុងទីផ្សារសម្រាប់ សហគ្រាសធុនតូច និងមធ្យម និងកាត់បន្ថយលក្ខខណ្ឌជាអប្បបរមា ព្រមទាំងលក្ខខណ្ឌតម្រូវលើរបាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ។

ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១០ ដែលគ.ម.ក. បានផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រចំនួន១៥ ក្រុមហ៊ុន។ គ.ម.ក. ក៏បានផ្តល់ការទទួលស្គាល់ដល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ភ្នាក់ងារទូទាត់ ក្រុមហ៊ុនគណនេយ្យជំនាញផ្តល់សេវាក្នុងវិស័យមូលបត្រ សវនករឯករាជ្យ និងក្រុមហ៊ុនវាយតម្លៃផ្តល់សេវាក្នុងវិស័យមូលបត្រ។ ក្នុងឆ្នាំ២០១៤ និងឆ្នាំ២០១៥ បុគ្គលចំនួន១១៨ រូបបានប្រឡងជាប់ទទួលស្គាល់គុណវុឌ្ឍិដែលរៀបចំដោយ គ.ម.ក.[15]។

នាពេលបច្ចុប្បន្នរហូតដល់ឆមាសទី១ ឆ្នាំ២០២០ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រដែលបានចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជាមាន៖

- មូលបត្រកម្មសិទ្ធិ Stock
  - រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (Phnom Penh Water Supply Authority, PWAS)

[15] យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១៦-២០២៥, ជំពូកទី៣ វិស័យមិនមែនធនាគារ ទំព័រ២៧

- ក្រុមហ៊ុន ហ្គ្រេន ធ្វីន អីនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី ( Grand Twins International (Cambodia) Plc, GTI)
- កំពង់ផែស្វយ័តក្រុងភ្នំពេញ (Phnom Penh Autonomous Port, PPAP)
- ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី ឬ តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (Phnom Penh SEZ Plc., PPSP)
- កំពង់ផែស្វយ័តក្រុងព្រះសីហនុ (Sihanoukville Autonomous Port, PAS)
- ធនាគារ អេស៊ីលីដា ភីអិលស៊ី (Acleda Bank Plc. , ABC)

➢ សញ្ញាបណ្ណ Bond

- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីធីត (Hattha Kaksekor Limited, HKL)
- អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី (LOLC Cambodia Plc.)
- ធនាគារ អេប៊ីអេ សញ្ញាបណ្ណសាជីវកម្ម (Advanced Bank of Asia Limited, ABA)
- ធនាគារ ភ្នំពេញពាណិជ្ជ (Phnom Penh Commercial Bank, PPCB)
- អ អិម អេ (ខេមបូឌា) ម.ក (RMA Cambodia Plc., RMA)
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក (Prasac Microfinance Institution Plc., PRA ។

### ៤.១.៣. ការរីកចម្រើននៃប្រព័ន្ធផ្សព្វផ្សាយ

នៅពេលបច្ចុប្បន្ននេះ នៅក្នុងវិស័យមូលបត្រការរីកចម្រើននៃប្រព័ន្ធផ្សព្វផ្សាយមានភាពទូលំទូលាយងាយស្រួលជាងមុនក្នុងការស្វែងយល់ និងតាមដាននៅបម្រែបម្រួលថ្លៃភាគហ៊ុនប្រចាំថ្ងៃ និងព័ត៌មានផ្សេងៗដែលទាក់ទងទៅនឹងការវិនិយោគមូលបត្រ។ នៅក្នុងវិស័យនេះ គ.ម.ក. និង ផ.ម.ក. បានធ្វើការផ្សព្វផ្សាយព័ត៌មានទាក់ទងជាមួយមូលបត្រតាមរយៈការផ្សព្វផ្សាយដូចខាងក្រោម៖

- STOCKINFO គឺជាការបោះផ្សាយប្រចាំឆ្នាំ ដែលផ្តោតសំខាន់លើព័ត៌មានអំពីក្រុមហ៊ុនចុះបញ្ជីទាំងអស់នៅ ផ.ម.ក.។ STOCKINFO ត្រូវបានផ្តួចផ្តើមឡើងក្នុងគោលបំណងផ្តល់ជូនវិនិយោគិននូវភាពងាយស្រួលក្នុងការស្វែងរកព័ត៌មានអំពីក្រុមហ៊ុនចុះបញ្ជីក្នុងកូនសៀវភៅតែមួយ។ ព័ត៌មាននៅក្នុង STOCKINFO មានដូចជាសេចក្តីសង្ខេបអំពីក្រុមហ៊ុន ព័ត៌មានជួញដូរ របាយការណ៍ហិរញ្ញវត្ថុ និងព័ត៌មានសំខាន់ៗផ្សេងទៀត។
- ប៉ុស្តិ៍មូលបត្រ៖ ចំណេះដឹងមូលដ្ឋាន ជាកម្រងអត្ថបទអប់រំដែលផ្តោតលើការលើកកម្ពស់ការយល់ដឹងឲ្យកាន់តែទូលំទូលាយអំពីដំណើរការនៃទីផ្សារមូលបត្រនៅកម្ពុជា។ កម្រងអត្ថបទនេះចេញផ្សាយជា

ស៊េរី ដែលអនុញ្ញាតឱ្យវិនិយោគិនស្វែងយល់ និងទទួលចំណេះដឹងបានជាបន្តបន្ទាប់។ អត្ថបទនឹងចេញផ្សាយនៅរៀងរាល់ថ្ងៃច័ន្ទនៃដើមខែនីមួយៗដោយផ្តោតលើផ្នែកផ្សេងៗនៃទីផ្សារមូលបត្រ រាប់ចាប់ពីចំណេះដឹងមូលដ្ឋានគ្រឹះ រហូតដល់ប្រធានបទសំខាន់ៗនានា។ ប៉ុស្តិ៍មូលបត្រគឺជាកិច្ចសហការរវាងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងកាសែតភ្នំពេញប៉ុស្តិ៍។

- FACTBOOK ជាការចងក្រងនូវប្រវត្តិ សកម្មភាពចម្បងៗរបស់ ផ.ម.ក. និងស្ថានភាពនៃការជួញដូរភាគហ៊ុន ព្រមទាំងនីតិវិធីនិងដំណើរការនៃការចុះបញ្ជី ការជួញដូរ ការផាត់ទាត់ ការទូទាត់ និងការរក្សាទុកភាគហ៊ុននៅផ.ម.ក.។ សៀវភៅនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងជុំវិញក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក៏ដូចជាទីផ្សារមូលបត្រនៅកម្ពុ ជាទូទៅដល់សាធារណជន និងជាពិសេសវិនិយោគិនដែលមានបំណងវិនិយោគប្រាក់សន្សំប្រកបដោយភាពឈ្លាសវៃ រួមទាំងក្រុមហ៊ុនដែលមានបំណងស្វែងរកមូលធនពីសាធារណជនតាមរយៈផ្សារមូលបត្រកម្ពុជា។

### ៤.១.៤. ការរីកចម្រើននៃប្រព័ន្ធបច្ចេកវិទ្យា

បច្ចេកវិទ្យាបានដើរតួយ៉ាងសំខាន់ក្នុងវិស័យមូលបត្រ ដែលមនុស្សភាគច្រើនបានប្រើប្រាស់វាស្ទើរតែរាល់ថ្ងៃ។ បច្ចុប្បន្ននេះប្រទេសកម្ពុជាក៏ត្រៀមខ្លួនរួចជាស្រេចសម្រាប់អភិវឌ្ឍន៍ និងអនុវត្តប្រព័ន្ធបច្ចេកវិទ្យានេះឲ្យកាន់តែល្អប្រសើរនៅក្នុងវិស័យមូលបត្រ ដូចជាប្រព័ន្ធជួញដូរ ប្រព័ន្ធទូទាត់ និងការបម្រើសេវាផ្សេងទៀតឱ្យកាន់តែមានភាពងាយស្រួល។ ផ.ម.ក.បានបង្កើត **ប្រព័ន្ធជួញដូរចល័ត** (MTS) ដែលជាប្រព័ន្ធថ្មីមួយទើបតែបង្កើតឡើង។ តាមរយៈប្រព័ន្ធនេះ វិនិយោគិនអាចជួញដូរភាគហ៊ុនបានឆាប់រហ័ស ប្រកបដោយសុវត្ថិភាព និងងាយស្រួល។ MTS បានភ្ជាប់មកនូវមុខងារជាច្រើនដែលអនុញ្ញាតឲ្យអ្នកប្រើប្រាស់អាចដាក់បញ្ជាដោយខ្លួនឯងពីគ្រប់ទីកន្លែង ពិនិត្យមើលទិន្នន័យទីផ្សារបច្ចុប្បន្ន និងកន្លងមក រួមជាមួយនឹងទិន្នន័យនៃគណនីជួញដូររបស់ខ្លួនតាមរយៈ smartphones ឬ tablets ដែលតភ្ជាប់នឹងប្រព័ន្ធអ៊ីនធឺណេត។

នៅក្នុងប្រព័ន្ធជួញដូរចល័ត (MTS) វិនិយោគិនអាចធ្វើប្រត្តិបតិការដូចជា៖

- ការដាក់បញ្ជាទិញ-លក់
- ការកែប្រែ និងលុបចោលបញ្ជា
- ការពិនិត្យមើលបញ្ជា និងកំណត់ត្រានៃការជួញដូរកន្លងមក
- ការពិនិត្យមើលសមតុល្យក្នុងគណនីជួញដូរ
- ការពិនិត្យមើលភាពចំណេញ/ខាតនៃមូលបត្រកាន់កាប់បច្ចុប្បន្ន និងប្រតិបត្តិការកន្លងមក
- ការតាមដានស្ថានភាពទីផ្សារ ការស្វែងរកព័ត៌មាន និងសេចក្តីជូនដំណឹងផ្សេងៗដែលពាក់ព័ន្ធ

- ការស្នើដកប្រាក់។

ក្រៅពីប្រព័ន្ធជួញដូរ(MTS) វិនិយោគិនក៏អាចទាញយកកម្មវិធី ដើម្បីតាមដាន និងទទួលព័ត៌មានផ្សេងៗ ពាក់ព័ន្ធនឹងការវិនិយោគភាគហ៊ុន តាមរយៈកម្មវិធី(App)ចល័តដោយប្រើប្រព័ន្ធអិនធើណិត ដូចជាកម្មវិធី App មានឈ្មោះថា **ផ្សារហ៊ុន (Phsar Hun)** ដែលមានការពេញនិយមជាងគេ។

### ៤.១.៥ កំណើនទំនោរនៃការវិនិយោគមូលបត្រ

ការវិនិយោគមូលបត្រ អាចជាការវិនិយោគថ្មីមួយសម្រាប់កម្ពុជា ដែលជាទូទៅវិនិយោគិនភាគច្រើន និយមវិនិយោគលើអចលនទ្រព្យ ការដាក់ប្រាក់បញ្ញើរ ឬចងការប្រាក់ជាដើម។ល។ ប៉ុន្តែបច្ចុប្បន្នយើងសង្កេតឃើញថា វិនិយោគិនចាប់ផ្តើមមានទំនោរងាកមកវិនិយោគមូលបត្រកាន់តែច្រើនឡើង ដោយសារវិនិយោគិនមានការយល់ដឹងច្រើនជាងមុនពីមូលបត្រ ដោយអាចវិភាគពីផលចំណេញ សុវត្ថិភាព និងអត្ថប្រយោជន៍ផ្សេងទៀតពីការវិនិយោគមូលបត្រ។ នៅពេលមានកំណើនវិនិយោគិន និងក្រុមហ៊ុនបោះផ្សាយ ធ្វើអោយមូលបត្រនៅលើទីផ្សារងាយស្រួលជួញដូរជាងមុនឬធ្វើអោយមានកំណើនសន្ទនីយភាពទីផ្សារ។កំណើនគណនីជួញដូររបស់វិនិយោគិនមានការកើនឡើងចំនួន ៩៧៥ គណនី គិតត្រឹមឆ្នាំ២០១៩ សរុបមានចំនួន ២២ ៤៤៦គណនី ដែលក្នុងនោះ ៨៣%ជាវិនិយោគិនក្នុងស្រុក និង១៧%ជាវិនិយោគិនបរទេស[16]។

### ៤.១.៦.ទស្សនៈរបស់វិនិយោគិន

មនុស្សម្នាក់ៗមានទស្សនៈវិនិច្ឆ័យ និង ការយល់ឃើញរៀងៗខ្លួនទៅលើការទិញ ឬលក់ភាគហ៊ុននីមួយៗ។ ទស្សនៈវិនិយោគិន អាចជាកត្តាមួយធ្វើអោយមានកំណើនសកម្មភាពជួញដូរនៅលើទីផ្សារមូលបត្រផងដែរ។ គេអាចចែកកត្តាដែលធ្វើឲ្យមនុស្សសម្រេចចិត្តទិញ ឬលក់ភាគហ៊ុនជាពីរធំៗគឺ កត្តាវិទ្យាសាស្ត្រ និងកត្តាចិត្តសាស្ត្រ។[17]

#### ក.កត្តាវិទ្យាសាស្ត្រ

កត្តាវិទ្យាសាស្ត្រគឺសំដៅទៅលើការសម្រេចចិត្តទិញ ឬលក់ភាគហ៊ុនតាមរយៈការវិភាគល្អិតល្អន់ជាលក្ខណៈវិទ្យាសាស្ត្រ ទៅលើលទ្ធភាពចំណេញ និងសុខភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននោះ។ វិនិយោគិនពិចារណាលើព័ត៌មានទាំងឡាយណាដែលពាក់ព័ន្ធនឹងក្រុមហ៊ុន ព្រមទាំងព័ត៌មានអតីតកាល និងបច្ចុប្បន្នកាល រួចធ្វើការវាយតម្លៃអំពីភាពរឹងមាំរបស់ក្រុមហ៊ុន (ទាំងផ្នែកហិរញ្ញវត្ថុនិងអាជីវកម្ម) ហើយប៉ាន់ស្មាន (educated guess) អំពីលទ្ធភាពរកប្រាក់ចំណេញរបស់ក្រុមហ៊ុននាពេលអនាគត។ ដូច្នេះ អាចនិយាយបាន

[16] ពុទ្ធិមូលបត្រ៖ ទិដ្ឋភាពទូទៅនៃទីផ្សារមូលបត្រកម្ពុជាគិតត្រឹមឆ្នាំ២០១៩ លេខ៤៥,ចេញផ្សាយឆ្នាំ២០២០

[17] www.csx.com.kh, ការអប់រំនិងការផ្សព្វផ្សាយ, បទសម្ភាសន៍

ថា រាល់ថ្លៃដែលវិនិយោគិនដាក់ទិញឬលក់ គឺបានឆ្លងកាត់ការពិចារណាលើព័ត៌មានដែលពាក់ព័ន្ធនឹងក្រុមហ៊ុននោះរួចហើយ។ ប៉ុន្តែជាញឹកញាប់ បើទោះជានៅលើទីផ្សារមិនមានព័ត៌មានថ្មីក៏ដោយ ក៏ថ្លៃភាគហ៊ុននៅតែប្រែប្រួល នោះគឺដោយសារតែភាពមិនច្បាស់លាស់នៃអនាគត ទាក់ទងនឹងសកម្មភាពអាជីវកម្មនិងប្រាក់ចំណេញរបស់ក្រុមហ៊ុន ហើយនិងការប្រែប្រួលនៃការយល់ឃើញរបស់វិនិយោគិនទៅតាមពេលវេលា។

**ខ.កត្តាចិត្តសាស្ត្រ**

កត្តាចិត្តសាស្ត្រ គឺសំដៅដល់ការសម្រេចចិត្តទិញ/លក់ភាគហ៊ុន ដោយមិនបានឆ្លងកាត់ការពិចារណាល្អិតល្អន់ ប៉ុន្តែធ្វើឡើងដោយអារម្មណ៍ ឬការយល់ឃើញ។ ព័ត៌មានល្អៗអំពីក្រុមហ៊ុនមួយឬទីផ្សារទាំងមូលអាចធ្វើឱ្យមនុស្សរំជើបរំជួល ដណ្តើមគ្នាទិញ ព្រោះវាជាឱកាសក្នុងកាទទួលបានផលចំណេញវិនិយោគ ដែលធ្វើឱ្យមានការកើនឡើងនូវថ្លៃភាគហ៊ុន និងសកម្មភាពជួញដូរជារួមនៅលើទីផ្សារ។

### ៤.១.៧. ស្ថេរភាពនយោបាយ និង ប្រសិទ្ធិភាពនៃការអនុវត្តច្បាប់

ស្ថានភាពនយោបាយជាកត្តាគ្របដណ្តប់ និងមានឥទ្ធិពលលើគ្រប់វិស័យ។ ស្ថេរភាពនយោបាយ ធ្វើអោយវិនិយោគិនមិនថាជាតិ និងអន្តរជាតិមានទំនុកចិត្តក្នុងការបោះទុនវិនិយោគ នាំទៅរកកំណើនវិនិយោគជាលក្ខណៈជាតិ និងអន្តរជាតិ ឬកំណើនវិនិយោគិនបរទេស និងផ្តល់ឱកាសដល់ស្ថាប័នវិនិយោគបរទេសអាចបោះផ្សាយលក់មូលបត្រនៅកម្ពុជាផ្ទាល់ ចំណែកវិនិយោគិនរូបវន្តបុគ្គលក៏មានទំនុកចិត្តក្នុងការវិនិយោគផងដែរ។ ប្រសិទ្ធិភាពនៃការអនុវត្តច្បាប់ ធ្វើអោយវិនិយោគិនទូទៅជាពិសេសវិនិយោគិនបរទេស អាចទទួលបានការដោះស្រាយបញ្ហាតាមផ្លូវច្បាប់ប្រកបដោយសុក្រឹតភាព តម្លាភាព និងលើកកម្ពស់ឈ្មោះប្រទេសជាតិទៅកាន់វិនិយោគិនបរទេសផ្សេងទៀតអោយមកវិនិយោគនៅកម្ពុជាកាន់តែច្រើនឡើង។

## ៤.២.បញ្ហាប្រឈមរបស់ទីផ្សារមូលបត្រកម្ពុជា

ក្រៅពីឱកាស វិនិយោគិនគួរតែស្វែងយល់អំពីបញ្ហាប្រឈមមួយចំនួនដែលប៉ះពាល់ដល់ដំណើរការវិនិយោគផងដែរ។ កត្តាមួយចំនួនដែលវិនិយោគិនគួរយកចិត្តទុកដាក់នោះមានដូចជា៖

### ៤.២.១. កំណើនក្រុមហ៊ុនចុះបញ្ជីលើទីផ្សារនៅមានកម្រិត

គ.ម.ក. គឺជានិយ័តករមូលបត្រ ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩។ ចំពោះ ផ.ម.ក. ដែលត្រូវបានប្រកាសបើកការជួញដូរមូលបត្រនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ រហូតមកដល់ពេលបច្ចុប្បន្ននេះ។ យើងសង្កេតឃើញថា នាពេលបច្ចុប្បន្នរហូតដល់ឆមាសទី១ ឆ្នាំ២០២០ មានក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ចំនួន១២ក្រុមហ៊ុន ក្នុងនោះមាន ក្រុមហ៊ុនមូលបត្រកម្មសិទ្ធិចំនួន ៦ក្រុមហ៊ុន និងក្រុមហ៊ុនមូលបត្របំណុលចំនួន ៦ក្រុមហ៊ុន។ ដោយសារទីផ្សារមូលបត្រកម្ពុជាចាប់ផ្តើមបើកដំណើរការរយៈ

ពេល ៨ឆ្នាំ ហើយមានតែក្រុមហ៊ុនចំនួនតែ១២ប៉ុណ្ណោះចូលរួមបោះផ្សាយលក់មូលបត្រ។ ជាការពិត តាមនីតិវិធីនៃការចុះបញ្ជី ដើម្បីអាចឱ្យក្រុមហ៊ុន ឬស្ថាប័នមួយអាចបោះផ្សាយលក់មូលបត្របានទាមទារមានគុណវុឌ្ឍិគ្រប់គ្រាន់ ដើម្បីធានាពីស្ថេរភាពហិរញ្ញវត្ថុ និងប្រព័ន្ធគ្រប់គ្រងមានប្រសិទ្ធិភាព ជាពិសេសនោះគឺការផ្តល់ទំនុកចិត្តដល់បណ្តាវិនិយោគិនសាធារណៈ ក្នុងការវិនិយោគលើមូលបត្រក្នុងក្រុមហ៊ុននោះ។ ចំពោះទីផ្សារមូលបត្រកម្ពុជាតាមតថភាពបច្ចុប្បន្ន ត្រូវការឱ្យមានក្រុមហ៊ុនចុះបញ្ជីបន្ថែមទៀត ដើម្បីផ្តល់ជម្រើសដល់វិនិយោគិនបង្កើនសកម្មភាពជួញដូរនៅលើទីផ្សារ និងជួយលើកកម្ពស់ទីផ្សារមូលបត្រនាពេលអនាគត។

យើងអាចសន្និដ្ឋានបានថា ទីផ្សារមូលបត្រនៅកម្ពុជា គឺនៅមានចំនួនក្រុមហ៊ុនតិចតួចចូលរួមក្នុងការបោះផ្សាយលក់មូលបត្រ និងនូវមានកម្រិតនៅឡើយ ហេតុដូចនេះហើយវាជាបញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមផ្សេងទៀត សម្រាប់ទីផ្សារមូលបត្រកម្ពុជានាពេលបច្ចុប្បន្ននេះ។

### ៤.២.២. គុណវុឌ្ឍិដើម្បីក្លាយជាក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ

ក្រុមហ៊ុនដែលមានបំណងចង់បោះផ្សាយលក់មូលបត្រជាសាធារណៈ នៅក្នុងទីផ្សារមូលបត្រកម្ពុជាត្រូវគោរពតាមលក្ខខណ្ឌ និងអនុលោមតាមច្បាប់ បទបញ្ញត្តិជាច្រើន ទើបអាចមានសិទ្ធិបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបាន។ ម៉្យាងទៀតក្រុមហ៊ុនត្រូវឆ្លងកាត់ការត្រួតពិនិត្យ និងការពិចារណាពីសំណាក់គណៈកម្មការមូលបត្រកម្ពុជាយ៉ាងតឹងរឹង និងត្រឹមត្រូវដូចខាងក្រោម៖

- គុណភាពនៃអភិបាលកិច្ច និងប្រវត្តិហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ
- តម្រូវការរបស់ទីផ្សារមូលបត្រ រួមទាំងតម្រូវការដើម្បីអភិវឌ្ឍទីផ្សារមូលបត្រ
- កត្តាជោគជ័យនៃសំណើបោះផ្សាយ និងលក់មូលបត្រជាសាធារណៈរួមទាំងអត្ថិភាពនៃកិច្ចសន្យាធានាទិញ ឬគម្រោងចុះកិច្ចសន្យាធានាទិញដែលនឹងធានាថារាល់មូលបត្រទាំងអស់ដែលប្រកាសលក់ក្នុងក្របខ័ណ្ឌនៃសំណើលក់ជាសាធារណៈនេះអាចបោះផ្សាយបាន ឬអាចលក់អស់
- លក្ខខណ្ឌតម្រូវក្នុងការចុះបញ្ជីដើម្បីលក់មូលបត្រនៅលើទីផ្សារ
- លក្ខខណ្ឌតម្រូវផ្សេងៗ ក្នុងការផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មានស្របតាមការកំណត់របស់ គ.ម.ក.
- បញ្ហាផ្សេងៗទៀតដែលគ.ម.ក.ពិនិត្យឃើញថាមានលក្ខណៈមិនសមស្របក្នុងការការពារផលប្រយោជន៍សាធារណៈ ដែលតម្រូវអោយមានការកែតម្រូវ។

ចំណុចទាំងអស់នេះហើយដែលជាបញ្ហា និងឧបសគ្គសំរាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ដែលអាចនឹងមានការលំបាកក្នុងការអនុវត្តតាមអោយទាន់ស្ថានភាព និងប្រើប្រាស់រយៈពេលយូរក្នុងការរៀបចំខ្លួនដើម្បីចូលក្នុងទីផ្សារមូលបត្រ។ ដូចនេះវាជាបញ្ហាប្រឈមរបស់ក្រុមហ៊ុនផ្សេងៗ ដែលចង់បោះផ្សាយលក់មូលបត្រ

និង ត្រូវពិចារណាគ្រប់ចំណុចដូចដែលមានចែងយ៉ាងច្បាស់ មុនឈានចូលក្នុងទីផ្សារមូលបត្រកម្ពុជា។

### ៤.២.៣. ការយល់ដឹងពីវិស័យមូលបត្រនៅមានកំរិត

ទីផ្សារមូលបត្រនៅប្រទេសកម្ពុជា ទើបតែបានបង្កើតឡើង និងមានលក្ខណៈក្មេងខ្ចី។ សំរាប់សាធារណៈជនទូទៅ យើងសង្កេតឃើញថាការយល់ដឹងពីវិស័យមូលបត្រមិនទាន់មានភាពទូលំទូលាយ និងមានកម្រិតនៅឡើយ។ មានសាធារណជនខ្លះមិនបានដឹងថា អ្វីជាមូលបត្រ អ្វីជាទីផ្សារមូលបត្រ ជាពិសេសការវិនិយោគមូលបត្រនៅលើទីផ្សារមូលបត្រនៅឡើយទេ។ តាមរយៈទិន្នន័យដោយគិតត្រឹមដំណាច់ត្រីមាសទី១ ឆ្នាំ២០២០ ចំនួនវិនិយោគដែលទទួលបានលេខអត្តសញ្ញាណវិនិយោគិនពី គ.ម.ក. រួចហើយ នឹងបានទៅបើកគណនីជួញដូរមូលបត្រនៅតាមបណ្តាក្រុមហ៊ុនមូលបត្រមានចំនួនប្រហែលពីរម៉ឺនបួនពាន់លេខគណនីជួញដូរ។ ចំណែកចំនួនវិនិយោគិនដែលចូលរួមវិនិយោគក្នុងទីផ្សារមូលបត្រដែលគិតត្រឹមត្រីមាសទី១ ឆ្នាំ២០២០ ក្នុងនោះភាគហ៊ុនរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ(PWSA) ចំនួន១៩%, ភាគហ៊ុនរបស់ក្រុមហ៊ុនហ្គ្រេនធ្វីនអ៊ិនធើណេសិនណល(ខេមបូឌា)ភីអិលស៊ី (GTI) មានចំនួន១០%, ភាគហ៊ុនរបស់កំពង់ផែស្វយ័តភ្នំពេញ (PPAP) មានចំនួន១៩%, ភាគហ៊ុនរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ(PAS) មានចំនួន២៨%, ភាគហ៊ុនរបស់ភ្នំពេញ អេសអ៊ីហ្សិតភីអិលស៊ី(PPSP) មានចំនួន១៩% និងមូលបត្របំណុលរបស់ ធនាគារវឌ្ឍនៈអាស៊ីចំកាត់(ABA) មានចំនួន៦%[18]។ ហេតុដូចនេះទើប គ.ម.ក. បាននឹងកំពុងខិតខំផ្សព្វផ្សាយព័ត៌មាន បង្កើតសិក្ខាសាលា និងពិព័រណ៍ផ្សារហ៊ុនកម្ពុជាដើម្បីបង្កើតការយល់ដឹងដល់មហាជនអំពីវិស័យមូលបត្រនេះ។

## ៤.៣. ការវិភាគទិន្នន័យមូលធនូបនីយកម្មទីផ្សារសរុប ( Market Capitalization ) របស់ក្រុមហ៊ុនបោះផ្សាយមូលបត្រកម្មសិទ្ធិនីមួយៗពីឆ្នាំ២០១៥-ឆ្នាំ២០១៩

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលបានចុះបញ្ជីនៅទីផ្សារមូលបត្រកម្ពុជានៅ ឆ្នាំ២០១៥-ឆ្នាំ២០១៩មាន៖

- រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (Phnom Penh Water Supply Authority, PWAS)
- ក្រុមហ៊ុន ហ្គ្រេន ធ្វីន អីនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី ( Grand Twins International (Cambodia) Plc, GTI)
- កំពង់ផែស្វយ័តក្រុងភ្នំពេញ (Phnom Penh Autonomous Port, PPAP)
- ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី ឬ តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (Phnom Penh SEZ Plc., PPSP)
- កំពង់ផែស្វយ័តក្រុងព្រះសីហនុ (Sihanoukville Autonomous Port, PAS)

[18] ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគ ប្រចាំត្រីមាសទ១ ឆ្នាំ២០២០ ចេញផ្សាយលេខទី១ ទំព័រ១៦

- **តារាងទី៣៖ ទិន្នន័យមូលធនូបនីយកម្មទីផ្សារសរុប (Market Cap.) (លានរៀល)**

| មូលធនូបនីយកម្មទីផ្សារសរុប (Market Cap.)(លានរៀល) | | | | | |
|---|---|---|---|---|---|
| Year | PWSA | GTI | PPAP | PPSP | PAS |
| 2015 | 444,824 | 160,800 | 113,764 | - | - |
| 2016 | 356,590 | 172,800 | 109,627 | 165,523 | - |
| 2017 | 335,716 | 188,000 | 106,318 | 163,208 | 437,437 |
| 2018 | 365,287 | 172,800 | 158,856 | 208,438 | 866,297 |
| 2019 | 521,839 | 176,000 | 258,555 | 185,438 | 1,663,976 |

- **ក្រាហ្វិកសសរមូលធនូបនីយកម្មពីឆ្នាំ ២០១៥-២០១៩**



- **ក្រាហ្វិកខ្សែក្រាបមូលធនូបនីយកម្ម**




- **ការវិភាគទិន្នន័យ**

ទិន្នន័យមូលធនូបនីយកម្ម (Market Capitalization) ជាតម្លៃភាគហ៊ុនសរុបក្នុងទីផ្សាររបស់ក្រុមហ៊ុនចុះបញ្ជីមួយ។ បានមកពីការគណនាដោយយកថ្លៃភាគហ៊ុនចុងក្រោយរបស់ក្រុមហ៊ុនចុះបញ្ជីមួយ គុណនឹងចំនួនភាគហ៊ុនចុះបញ្ជីរបស់ក្រុមហ៊ុនចុះបញ្ជីនោះ (Price × N. of listed shares) ។

តាមទិន្នន័យដូចដែលបានបង្ហាញខាងលើ ឃើញថាទំហំមូលធនូនីយកម្មរបស់ក្រុមហ៊ុននីមួយៗមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ និងជារួមគឺមានទំនោរកើនឡើង ប៉ុន្តែក្នុងចំណោមក្រុមហ៊ុនទាំងអស់មានតែ**ក្រុមហ៊ុនកំពង់ផែស្វយ័តក្រុងព្រះសីហនុ** ប៉ុណ្ណោះ ដែលមានការប្រែប្រួលកើនឡើងខ្លាំងចន្លោះចាប់ពីឆ្នាំ ២០១៧ ដល់ ឆ្នាំ២០១៩ ពិសេសក្នុងឆ្នាំ២០១៩ដែលកើនឡើងគួរអោយកត់សម្គាល់។ ដោយសារតែថ្លៃភាគហ៊ុនរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ(PAS) មានការកើនឡើង ពិសេសកំឡុងឆ្នាំ ២០១៨-២០១៩ ទើបធ្វើឲ្យ Market Cap. របស់ PAS មានការកើនឡើងដែរ។ ហេតុផលផ្សេងៗ ដែលជាកត្តាធ្វើអោយ តម្លៃភាគហ៊ុនរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ(PAS) មានការកើនឡើងខ្លាំងនោះ បណ្តាលមកពី ការកំណត់គោលនយោបាយភាគលាភអំណោយផលដល់វិនិយោគិន ជាផែអន្តរជាតិសមុទ្រទឹកជ្រៅតែមួយគត់នៅកម្ពុជា ជាក្រុមហ៊ុនផ្តល់សេវាកម្មអាហារ័ណ និហារ័ណលើទំនិញគ្រប់ប្រភេទ និងសេវាជាច្រើនទៀតដូចជា ផ្តល់ភស្តុភារ

ដល់នាវា, ស្តុកទំនិញនៅឃ្លាំង, សេវាក្នុងតំបន់សេដ្ឋកិច្ចពិសេស ដូចជាជួលឃ្លាំង និងថែរក្សាទំនិញ រួមទាំងសេវាសន្តិសុខកំពង់ផែ និងតំបន់សេដ្ឋកិច្ចពិសេស។ PAS ជាមធ្យោបាយដឹកជញ្ជូនដែលមានប្រសិទ្ធភាពចំណាយទាប បើប្រៀបធៀបទៅនឹងមធ្យោបាយដឹកជញ្ជូនផ្សេងទៀត។ ដោយសារ PAS ស្ថិតនៅលើទីតាំងអំណោយផល អាចធ្វើការដឹកជញ្ជូនដោយផ្ទាល់ ជាមួយនឹងកំពង់ផែនានាលើពិភពលោក និងមានភ្ជាប់បណ្តាញដឹកជញ្ជូនចំរុះ (រថភ្លើង ពីខេត្តកំពត និងរាជធានីភ្នំពេញ, ផ្លូវអាកាសខេត្តសៀមរាប) ដែលសុទ្ធសឹងជាកត្តាសក្តានុពលវិនិយោគ។ ហេតុនេះហើយទើបធ្វើអោយ PAS ទទួលបានវិនិយោគិនច្រើនលើភាគហ៊ុនរបស់ខ្លួន។ កត្តាទាំងនេះដែលធ្វើឡើងឲ្យកំពង់ផែស្វយ័តក្រុងព្រះសីហនុ នៅឆ្នាំ២០១៨-២០១៩ មានការកើនឡើងនូវតម្លៃភាគហ៊ុន និងទំហំមូលធនូបនីយកម្ម (Market Cap.)។

តាមការវិភាគខាងលើ យើងអាចទាញសេចក្តីសន្និដ្ឋានបានថា ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រទាំងអស់គឺជាតួអង្គសម្ខាន់មួយសម្រាប់ដំណើរការទីផ្សារមូលបត្រនៅកម្ពុជា ហើយជារួម បើយើងមើលការវិភាគទិន្នន័យ និងក្រាហ្វិកខាងលើរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រនីមួយៗ ពីឆ្នាំ២០១៥-២០១៩ មានក្រុមហ៊ុនភាគច្រើន ទំហំមូលធនូបនីយកម្មមានការកើនឡើង និងមានក្រុមហ៊ុនភាគតិច ទំហំមូលធនូបនីយកម្មមានការធ្លាក់ចុះផងដែរ។ យើងសន្និដ្ឋានបានថា តម្លៃភាគហ៊ុនសរុបក្នុងទីផ្សាររបស់ក្រុមហ៊ុនចុះបញ្ជីមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំពិតមែន ប៉ុន្តែជារួមគឺមានការកើនឡើងច្រើនជាងការធ្លាក់ចុះ។ ដូចនេះទោះបីក្រុមហ៊ុនខ្លះមានទំហំមូលធនូបនីយកម្មធ្លាក់ចុះ តែភាគច្រើនមានទំហំមូលធនូបនីយកម្មកើនឡើង ទាំងចំនួនទឹកប្រាក់ ដំណើរការនៃការបោះផ្សាយ និងការលក់មូលបត្រ ដែលធ្វើឱ្យការជួញដូរមានភាពរីកចម្រើនជាលំដាប់ និងទូលំទូលាយពីមួយឆ្នាំទៅមួយឆ្នាំ ដែលជាកត្តាមួយឆ្ពោះទៅរកកាលានុវត្តភាពទីផ្សារមូលបត្រ-កម្ពុជាពិតប្រាកដ។

**វិភាគពីចំណុចខ្លាំង និង ចំណុចខ្សោយរបស់ទីផ្សារមូលបត្រកម្ពុជា៖**

❖ **ចំណុចខ្លាំង**

- ក្រុមហ៊ុនដែលបានចុះបញ្ជី សុទ្ធសឹងជាក្រុមហ៊ុនដែលមានស្ថានភាពហិរញ្ញវត្ថុរឹងមាំ និងមានតម្លាភាពដែលជាមូលដ្ឋានគ្រឹះទ្រទ្រង់ទីផ្សារ
- ច្បាប់ និងបទប្បញ្ញត្តិនានាមានលក្ខណៈរឹងមាំ ដើម្បីគ្រប់គ្រង និងការពារហានិភ័យផ្សេងៗ ដែលអាចកើតមានឡើង នៅក្នុងវិស័យមូលបត្រ
- គណៈកម្មការមូលបត្រកម្ពុជាបានធ្វើការកែតម្រូវលើលក្ខខណ្ឌមួយចំនួនដើម្បីផ្តល់ឱកាសដល់សហ-គ្រាសធុនតូច និងមធ្យមមានលទ្ធភាពអាចចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជាបាន ដើម្បីស្វែងរកហិរញ្ញប្បទាន

រយៈពេលវែង សម្រាប់ការពង្រីកសកម្មភាពដំណើរការអាជីវកម្មរបស់ខ្លួន

- គណៈកម្មការមូលបត្រកម្ពុជា បានបង្កើតវគ្គបណ្ដុះបណ្ដាល សិក្ខាសាលាទាក់ទិននឹងមូលបត្រ និង ជំរុញការពង្រីកចំណេះដឹង តាមរយៈការចេញផ្សាយនូវសៀវភៅ ព័ត៌មានតាមប្រពន្ធ័គេហទំព័ររបស់ គណៈកម្មការមូលបត្រកម្ពុជា ដើម្បីជួយបន្ថែមការយល់ដឹងដល់សាធារណៈជន
- មានប្រព័ន្ធជួញដូរមួយច្បាស់លាស់(MTS) ដែលអាចធានាសុវត្ថិភាព និងទំនុកចិត្តក្នុងការជួញដូរ។

❖ **ចំណុចខ្សោយ**

- ជម្រើសក្នុងការវិនិយោគនៅមានចំនួនតិចនៅឡើយ ហើយទំហំនៃការជួញដូរមានការថយចុះ
- ដំណើរការក្នុងការចុះបញ្ជីមានភាពស្មុកស្មាញ ចំណាយពេលវេលាយូរ និងថវិកាច្រើន
- នីតិវិធីក្នុងការចុះឈ្មោះជាវិនិយោគិន មិនទាន់មានភាពងាយស្រួលនៅឡើយ ដោយអ្នកដែលចង់ចុះ ឈ្មោះត្រូវមកកាន់ក្រុមហ៊ុនមូលបត្រផ្ទាល់ ទោះបីនៅតាមបណ្ដាខេត្តក៏ដោយ។

# សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

## ១. សេចក្ដីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ និងចុះកម្មសិក្សានៅគណៈកម្មការមូលបត្រកម្ពុជាអស់រយៈពេលពីរខែកន្លងមកក្រុមយើងខ្ញុំយល់ឃើញថា ផលលំបាក និងបញ្ហាប្រឈមមួយចំនួនរបស់ទីផ្សារមូលបត្រដែលកំពុងជួបប្រទះត្រូវបានដោះស្រាយជាបណ្ដើរៗ តាមរយៈការត្រួតពិនិត្យ គ្រប់គ្រង និងសម្របសម្រួលពីសំណាក់ គ.ម.ក.ដែលប្រៀបបាននឹងអាណាព្យាបាលរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា(ផ.ម.ក.) ទើបក្រុមហ៊ុននេះអាចដំណើរការបានយ៉ាងរលូននៅឆ្នាំ២០១២ ដោយមានការចុះបញ្ជីបោះផ្សាយ និងជួយដូរមូលបត្ររបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។ ទោះបីជានៅចុងឆ្នាំ២០១៩ ដែលពិភពលោកបានជួបប្រទះនូវវិបត្តិបញ្ហាជម្ងឺកូវីណា (Covid-19) ក៏ពិតមែនដែលវាមិនមែនជាបញ្ហាប្រឈមក៏ធ្ងន់ធ្ងរនោះទេ ចំពោះប្រទេសកម្ពុជាយើង ពីព្រោះ វិបត្តិជម្ងឺនេះធ្វើឱ្យសកម្មភាពជួញដូរមូលបត្រនៅលើទីផ្សារមានភាពយឺតជាងពេលធម្មតា តែនៅមានសកម្មភាពរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី(Acleda Bank Plc.) បានចូលរួមបោះផ្សាយលក់មូលបត្រកម្មសិទ្ធិផងដែរ។ បើយើងក្រឡេកមើលពីមូលធនូបនីយកម្មទីផ្សារ (Market Cap.) របស់ក្រុមហ៊ុននីមួយៗមានការកើនឡើង លើកលែងតែភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (PPSP) មានការធ្លាក់ចុះបន្តិចបន្តួច។

ជាលទ្ធផលនៃការស្រាវជ្រាវចំណោទបញ្ហា ដែលចោទទៅលើក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចំពោះទំនុកចិត្ត និងការយល់ដឹងរបស់ប្រជាពលរដ្ឋកម្ពុជា និងវិនិយោគិនថ្មីត្រូវបានដោះស្រាយពីមួយជំហានទៅមួយជំហាន។ រីឯកាលានុវត្តភាពនៅក្នុងទីផ្សារមូលបត្រ ពិតជាមានអត្ថប្រយោជន៍ដល់វិនិយោគិន ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ និងសេដ្ឋកិច្ចនៅប្រទេសកម្ពុជា។ តាមការសិក្សាស្រាវជ្រាវ និងធ្វើការវិភាគរួចមកអាចវាយតម្លៃបានថា កាលានុវត្តភាពទីផ្សារមូលបត្រកម្ពុជា មានអានុភាព និងឥទ្ធិពលច្រើនជាង បញ្ហាប្រឈម ទោះបីទីផ្សារមូលបត្រកម្ពុជាមិនទាន់មានការរីកចម្រើនដូចប្រទេសអភិវឌ្ឍន៍មួយចំនួនយ៉ាងណាក្ដី។ រាជរដ្ឋាភិបាលបានយកចិត្តទុកយ៉ាងខ្លាំងក្នុងវិស័យមូលបត្រ ដោយបានបង្កើតនៅ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ-ហិរញ្ញវត្ថុ ឆ្នាំ២០១៦-២០២៥ និង អនុក្រឹត្យស្ដីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ។ល។ ទោះបីយើងឃើញថាវិស័យនេះកំពុងដំណើរការបានល្អប្រសើរក៏ពិតមែន តែវាក៏មានបញ្ហាប្រឈមមួយចំនួនដែលយើងត្រូវជួបប្រទះ ហើយត្រូវតែខិតខំរកវិធីសាស្ត្រ និងរៀបចំយុទ្ធសាស្ត្រក្នុងការដោះស្រាយបញ្ហាទាំងអស់នេះ។

សរុបសេចក្ដីមក តាមរយៈការស្រាវជ្រាវមក គណៈកម្មការមូលបត្រ មានតួនាទី និងភារកិច្ចដាក់ឲ្យអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រសំខាន់ៗពាក់ព័ន្ធនឹងវិស័យមូលបត្រសម្រាប់ដំណើរការ និងអភិវឌ្ឍន៍ទីផ្សារមូលបត្រកម្ពុជា។ ចំណែកទីផ្សារមូលបត្រជាកន្លែងផ្ដល់ការជួញដូរមូលបត្រ សំរាប់អ្នកលក់ និងអ្នកទិញ

បានជួបគ្នាដោះដូរ ឬវិនិយោគមូលបត្រដើម្បីទទួលបានផលចំណេញដែលផ្តល់នូវទីកន្លែង និងប្រព័ន្ធជួញដូរដ៏ប្រសើរ។

## ២. ការផ្តល់អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះរួចមកឃើញថាទីផ្សារមូលបត្រកម្ពុជាមានចំណុចខ្វះខាតមួយចំនួនដែលរាំងស្ទះដល់ដំណើរប្រព្រឹត្តទៅនៃទីផ្សារ។ ហេតុដូច្នេះហើយក្រុមយើងខ្ញុំសូមផ្តល់ជាអនុសាសន៍មួយចំនួនដើម្បីចូលរួមចំណែកក្នុងការកែលម្អ និងអភិវឌ្ឍន៍ទីផ្សារ។ មតិយោបល់ទាំងនេះមានដូចខាងក្រោម៖

- គណៈកម្មការមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា គួរមានការកែសម្រួលលើវិធីសាស្ត្រនៃការចុះបញ្ជីរបស់ក្រុមហ៊ុនបោះផ្សាយឱ្យមានភាពងាយស្រួលជាងមុន ដើម្បីកាត់បន្ថយពេលវេលា និងថវិការបស់ក្រុមហ៊ុននីមួយៗ។
- គណៈកម្មការមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវបង្កើនឲ្យមានបណ្តុះបណ្តាលពីវិស័យមូលបត្រឲ្យបានច្រើន តាមស្ថាប័នអប់រំ និងការងារ នៅក្នុងរាជធានីភ្នំពេញ ជាពិសេសតាមបណ្តាខេត្តនានា ដើម្បីបង្កើនការយល់ដឹងនិងភាពជឿជាក់មកលើផ្សារមូលបត្រ។
- គណៈកម្មការមូលបត្រកម្ពុជា គួរបង្កើនការផ្សព្វផ្សាយអំពីវិស័យមូលបត្រឲ្យបានកាន់តែច្រើន និងទូលំទូលាយជាងមុនបន្ថែមទៀតតាមរយៈ ប្រព័ន្ធផ្សព្វផ្សាយនានា ដូចជា ទូរទស្សន៍ វិទ្យុ ទស្សនាវដ្តី កាសែត និងគេហទំព័រ ដើម្បីឲ្យសាធារណជនបានជ្រាបកាន់តែច្បាស់លាស់លើវិស័យនេះ។
- លើកទឹកចិត្តបន្ថែមទៀត ចំពោះសហគ្រាស ឬក្រុមហ៊ុនដែលមានសក្តានុពល ឲ្យចូលរួមក្នុងទីផ្សារមូលបត្រតាមរយៈការដាក់ចេញនូវគោលនយោបាយ និងលក្ខខណ្ឌដែលទទួលបានផលចំណេញដ៏ល្អប្រសើរសម្រាប់ពួកគេ។
- ដោយសារតែក្រុមហ៊ុនមួយចំនួនគិតថា ការចូលខ្លួនក្នុងវិស័យមូលបត្រមាន នីតិវិធីចុះបញ្ជីច្រើន ចំណាយទុនច្រើន និងចំណាយពេលច្រើន ហើយត្រូវរៀបចំខ្លួនចូលក្នុងវិស័យនេះមានរយៈពេលយូរ ដូចនេះរាជរដ្ឋាភិបាលកម្ពុជាគួរតែធ្វើការបន្ធូរបន្ថយនូវអនុលោមភាពមួយចំនួន ថែមទាំងពង្រឹងការផ្សព្វផ្សាយពីច្បាប់ និងបទប្បញ្ញត្តិទាំងនោះទៅដល់វិនិយោគិនឲ្យបានច្បាស់លាស់ ដើម្បីជាភាពងាយស្រួលដល់ការបោះផ្សាយមូលបត្រ។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- ច្បាប់ស្តីពី ការបោះផ្សាយ និងជួញដូរមូលបត្រមហាជន.២០០៧ (ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១០០៧/០២៨ ចុះនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧)
- ច្បាប់ស្តីពីមូលបត្ររដ្ឋ ដែលបានអនុម័តដោយរដ្ឋសភា (ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះនៅថ្ងៃទី១០ ខែមករា ឆ្នាំ ២០០៧)
- អនុក្រឹត្យ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ (ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩)។

## ២. សៀវភៅ និងអត្ថបទស្រាវជ្រាវ


- សៀវភៅ "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១៦-២០២៥" រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ២០១៦
- Frederic S.Miskin and Stanley G.Eakins សៀវភៅ "ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ (Financial Market and Institution) " ,9th Edition 2018, Bond Market ទំព័រ ៣០៨-៣២៩, Stock Market ទំព័រ ៣៣៣-៣៥០
- ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគ ប្រចាំត្រីមាសទី១ ចេញផ្សាយលេខទី១ ដោយនាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ឆ្នាំ២០២០
- ព្រឹត្តិបត្រមូលបត្រ ចេញផ្សាយលេខ៣ ដោយគណៈកម្មការមូលបត្រកម្ពុជា ឆ្នាំ២០១៨
- ព្រឹត្តិបត្រទិន្នន័យជួញដូរមូលបត្រ ប្រចាំត្រីមាសទី៤ ដោយនាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ឆ្នាំ២០១៩
- ពុទ្ធិមូលបត្រ៖ ទិដ្ឋភាពទូទៅនៃទីផ្សារមូលបត្រកម្ពុជាគិតត្រឹមឆ្នាំ២០១៩ លេខ៤៥ ចេញផ្សាយឆ្នាំ២០២០
- លោក បៀន សាំង សៀវភៅ "មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ" បោះពុម្ពលើកទី១ ឆ្នាំ២០១១
- របាយការណ៍សមិទ្ធផលការងារ ឆ្នាំ២០១២-២០១៧ ដោយគណៈកម្មការមូលបត្រកម្ពុជា
- មគ្គុទេសក៍ ស្តីពីការស្វែងយល់ពីហិរញ្ញប្បទានតាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ(ភាគហ៊ុន) ជាសាធារណៈ នៅព្រះរាជាណាចក្រកម្ពុជា ដោយគណៈកម្មការមូលបត្រកម្ពុជា ចេញផ្សាយឆ្នាំ២០១៧

- របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា “ការជួញដូរមូលបត្រនៅផ្សារមូលបត្រកម្ពុជា” របស់និស្សិតឈ្មោះ គឹម ច័ន្ទសុវណ្ណលក្ខណា នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ២០១៧
- សារណាបញ្ចប់ការសិក្សា “ដំណើរការជួញដូរមូលបត្រលើទីផ្សារមូលបត្រកម្ពុជា” របស់និស្សិតឈ្មោះ លឹម វិភា នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ ២០១៨។

### ៣. គេហទំព័រ

- គណៈកម្មការមូលបត្រកម្ពុជា http://www.secc.gov.kh/khmer (ចូលមើលថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០)
- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា http://www.csx.gov.kh/khmer (ចូលមើលថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០)
- https://www.thebalance.com/what-are-securities (ចូលមើលថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០)
- https://ebrary.net/13353/business_finance/securities_firms (ចូលមើលថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០)
- https://www.nbc.org.kh/monetary_policy/ncds_overview.php (ចូលមើលថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២០)
- https://m.phnompenhpost.com/business/cambodia-securities-exchange-trading-record-numbers-year (ចូលមើលថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០)
- STOCKINFO 2018-KH ក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាhttp://www.csx.gov.kh/khmer (ចូលមើលថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០)
- STOCKINFO 2019-KH ក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាhttp://www.csx.gov.kh/khmer (ចូលមើលថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០)

# ឧបសម្ព័ន្ធទី ១
# ច្បាប់ស្តីពីការបោះផ្សាយ
# និង ការជួញដូរ
# មូលបត្រមហាជន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្តីពី

# ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឆ្នាំ ២០០៧

# ព្រះរាជក្រម

នស/រកម/០១០៧/០២៨

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភានីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភា ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### មាត្រា ១.- គោលដៅ

ច្បាប់នេះមានគោលដៅគ្រប់គ្រងទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់ ប្រតិបត្តិកររក្សាទុកមូលបត្រ និងប្រតិបត្តិករដទៃទៀតនៅក្នុងទីផ្សារមូលបត្រដែលធ្វើការជួញដូរ ឬផ្ដល់សេវាកម្មហិរញ្ញវត្ថុ ព្រមទាំងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតដែលបោះផ្សាយលក់មូលបត្រ។ ច្បាប់នេះរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គម តាមរយៈការកៀរគរមូលធនពីសាធារណជន ឬអ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុ សម្រាប់ការវិនិយោគ។

### មាត្រា ២.- គោលបំណង

ច្បាប់នេះមានគោលបំណង :

១-បង្កើត និងរក្សាឱ្យមានទំនុកចិត្តពីអ្នកវិនិយោគ នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការការពារសិទ្ធិស្របច្បាប់របស់អ្នកវិនិយោគ និងធានាឱ្យមានការបោះផ្សាយ និងការជួញដូរមូលបត្រប្រកបដោយសណ្ដាប់ធ្នាប់ និងត្រឹមត្រូវ។

២-លើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រឱ្យមានប្រសិទ្ធភាព និងជម្រុញការអភិវឌ្ឍទីផ្សារនេះឱ្យមានសណ្ដាប់ធ្នាប់ និងរបៀបរៀបរយ។

៣-ជម្រុញឱ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ជ័យ តាមរយៈការទិញមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត។

៤-ជំរុញឱ្យមានការធ្វើវិនិយោគទុនពីបរទេស និងការចូលរួមក្នុងទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៥-ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្ម សហគ្រាសសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## មាត្រា ៣.- វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រតិបត្តិការមូលបត្រមហាជននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## មាត្រា ៤.- និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងច្បាប់នេះត្រូវបានកំណត់ដោយសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

# ជំពូកទី ២
# គណៈកម្មការមូលបត្រកម្ពុជា

## មាត្រា ៥.- អាណត្តិរបស់គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា **គ.ម.ក.**) ត្រូវបានបង្កើតឡើងដោយច្បាប់នេះ ដែលមានប្រធាន ១(មួយ)រូប និងសមាជិកចំនួន ៨(ប្រាំបី)រូប ដែលតែងតាំងដោយអនុក្រឹត្យ។ សមាជិករបស់ **គ.ម.ក.** មានអាណត្តិ ៥(ប្រាំ)ឆ្នាំ។ ក្នុងរយៈពេលនៃការបំពេញមុខងាររបស់ខ្លួន សមាជិកអាចត្រូវបានដកហូត ឬផ្លាស់ប្តូរភារកិច្ច។ សមាជិក **គ.ម.ក.** អាចត្រូវបានតែងតាំងសារជាថ្មីទៀតបាន តាមសំណើរបស់ប្រធាន **គ.ម.ក.** នៅពេលផុតអាណត្តិ។

## មាត្រា ៦.- សមាសភាពរបស់គណៈកម្មការមូលបត្រកម្ពុជា

ប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា ជារដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សមាសភាពរបស់ **គ.ម.ក.** មាន :

| | | |
|---|---|---|
| ១- | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១ (មួយ)រូប |
| ២- | តំណាងធនាគារជាតិនៃកម្ពុជា | ០១ (មួយ)រូប |
| ៣- | តំណាងក្រសួងពាណិជ្ជកម្ម | ០១ (មួយ)រូប |

៤- តំណាងក្រសួងយុត្តិធម៌ ០១ (មួយ)រូប

៥- តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី ០១ (មួយ)រូប

៦- អគ្គនាយក **គ.ម.ក.** ០១ (មួយ)រូប

៧- អ្នកជំនាញដែលមានបទពិសោធន៍វិស័យមូលបត្រ ០២(ពីរ)រូប ដែលមានស្ថានភាពអព្យាក្រឹត្យ ព្រមទាំងជ្រើសរើស និងស្នើឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បេក្ខភាពរបស់អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ត្រូវជ្រើសរើស និងស្នើឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជូនប្រមុខរាជរដ្ឋាភិបាល។ សមាជិកនៃ **គ.ម.ក.** ដែលជាអ្នកជំនាញ ត្រូវមានសញ្ញាបត្រថ្នាក់ក្រោយឧត្តមសិក្សា មានសមត្ថភាព និងលក្ខណសម្បត្តិគ្រប់គ្រាន់ និង សមស្របក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនព្រមទាំងមានបទពិសោធន៍មួយ ឬ ច្រើនផ្នែក ដូចជាពាណិជ្ជកម្មគ្រប់គ្រងក្រុមហ៊ុនទីផ្សារមូលបត្រ ច្បាប់ សេដ្ឋកិច្ច គណនេយ្យ និងផ្នែកផ្សេងទៀតតាមតម្រូវការជាក់ស្តែង។

**មាត្រា ៧.- មុខងាររបស់គណៈកម្មការមូលបត្រកម្ពុជា**

គណៈកម្មការមូលបត្រកម្ពុជា មានមុខងារដូចខាងក្រោម :

១-គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជារួមទាំងទីផ្សារមូលបត្ររដ្ឋ។

២-ដាក់ឱ្យអនុវត្តនូវគោលនយោបាយ ដែលពាក់ព័ន្ធនឹងទីផ្សារមូលបត្រ។

៣-កំណត់លក្ខខណ្ឌ ដើម្បីផ្តល់ការអនុញ្ញាត ជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ។

៤-កំណត់លក្ខខណ្ឌដើម្បីផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនមូលបត្រ និង ភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ។

៥-លើកកម្ពស់ និងជម្រុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់នេះ។

៦-ដើរតួជាស្ថាប័នពិនិត្យ និងដោះស្រាយលើការតវ៉ាចំពោះសេចក្តីសម្រេចរបស់

នីតិបុគ្គលមានអាជ្ញាប័ណ្ណ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សមាជិកអ្នកចូលរួម ឬអ្នកវិនិយោគ។

៧-ពិគ្រោះយោបល់ជាមួយបុគ្គល ដែលមានលក្ខណសម្បត្តិសមស្រប ដើម្បីបង្កើតគោលនយោបាយសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៨-បំពេញការងារផ្សេងទៀតដែលមានចែងនៅក្នុងអនុក្រឹត្យ។

**មាត្រា ៨.- មុខងាររបស់អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា**

អគ្គនាយកនៃ **គ.ម.ក.** មានមុខងារដូចខាងក្រោម :

១-គ្រប់គ្រងបុគ្គលិក និងមន្ត្រីជំនាញដែលទទួលបន្ទុកសម្របសម្រួលកិច្ចការរដ្ឋបាលរបស់ **គ.ម.ក.** ក្នុងការគ្រប់គ្រងការអភិវឌ្ឍ និងការត្រួតពិនិត្យទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២-រាយការណ៍និងផ្តល់អនុសាសន៍ជូនប្រធាននិងសមាជិកទាំងអស់នៃ **គ.ម.ក.** នូវរាល់បញ្ហាទាំងអស់ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការអភិវឌ្ឍ និងការត្រួតពិនិត្យទីផ្សារមូល-បត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងការលើកសំណើសុំធ្វើវិសោធនកម្មច្បាប់ និងបទ-ប្បញ្ញត្តិផ្សេងៗ។

៣-ពិនិត្យសំណុំឯកសារ ដែលស្នើសុំធ្វើសំណើលក់មូលបត្រជាសាធារណៈ និងផ្តល់ការអនុញ្ញាតលើពាក្យស្នើសុំដែលបានបំពេញតាមលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

៤-ពិនិត្យឯកសារផ្តល់ព័ត៌មាន ដែលទាក់ទងនឹងសំណើដាក់លក់មូលបត្រមហាជនដែលដាក់មក **គ.ម.ក.** ដើម្បីធានានូវការគោរពតាមលក្ខខណ្ឌនៃច្បាប់នេះ និងបញ្ញត្តិនានានៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដោយផ្តល់ការអនុញ្ញាត និងចុះបញ្ជីឯកសារដែលបំពេញតាមលក្ខខណ្ឌត្រឹមត្រូវ។

៥-ត្រួតពិនិត្យឯកសារផ្តល់ព័ត៌មានជាប្រចាំ ដែលផ្តល់ជូនទីផ្សារមូលបត្រនូវ

ព័ត៌មានហិរញ្ញវត្ថុ ព័ត៌មានមិនមែនហិរញ្ញវត្ថុ និងព័ត៌មានផ្សេងទៀតរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងនីតិបុគ្គលប្រតិស្រុត ដែលបោះផ្សាយលក់មូលបត្រជូនអ្នកវិនិយោគសាធារណៈ។

៦-ត្រួតពិនិត្យការអនុវត្តច្បាប់របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងនីតិបុគ្គលប្រតិស្រុត ដែលបោះផ្សាយលក់មូលបត្រជូនអ្នកវិនិយោគសាធារណៈ ដោយគោរពតាមលក្ខខណ្ឌទាំងឡាយដែលច្បាប់តម្រូវ និងចាត់វិធានការអនុវត្តសមស្របណាមួយ ចំពោះអំពើល្មើសនឹងច្បាប់នេះ។

៧-ទាក់ទងនឹងទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់ និងសេវារក្សាទុកមូលបត្រ អគ្គនាយក **គ.ម.ក.** ត្រូវ ៖

ក-ពិនិត្យ និងពិនិត្យឡើងវិញលើពាក្យស្នើសុំអាជ្ញាប័ណ្ណ និងផ្តល់ការអនុញ្ញាត នៅពេលដែលអ្នកស្នើសុំបំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ និងលក្ខខណ្ឌផ្សេងទៀតដែល **គ.ម.ក.** បានកំណត់។

ខ-ពិនិត្យ និងពិនិត្យឡើងវិញ និងផ្តល់ការអនុញ្ញាតឱ្យធ្វើការកែប្រែលើវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់ និងសេវារក្សាទុកមូលបត្រ ដែលទទួលបានការអនុញ្ញាត។

គ-ត្រួតពិនិត្យសកម្មភាពរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រដើម្បីធានាការគោរពតាមលក្ខខណ្ឌនៃការផ្តល់ការអនុញ្ញាត និងលក្ខខណ្ឌនៃច្បាប់នេះ និងលក្ខខណ្ឌផ្សេងទៀតដែល **គ.ម.ក.** បានកំណត់។

ឃ-ធ្វើការស៊ើបអង្កេតករណីសង្ស័យ ចំពោះអំពើល្មើសរបស់បុគ្គលដែលទទួលបានការអនុញ្ញាតទៅនឹងលក្ខខណ្ឌនៃការផ្តល់ការអនុញ្ញាត ឬ លក្ខខណ្ឌដែលច្បាប់តម្រូវ និងចាត់វិធានការអនុវត្តសមស្របណាមួយរួមមានការព្យួរ ឬការដកហូតការអនុញ្ញាត។

ង-មុនផ្តល់ការអនុញ្ញាត ឬដកហូតការអនុញ្ញាត អគ្គនាយកត្រូវសុំការ

ពិគ្រោះយោបល់ ពីការប្រជុំពេញអង្គរបស់ **គ.ម.គ.**។

៨-ទាក់ទងនឹងក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ អគ្គនាយក នៃ **គ.ម.គ.** ត្រូវ :

ក-ពិនិត្យពាក្យស្នើសុំអាជ្ញាប័ណ្ណ និងផ្តល់អាជ្ញាប័ណ្ណ ប្រសិនបើអ្នកស្នើសុំបានបំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ និងលក្ខខណ្ឌផ្សេងទៀតដែល **គ.ម.គ.** បានកំណត់។

ខ-ត្រួតពិនិត្យសកម្មភាពរបស់អ្នកកាន់អាជ្ញាប័ណ្ណ ក្នុងការគោរពតាមលក្ខខណ្ឌនៃអាជ្ញាប័ណ្ណ រួមទាំងលក្ខខណ្ឌហិរញ្ញវត្ថុ។

គ-ត្រួតពិនិត្យការគោរពតាមលក្ខខណ្ឌ នៃអាជីវកម្មដែលកំណត់ក្នុងច្បាប់នេះ និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

ឃ-ពិនិត្យដើម្បីផ្តល់ការអនុញ្ញាត ចំពោះការស្នើសុំឱ្យក្លាយទៅជាស្វ័យនិយ័តករចំពោះពាណិជ្ជករមូលបត្រ ឬទីប្រឹក្សាវិនិយោគ ប្រសិនបើអ្នកស្នើសុំនោះបានគោរពតាមលក្ខខណ្ឌដែលបានកំណត់។

ង-ត្រួតពិនិត្យការអនុវត្តតាមលក្ខខណ្ឌ នៃច្បាប់របស់ស្វ័យនិយ័តករដែលបានការអនុញ្ញាត។

ច-ធ្វើការស៊ើបអង្កេតករណីសង្ស័យ ចំពោះអំពើល្មើសនឹងលក្ខខណ្ឌនៃអាជ្ញាប័ណ្ណ ឬនៃការអនុញ្ញាត ឬអំពើល្មើសនឹងលក្ខខណ្ឌនៃច្បាប់នេះរបស់អ្នកកាន់អាជ្ញាប័ណ្ណ និងចាត់វិធានការអនុវត្តសមស្របណាមួយ ដូចជា ព្យួរ ឬដកហូតអាជ្ញាប័ណ្ណ ឬការអនុញ្ញាត។

៩-ចាត់រាល់វិធានការសមស្រប ដែលច្បាប់នេះអនុញ្ញាតដើម្បីអង្កេតស្វែងរក និងបង្ក្រាបអាជីវកម្មខុសច្បាប់ ផ្ទុយនឹងក្រមសីលធម៌ និងអំពើមិនសមស្រប ដែលពាក់ព័ន្ធនឹងអាជីវកម្មមូលបត្រ។

**មាត្រា ៩.- សិទ្ធិអំណាចរបស់អគ្គនាយកក្នុងការគ្រប់គ្រង គ.ម.គ**

ក្នុងគោលបំណងអនុវត្តតាមមុខងារដែលមានចែងក្នុងច្បាប់នេះ អគ្គនាយកនៃ **គ.ម.គ.** មានសិទ្ធិអំណាចដូចខាងក្រោម :

១-ផ្តល់សិទ្ធអំណាចទៅបុគ្គលិករបស់ **គ.ម.ក.** ឬផ្តល់សិទ្ធអំណាចទៅបុគ្គលផ្សេងទៀត ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមុន។

២-ក្នុងករណីអគ្គនាយកនៃ **គ.ម.ក.** មានមូលហេតុត្រឹមត្រូវ ហើយជឿជាក់ថា បទល្មើសត្រូវបានប្រព្រឹត្តនៅក្រោមច្បាប់នេះ អគ្គនាយកនៃ **គ.ម.ក.** អាចសម្រេចឱ្យបុគ្គលិករបស់ខ្លួនធ្វើការស៊ើបអង្កេតលើ :

ក-បុគ្គលដែលទទួលបានអាជ្ញាប័ណ្ណ ឬ ទទួលបានការអនុញ្ញាត។

ខ-បុគ្គលដែលធ្វើសំណើលក់មូលបត្រជាសាធារណៈ។

គ-ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានមូលបត្រដាក់លក់ ឬ ដាក់តម្លៃនៅក្នុងទីផ្សារមូលបត្រ។

ឃ-បុគ្គលផ្សេងទៀតតាមការជាក់ស្តែង។

៣-ប្រមូលភស្តុតាងពីបុគ្គលដែលស្ថិតក្រោមការស៊ើបអង្កេត។

៤-រាយការណ៍ជាបន្ទាន់អំពីលទ្ធផលនៃការស៊ើបអង្កេតជូនប្រធាន និងសមាជិកទាំងអស់នៃ **គ.ម.ក.** ដោយភ្ជាប់មកជាមួយនូវអនុសាសន៍ ដើម្បីចាត់វិធានការអនុវត្តបន្ត។

៥-បញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីធ្វើការចោទប្រកាន់ពីបទល្មើស។

៦-ធ្វើការអង្កេតលើរាល់សកម្មភាពទីផ្សារមូលបត្រប្រតិស្រុត។

៧-ផ្សព្វផ្សាយឈ្មោះ និងសកម្មភាពរបស់បុគ្គលដែលមានពិរុទ្ធភាពពីបទល្មើសដែលមានចែងក្នុងច្បាប់នេះ ឬ ដែលទទួលទណ្ឌកម្មខាងវិន័យពី **គ.ម.ក.**។

៨-ដកហូត ឬលុបអាជ្ញាប័ណ្ណ ការអនុញ្ញាត ឬការចុះបញ្ជីដែលបានផ្តល់ឱ្យ។

៩-សិទ្ធិមួយចំនួនទៀតស្របតាមមាត្រា ៤៥ នៃច្បាប់នេះ។

**មាត្រា ១០.- សិទ្ធិពិសេសរបស់ គ.ម.ក.**

មន្ត្រីរបស់ **គ.ម.ក.** ទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មានមុខងារដូចមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌស្តីពីមុខងាររបស់នគរបាលយុត្តិធម៌។



**មាត្រា ១១.- ការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ម.ក.**

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា ត្រូវកំណត់ដោយអនុក្រឹត្យ។ **គ.ម.ក.** ត្រូវមានថវិកាសម្រាប់ចំណាយផ្ទាល់ខ្លួនដាច់ដោយឡែក។

# ឧបសម្ព័ន្ធទី ២
# ច្បាប់ស្ដីមូលបត្ររដ្ឋ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្តីពី

# មូលបត្ររដ្ឋ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឆ្នាំ ២០០៧

# ព្រះរាជក្រម

# យើង

នស/រកម/០១០៧/០០១

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សម្ពហោគាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីមូលបត្ររដ្ឋ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី២ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងផ្តល់នូវក្របខ័ណ្ឌមួយសម្រាប់ការបោះផ្សាយ និង ការគ្រប់គ្រងមូលបត្ររដ្ឋប្រកបដោយប្រសិទ្ធភាព ដើម្បីធានាថាកាតព្វកិច្ចទូទាត់សងចំពោះតម្រូវការហិរញ្ញប្បទានរបស់រដ្ឋ ត្រូវចំណាយក្នុងតម្លៃមួយដែលទាបបំផុត សម្រាប់មូលបត្ររយៈពេលមធ្យម ឬ វែង ហើយត្រូវសមស្របទៅតាមកម្រិតហានិភ័យដែលអាចកើតមានឡើង និង ដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍ទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងច្បាប់នេះ មានដូចខាងក្រោម :

**១-មូលបត្ររដ្ឋ** សំដៅដល់ប័ណ្ណ សញ្ញាប័ណ្ណ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀតដែលបញ្ជាក់ពីការទទួលស្គាល់បំណុល ដែលបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាលនៅក្រោមច្បាប់នេះ រួមមាន:

ក-ប័ណ្ណរតនាគារដែលមានឥណប្រតិទានតិចជាងមួយឆ្នាំ។

ខ-សញ្ញាប័ណ្ណរតនាគារដែលមានឥណប្រតិទានចាប់ពីមួយឆ្នាំឡើងទៅ។

គ-សញ្ញាប័ណ្ណដែលផលចំណូលផ្សារភ្ជាប់នឹងអត្រាអតិផរណា ឬ អត្រាប្តូរប្រាក់ ឬ អត្រាផ្សេងៗ។

ឃ-មូលបត្ររដ្ឋដែលមិនអាចជួញដូរបាននៅលើទីផ្សារ។

ង-មូលបត្ររដ្ឋផ្សេងៗដទៃទៀត។

មូលបត្ររដ្ឋទាំងអស់ខាងលើនេះ មិនរួមបញ្ចូលនូវមូលបត្រ ដែលបោះផ្សាយដោយអាជ្ញាធរខេត្ត-ក្រុង និង សហគ្រាសសាធារណៈ ឬ ការសុំខ្ចីផ្សេងៗរបស់រាជរដ្ឋាភិបាលដែលមិនស្របទៅនឹងច្បាប់នេះទេ ។

**២-មូលបត្ររដ្ឋមិនអាចជួញដូរបាន** សំដៅដល់មូលបត្រទាំងឡាយណាដែលត្រូវសងទៅឱ្យអ្នកកាន់កាប់មូលបត្រដែលបានចុះបញ្ជី ឬ សន្តតិជនពេញសិទ្ធិតាមលក្ខខណ្ឌរបស់មូលបត្រនោះ ដោយស្របទៅតាមវិសាលភាព និង ការកំណត់របស់ប្រកាសដែលដាក់ឱ្យអនុវត្តដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អ្នកកាន់កាប់មូលបត្រ ឬ សន្តតិជនពេញសិទ្ធិមានសិទ្ធិស្នើសុំការទូទាត់សងមុនឥណប្រតិទាន ទៅតាមលក្ខខណ្ឌនៃមូលបត្រទាំងនោះ។

**៣-វិញ្ញាបនបត្រមូលបត្ររដ្ឋ** សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុជាលាយលក្ខណ៍អក្សរ ដោយមានការធានានូវការបំពេញកាតព្វកិច្ចទូទាត់ពេញលេញពីរាជរដ្ឋាភិបាលកម្ពុជា ដោយមានចែងអំពីរយៈពេល លក្ខខណ្ឌ និង កាតព្វកិច្ចផ្សេងៗទៀតរបស់មូលបត្រនោះ។

**៤-គណនី** សំដៅដល់គណនីទូទៅ និង គណនីពិសេសរបស់រតនាគារជាតិ ដូចមានចែងនៅក្នុងច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ ០១ ន.ស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និង គណនីពិសេសផ្សេងទៀតដែលបានបង្កើតដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**៥-សន្តតិជន** សំដៅដល់ជនដែលទទួលបន្តនូវសិទ្ធិ និងករណីកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម។

**៦-សន្តតិកម្ម** សំដៅដល់ការផ្ទេរសិទ្ធិ និងករណីកិច្ចរបស់មតកជនម្នាក់ ឬ ច្រើននាក់តាមឆន្ទៈ ឬ តាមច្បាប់។

**៧-មូលនិធិផ្សេងៗ** សំដៅដល់មូលនិធិពិសេស ដែលបង្កើតដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ មូលនិធិនេះ ត្រូវប្រើប្រាស់សម្រាប់ប្រតិបត្តិការមួយជាក់លាក់ក្នុងគោលបំណងច្បាស់លាស់ ហើយប្រតិបត្តិការនៃមូលនិធិនេះ មិនពាក់ព័ន្ធនឹងថវិកាចំណូល-ចំណាយរបស់រាជរដ្ឋាភិបាល ដែលស្ថិតនៅក្រោមច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ ០១ ន.ស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ នោះទេ លើកលែងតែមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ហៅកាត់ថា **ម.គ.ម.រ.** ដែលមានចែងក្នុងមាត្រា ៧ នៃច្បាប់នេះ។

**៨-មូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ (ម.គ.ម.រ.)** សំដៅដល់ប្រាក់ដែលផ្តល់ឱ្យ

ដោយរាជរដ្ឋាភិបាល និង ប្រាក់ដែលបានមកពីស្ថាប័នឯកជន និង សាធារណៈតាមរយៈការបោះផ្សាយមូលបត្ររដ្ឋ ប្រាក់នេះត្រូវបានប្រើប្រាស់សម្រាប់កិច្ចការទូទាត់សងប្រាក់ដើម និង ការប្រាក់នៃមូលបត្ររដ្ឋទាំងឡាយណាដែលបានបោះផ្សាយរួច។ មូលនិធិនេះ មិនមែនជាមូលនិធិដែលបង្កើតឡើងក្នុងគោលដៅមនុស្សធម៌នោះទេ។

**៩-ប្រធានស្ថាប័នរដ្ឋបាលកណ្តាល** សំដៅដល់ថ្នាក់ដឹកនាំក្រសួងនានា និងថ្នាក់ដឹកនាំនៃស្ថាប័នរដ្ឋបាលកណ្តាលផ្សេងទៀតដែលទទួលបានសិទ្ធិស្របច្បាប់ និងមានតួនាទីស្មើក្រសួងនានា។

**១០-ឥណប្រតិទាន** សំដៅដល់កាលបរិច្ឆេទមូលបត្រត្រូវដល់កាលកំណត់សង។

**១១-រដ្ឋមន្ត្រី** សំដៅដល់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**១២-ច្បាប់ធនាគារជាតិ** សំដៅដល់ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ន.ស./រ.ក.ម./០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦។

**១៣-ក្រសួង** សំដៅដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី ២
## ការបោះផ្សាយ និង ការដាក់លក់មូលបត្ររដ្ឋ

**មាត្រា ៣.-**

ការបោះផ្សាយ និង ការដាក់លក់មូលបត្ររដ្ឋ ត្រូវអនុវត្តដូចខាងក្រោមៈ

ក-មានតែរដ្ឋមន្ត្រីម្នាក់ប៉ុណ្ណោះ ដែលអាចបោះផ្សាយមូលបត្ររដ្ឋក្នុងក្របខ័ណ្ឌចំណាយនៃ **ម.គ.ម.រ.** ដូចមានចែងក្នុងមាត្រា ៧ នៃច្បាប់នេះ ។ រដ្ឋមន្ត្រីអាចទិញ ទូទាត់សង និង ផ្តល់ប្រាក់វិញនូវរាល់មូលបត្ររដ្ឋដែលដល់ ឬ មិនទាន់ដល់ឥណប្រតិទាន។ ប្រាក់ដើម និង ការប្រាក់នៃមូលបត្ររដ្ឋត្រូវបានធានាដោយគ្មានលក្ខខណ្ឌពីរាជរដ្ឋាភិបាល។

ខ-រតនាគារជាតិ និងនាយកដ្ឋានពាក់ព័ន្ធ ដែលស្ថិតនៅក្រោមការដឹកនាំរបស់រដ្ឋមន្ត្រី ត្រូវទទួលបន្ទុករាល់កិច្ចការពាក់ព័ន្ធនឹងមូលបត្ររដ្ឋ លើកលែងតែរដ្ឋមន្ត្រីបានផ្ទេរសិទ្ធិអំណាចជាលាយលក្ខណ៍អក្សរទៅឱ្យស្ថាប័នរដ្ឋដទៃទៀត។

គ-ដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់ធនាគារជាតិ រាល់ការងារបច្ចេកទេស និង ប្រតិបត្តិការទាក់ទងនឹងមូលបត្ររដ្ឋ អាចអនុវត្តដោយធនាគារជាតិនៃកម្ពុជា ដោយមានការណែនាំពីរដ្ឋមន្ត្រី ដែលមានចែងនៅក្នុងអនុក្រឹត្យ លើកលែងតែមានចែងក្នុងច្បាប់ផ្សេងទៀត។ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ត្រូវបង្កើតនូវនីតិវិធីដើម្បីបែងចែកឱ្យដាច់ដោយឡែកពីគ្នានូវមុខងារប្រតិបត្តិការទាក់ទងនឹងមូលបត្ររដ្ឋ និង មុខងារគោលនយោបាយរូបិយវត្ថុ។

ប្រសិនបើប្រធានស្ថាប័នរដ្ឋបាលកណ្តាលណាមួយ ដែលគ្រប់គ្រងគណនី និងមូលនិធិដទៃទៀត ដែលស្ថិតនៅក្រោមច្បាប់ផ្សេង ហើយមានបំណងបោះផ្សាយមូលបត្ររដ្ឋត្រូវធ្វើសំណើទៅរដ្ឋមន្ត្រីអំពីការបោះផ្សាយមូលបត្រនោះ។

អាជ្ញាធរខេត្ត-ក្រុង គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈមិនអាចបោះ-ផ្សាយសញ្ញាប័ណ្ណរដ្ឋ ដោយពុំមានការយល់ព្រមពីរដ្ឋមន្ត្រីជាមុននោះទេ។

មូលបត្ររដ្ឋអាចត្រូវបានបោះផ្សាយជារូបិយវត្ថុជាតិ ឬ ជារូបិយប័ណ្ណបរទេស។

**មាត្រា ៤.-**

ចំនួនទឹកប្រាក់សរុប នៃការបោះផ្សាយមូលបត្ររដ្ឋសម្រាប់ឆ្នាំសារពើពន្ធនីមួយៗ ត្រូវបានអនុម័តដោយរដ្ឋសភា។

នាយករដ្ឋមន្ត្រី ត្រូវធ្វើជូនរដ្ឋសភានូវចំនួនទឹកប្រាក់សរុបនៃមូលបត្ររដ្ឋដែលត្រូវបោះ-ផ្សាយ ដែលជាផ្នែកមួយនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ។

នាយករដ្ឋមន្ត្រី អាចធ្វើសំណើទៅរដ្ឋសភា ដើម្បីសុំការអនុម័តលើការបោះផ្សាយមូលបត្ររដ្ឋបន្ថែមទៅលើចំនួនទឹកប្រាក់សរុប ដែលរដ្ឋសភាបានអនុម័តរួចហើយ។ ជាមួយនឹងសំណើនេះ នាយករដ្ឋមន្ត្រីត្រូវផ្តល់នូវការពន្យល់ឱ្យបានច្បាស់លាស់នូវហេតុផលដ៏ចាំបាច់នៃការបោះផ្សាយមូលបត្របន្ថែមនេះ។

**មាត្រា ៥.-**

មូលបត្ររដ្ឋ ត្រូវបានបោះផ្សាយលក់ជាសាធារណៈ នៅលើទីផ្សារក្នុងតម្លៃសមស្រប តាមវិសាលភាពដែលអាចធ្វើទៅបាន ព្រមទាំងផ្តល់ឱកាសស្មើភាពគ្នា ដល់សាធារណជន ក្នុងការចូលរួមទិញមូលបត្រទាំងនេះ។

រដ្ឋមន្ត្រីអាចសម្រេចលើការបោះផ្សាយមូលបត្ររដ្ឋ តាមវិធីសាស្ត្រផ្សេងៗ ដើម្បីបម្រើផលប្រយោជន៍សាធារណៈ ដែលកំណត់ក្នុងអនុក្រឹត្យ។ ការបោះផ្សាយមូលបត្ររដ្ឋរួមទាំងរបៀបបោះផ្សាយ និង អត្រាការប្រាក់ត្រូវកំណត់ក្នុងអនុក្រឹត្យ។

មូលបត្ររដ្ឋត្រូវបានដាក់លក់ជាសាធារណៈ នៅទីផ្សារដំបូងដោយការដេញថ្លៃ។ នៅពេលដែលមានមូលបត្ររដ្ឋនៅសល់ពីការលក់ដោយការដេញថ្លៃ រដ្ឋមន្ត្រីអាចប្រើប្រាស់គណៈនីរាជរដ្ឋាភិបាល ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីទិញមូលបត្រទាំងនោះមកវិញតាមលក្ខខណ្ឌ និង រយៈពេលដូចដែលបានលក់ តាមរយៈការដេញថ្លៃ។

**មាត្រា ៦.-**

រាល់បញ្ហាទាក់ទងនឹងការគ្រប់គ្រងវិញ្ញាបនប័ត្រមូលបត្ររដ្ឋ ការចុះបញ្ជី និង ការទូទាត់សងប្រាក់ដើម និង ការប្រាក់នៃមូលបត្ររដ្ឋ ត្រូវកំណត់ក្នុងអនុក្រឹត្យ។

# ឧបសម្ព័ន្ធទី ៣

# អនុក្រឹត្យស្តីពី

# ការលើកទឹកចិត្តពន្ធដារ

# ក្នុងវិស័យមូលបត្រ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០១ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-** គោលបំណង

អនុក្រឹត្យនេះមានគោលបំណងលើកទឹកចិត្តពន្ធដារ ដើម្បីអភិវឌ្ឍវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-** គោលដៅ

អនុក្រឹត្យនេះមានគោលដៅកំណត់ពីប្រភេទ សកម្មភាព និងលក្ខខណ្ឌនានា ដែលជាកម្មវត្ថុនៃការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ដូចមានចែងក្នុងមាត្រា១២ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩។

**មាត្រា៣.-** វិសាលភាព

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះ÷

១. ក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា **គ.ម.ក.**) និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត។

២. អ្នកវិនិយោគសាធារណៈ ដែលកាន់កាប់ និង/ឬ ទិញ-លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលដែលបានបោះផ្សាយលក់ជាសាធារណៈ និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត។ សម្រាប់គោលដៅនៃអនុក្រឹត្យនេះ អ្នកវិនិយោគសាធារណៈរួមបញ្ចូលទាំងអ្នកវិនិយោគនិវាសនជន និងអនិវាសនជន។

## ជំពូកទី២
## សកម្មភាព និងលក្ខខណ្ឌនៃការលើកទឹកចិត្តពន្ធដារ

**មាត្រា៤.-** ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលចំពោះក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ក្នុងរយៈពេល ៣(បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ត្រូវបំពេញបែបបទជូនអគ្គនាយកដ្ឋានពន្ធដារតាមរយៈ **គ.ម.ក.** នៅរាល់មុនការិយបរិច្ឆេទបង់ពន្ធសម្រាប់ឆ្នាំសារពើពន្ធនីមួយៗ ដើម្បីទទួលបាននូវការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណូលចំនួន ៥០ (ហាសិប) ភាគរយ នៃពន្ធលើប្រាក់ចំណូលត្រូវបង់ក្នុងរយៈពេលនៃការទទួលបានការលើកទឹកចិត្តពន្ធដារ ដូចមានកំណត់ក្នុងកថាខណ្ឌទី២ នៃមាត្រា៤ នៃអនុក្រឹត្យនេះ។

ការលើកទឹកចិត្តពន្ធដារមានរយៈពេល ៣ (បី) ឆ្នាំ និងត្រូវគិតចាប់ផ្តើមពី÷

១- ដើមឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបានបោះផ្សាយលក់ជាសាធារណៈ ក្នុងករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ដើមឆ្នាំជាប់ពន្ធនោះ។

២- ដើមឆ្នាំជាប់ពន្ធបន្ទាប់ពីឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបោះផ្សាយលក់ជាសាធារណៈ ក្នុងករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ចុងឆ្នាំជាប់ពន្ធ។

៣- អំឡុងពេលណាមួយដែលទទួលបានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា៥.- ការអនុគ្រោះបំណុលពន្ធចំពោះក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ**

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ក្នុងរយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ត្រូវទទួលបានការអនុគ្រោះបំណុលពន្ធដែលរួមបញ្ចូលពន្ធលើប្រាក់ចំណូលទាំងស្រុង ពន្ធកាត់ទុក អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញ និងសេវាមួយចំនួន អាករស្នាក់នៅ អាករបំភ្លឺសាធារណៈ។ ការអនុគ្រោះបំណុលពន្ធទាំងស្រុងត្រូវអនុវត្តដូចខាងក្រោម÷

១- បំណុលពន្ធចាប់ពីកាលបរិច្ឆេទ N-3 ដល់ N-10 សម្រាប់ក្រុមហ៊ុន/ សហគ្រាសដែលបានបំពេញលក្ខខណ្ឌក្នុងការចុះបញ្ជីនៅទីផ្សារគោល។

២- បំណុលពន្ធចាប់ពីកាលបរិច្ឆេទ N-2 ដល់ N-10 សម្រាប់សហគ្រាសធុនតូច និងមធ្យមដែលបានបំពេញលក្ខខណ្ឌក្នុងការចុះបញ្ជីនៅទីផ្សារកំណើន។ (ឆ្នាំ N គឺជាឆ្នាំដែលក្រុមហ៊ុន/ សហគ្រាសធ្វើការបោះ-ផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលជាសាធារណៈជាលើកដំបូង។)

ការបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ និងចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត មិនតម្រូវឱ្យមានការធ្វើសវនកម្មពេញលេញជាមុនពីអគ្គនាយកដ្ឋានពន្ធដារនោះទេ។ សម្រាប់ការស្នើសុំបោះផ្សាយ ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ត្រូវផ្តល់ជូន **គ.ម.ក.** នូវវិញ្ញាបនបត្របញ្ជាក់កាតព្វកិច្ចពន្ធ ចេញដោយអគ្គនាយកដ្ឋានពន្ធដារ ដែលជាលិខិតសម្រាប់បញ្ជាក់ពីការប្រកាស និងបង់ពន្ធជាប្រចាំដោយមិនទាន់រងការធ្វើសវនកម្មពីអគ្គនាយកដ្ឋានពន្ធដារ។

**មាត្រា៦.-** ការលើកទឹកចិត្តពន្ធកាត់ទុកដល់អ្នកវិនិយោគមូលបត្រ

អ្នកវិនិយោគសាធារណៈត្រូវទទួលបានការបន្ថយពន្ធកាត់ទុក ៥០ (ហាសិប) ភាគរយ លើការប្រាក់ និង/ ឬ ភាគលាភ ដែលបានមកពីការកាន់កាប់ និង/ ឬ ការទិញ-លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុលសម្រាប់រយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន។

បុគ្គលជាភ្នាក់ងារកាត់ទុកដែលធ្វើការបើកការប្រាក់ និង/ ឬ ភាគលាភ ត្រូវធ្វើការគណនាប្រាក់ពន្ធកាត់ទុកដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ មុនការបើកប្រាក់ និងដាក់លិខិតប្រកាសបង់ប្រាក់ពន្ធកាត់ទុកជូនរដ្ឋបាលសារពើពន្ធ ទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ (ម្ភៃ) នៃខែបន្ទាប់ពីខែដែលបានធ្វើការកាត់ទុក។

**គ.ម.ក.** និងអគ្គនាយកដ្ឋានពន្ធដារ ត្រូវពិនិត្យជាមួយគ្នាលើអត្រាពន្ធកំណត់លើការប្រាក់នៃមូលបត្របំណុលនេះ និងស្នើសុំការពិនិត្យសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា៧.-** ក្រុមហ៊ុន/ សហគ្រាសដែលមិនត្រូវបានទទួលការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល

ក្រុមហ៊ុន/ សហគ្រាសមិនត្រូវទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងមាត្រា ៤ និងមាត្រា៥ នៃអនុក្រឹត្យនេះឡើយ ក្នុងករណីក្រុមហ៊ុននោះជាសហគ្រាសវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលកំពុងស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៨.-** ការបញ្ឈប់ការលើកទឹកចិត្តពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារអាចស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈ **គ.ម.ក.** ដើម្បីបញ្ឈប់ការលើកទឹកចិត្តពន្ធដារដូចមានចែងក្នុងមាត្រា៤ និងការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យនេះ ក្នុងករណីក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត÷

- មិនបានដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ និងបង់ប្រាក់ពន្ធ តាមកាលកំណត់របស់រដ្ឋបាលសារពើពន្ធ។

- មិនបានដាក់លិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំសារពើពន្ធ និងបង់ប្រាក់ពន្ធតាមកាលកំណត់របស់រដ្ឋបាលសារពើពន្ធ។ លិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំ ត្រូវភ្ជាប់មកជាមួយនូវរបាយ-ការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច ដោយក្រុមហ៊ុនគណនេយ្យជំនាញផ្តល់សេវានៅក្នុងវិស័យមូលបត្រ រួមមាន តារាងតុល្យការ គណនីលទ្ធផល តារាងចលនាសាច់ប្រាក់ និងកំណត់សម្គាល់ដោយមិនឱ្យហួសពីរយៈពេល ៣ (បី) ខែ ក្រោយពីដំណាច់ឆ្នាំសារពើពន្ធ។
- មិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធធ្វើសវនកម្មលើបញ្ជីកាគណនេយ្យ ឬឯកសារផ្សេងៗ។
- មិនបានបង់ពន្ធអាករទាំងអស់ ពន្ធបន្ថែម និងការប្រាក់ ដែលបានកំណត់សម្រាប់រយៈពេលជាប់ពន្ធដែលបានធ្វើសវនកម្មរួចដោយរដ្ឋបាលសារពើពន្ធ។

ក្នុងករណីក្រុមហ៊ុន/ សហគ្រាសដែលទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងអនុក្រឹត្យនេះ មិនបានអនុវត្តតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងវិស័យមូលបត្រ **គ.ម.ក.** អាចស្នើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីបញ្ឈប់ការលើកទឹកចិត្ត ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា៤ និងការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យនេះ។

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុតមិនត្រូវទទួលបាននូវការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងអនុក្រឹត្យនេះឡើយ ក្នុងករណីក្រុមហ៊ុន/ សហគ្រាសនោះបានដកខ្លួនចេញពីការចុះបញ្ជីជួញដូរមូលបត្រ ឬត្រូវបានដកពីការចុះបញ្ជីជួញដូរមូលបត្រនៅក្នុងទីផ្សារមូលបត្រប្រតិស្រុត។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា៩.-** ការលើកទឹកចិត្តពន្ធដារចំពោះក្រុមហ៊ុន/ សហគ្រាសដែលបានបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈរួច

ក្រុមហ៊ុន/ សហគ្រាសដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** ធ្វើការបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ និងដែលបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុតរួចហើយ តែមិនទាន់ទទួលបាននូវការលើកទឹកចិត្តពន្ធដារនោះ ត្រូវបានផ្តល់ការលើកទឹកចិត្តពន្ធ-ដារ ដូចមានចែងក្នុងមាត្រា៤ នៃអនុក្រឹត្យនេះ។

**មាត្រា១០.-** ការជំនួស

បញ្ញត្តិទាំងឡាយដែលចេញឡើងស្របតាមអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ ២០១៥ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារក្នុងវិស័យមូលបត្រ នឹងត្រូវបន្តអនុវត្តអនុលោមតាមអនុក្រឹត្យនេះ។

**មាត្រា១១..** ការអនុវត្ត

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មការមូលបត្រកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកអគ្គនាយកដ្ឋានពន្ធដារ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ១៣រោច ខែមិគសិរ ឆ្នាំមមែ សប្តស័ក ព.ស.២៥៥៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែមករា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ដូចមាត្រា ១១ "ដើម្បីអនុវត្ត"
- គ្រប់ក្រសួង-ស្ថាប័ន
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី ៤
# យុទ្ធសាស្ត្រអភិវឌ្ឍន៍
# វិស័យហិរញ្ញវត្ថុ
# ឆ្នាំ ២០១៦-២០២៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
# ឆ្នាំ ២០១៦ - ២០២៥



បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី
ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២១ ខែតុលា ឆ្នាំ២០១៦

**រាជរដ្ឋាភិបាលកម្ពុជា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
# ឆ្នាំ ២០១៦-២០២៥



រាជរដ្ឋាភិបាលកម្ពុជា

ឆ្នាំ ២០១៦

# ខ្លឹមសារសង្ខេប

I. **ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុកម្ពុជាឆ្នាំ២០០១-២០១០** កន្លងមក បានផ្តោតសំខាន់លើការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមួយដ៏រឹងមាំ និងផ្អែកលើយន្តការទីផ្សារ ដើម្បីពង្រឹងការកៀរគរ និងបែងចែកធនធានសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ នៅឆ្នាំ២០០៦ ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុកម្ពុជាឆ្នាំ២០០១-២០១០ ត្រូវបានធ្វើបច្ចុប្បន្នកម្មទៅជា **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥**។ យុទ្ធសាស្ត្រនេះ ក៏ត្រូវបានធ្វើបច្ចុប្បន្នកម្មលើកទី២ នៅឆ្នាំ២០១១ ទៅជា **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**។

II. ដើម្បីឆ្លើយតបនឹងការវិវត្តរីកចម្រើននៃសេដ្ឋកិច្ចជាតិ និងស្របតាមការប្រែប្រួលនៃស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិភពលោក និងតំបន់ រាជរដ្ឋាភិបាលបានសម្រេចធ្វើបច្ចុប្បន្នកម្មឯកសារយុទ្ធសាស្ត្រខាងលើជាលើកទី៣ ទៅជា **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥** ដោយដាក់ចេញនូវគោលដៅសម្រេចឲ្យបានប្រព័ន្ធហិរញ្ញវត្ថុមួយប្រកបដោយប្រសិទ្ធភាព ដោយផ្អែកលើគោលការណ៍ទីផ្សារ ហើយមានលក្ខណៈពិពិធភាព ភាពរឹងមាំ និងបរិយាបន្នដែលផ្តល់លទ្ធភាពទូលំទូលាយក្នុងការបំពេញតម្រូវការសេវាហិរញ្ញវត្ថុនៅក្នុងប្រទេស ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងប្រសិទ្ធភាព កាត់បន្ថយភាពក្រីក្រ បង្កើនចំណូលរបស់ប្រជាជន ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការធ្វើសមាហរណកម្មសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅក្នុងតំបន់។

III. យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ នេះ ឆ្លុះបញ្ចាំងពីសមិទ្ធផលផ្នែកសេដ្ឋកិច្ចរបស់កម្ពុជារហូតមកដល់បច្ចុប្បន្ន ព្រមទាំងវាយតម្លៃពីឧបសគ្គ និងបញ្ហាប្រឈមនាពេលបច្ចុប្បន្ន និងដាក់ចេញជាផែនការសកម្មភាពសម្រាប់ពេលអនាគត។ យុទ្ធសាស្ត្រនេះធ្វើសំយោគនិងកំណត់គោលដៅអាទិភាពនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់អនុវិស័យនីមួយៗនៃប្រព័ន្ធហិរញ្ញវត្ថុ ដើម្បីធានាឲ្យយុទ្ធសាស្ត្រ និងផែនការសកម្មភាពទាំងនេះដើរស្របតាមទស្សនវិស័យរយៈពេលវែងរបស់វិស័យហិរញ្ញវត្ថុទាំងមូល។ ឯកសារនេះ ក៏ជាមគ្គុទ្ទេសក៍ដែលអនុញ្ញាតឲ្យដៃគូអភិវឌ្ឍអាចសម្របសម្រួលផ្តល់ការកសាងសមត្ថភាព និងជំនួយបច្ចេកទេសក្នុងទម្រង់ផ្សេងៗផងដែរ។

IV. ឯកសារយុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើលទ្ធផល ក៏ដូចជាមេរៀន បទពិសោធ និងបញ្ហាប្រឈមក្នុងការអនុវត្តនាពេលកន្លងមក ហើយក៏ត្រូវបានរៀបចំឡើងឲ្យមានលក្ខណៈបត់បែនដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃស្ថានភាពសេដ្ឋកិច្ច សង្គម និងនយោបាយនៅ

កម្ពុជា ក៏ដូចជាការវិវត្តនៃវិស័យហិរញ្ញវត្ថុ ការផ្លាស់ប្តូរ និងបញ្ហាប្រឈមនានាដែលជាលទ្ធផលនៃសន្ទុះសមាហរណកម្មកម្ពុជាទៅក្នុងទីផ្សារតំបន់ និងសកល។

## ក. សមិទ្ធផលសំខាន់ៗអនុវត្តបានក្នុងរយៈពេល ១៥ឆ្នាំចុងក្រោយ

V. រាជរដ្ឋាភិបាល សម្រេចបានសមិទ្ធផលជាច្រើនក្នុងរយៈពេល ១៥ឆ្នាំចុងក្រោយនេះ តាមរយៈការធ្វើកំណែទម្រង់ជាច្រើនជាបន្តបន្ទាប់។ សមិទ្ធផលសំខាន់ៗរួមមាន៖

- ការអនុម័តច្បាប់សំខាន់ៗទាក់ទងនឹងវិស័យពាណិជ្ជកម្មនិងហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុឱ្យរឹងមាំនិងផ្អែកលើយន្តការទីផ្សារ
- កំណែទម្រង់រចនាសម្ព័ន្ធវិស័យធនាគារនិងការពង្រឹងគ្រឹះស្ថានហិរញ្ញវត្ថុសំខាន់ៗ
- ការបង្កើតហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ដល់សកម្មភាពទីផ្សារហិរញ្ញវត្ថុ និងពង្រីកសេវាហិរញ្ញវត្ថុដល់ជនបទ
- ការបង្កើតនិងដាក់ឱ្យដំណើរការនូវវិស័យហិរញ្ញវត្ថុផ្សេងទៀត ដូចជា វិស័យមូលបត្រ ធានារ៉ាប់រងអាយុជីវិត សោធន ទទួលបញ្ចាំ និងវិស័យអចលនវត្ថុ
- ការអភិវឌ្ឍធនធានមនុស្សនិងការធ្វើឯកទេសកម្មជំនាញបច្ចេកទេស និង
- ការពង្រីកតួនាទីវិស័យហិរញ្ញវត្ថុ ដើម្បីគៀរគរធនធានហិរញ្ញវត្ថុក្នុងស្រុកសម្រាប់បំពេញតម្រូវការសេដ្ឋកិច្ចដែលកាន់តែរីកចម្រើនយ៉ាងឆាប់រហ័ស។

VI. ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានកន្លងមក យុទ្ធសាស្ត្រ២០១៦-២០២៥នេះ ក៏មានគោលដៅដោះស្រាយបញ្ហាប្រឈមសំខាន់ៗដូចជា៖

- ហានិភ័យនិងបញ្ហាប្រឈមពីកត្តាខាងក្រៅដែលអាចប៉ះពាល់ដល់សមិទ្ធផលសេដ្ឋកិច្ចជាតិបច្ចុប្បន្ន
- ហានិភ័យផ្ទៃក្នុងដែលកើតឡើងដោយសារភាពយឺតយ៉ាវក្នុងការធ្វើកំណែទម្រង់មួយចំនួនដែលអាចប៉ះពាល់ដល់ស្ថិរភាពហិរញ្ញវត្ថុ
- ការសម្របសម្រួលគោលនយោបាយ នៅមានកម្រិតដែលពន្យារពេលក្នុងការដោះស្រាយភាពខ្វះចន្លោះនៃក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន ដើម្បីឱ្យស្របតាមការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យនេះ
- តម្រូវការជាបន្តបន្ទាប់ក្នុងការកសាងធនធានមនុស្សក្នុងវិស័យហិរញ្ញវត្ថុ និងការរក្សានូវការរីកចម្រើននេះ
- តម្រូវការក្នុងការធ្វើសុខដុមនីយកម្មក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធឱ្យស្របតាមការរីកចម្រើននៃវិស័យហិរញ្ញវត្ថុ និង

- តម្រូវការកិច្ចសហការពីអាជ្ញាធរពាក់ព័ន្ធ ដើម្បីជៀសវាងហានិភ័យប្រទាក់ក្រឡាដែលអាចជះឥទ្ធិពលដល់សេដ្ឋកិច្ចទាំងមូល។

## ខ. ការត្រៀមលក្ខណៈដោះស្រាយបញ្ហាប្រឈម

VII. ដើម្បីត្រៀមលក្ខណៈដោះស្រាយបញ្ហាប្រឈម ដែលអាចនឹងកើតមានឡើងក្នុងអំឡុងពេលនៃការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ ទាមទារនូវ៖

- ការយល់ដឹង ការត្រៀមលក្ខណៈ និងការសម្របសម្រួលដ៏ជិតស្និទ្ធរវាងភាគីពាក់ព័ន្ធសំខាន់ៗ
- ការតាមដានសមិទ្ធផលជាប្រចាំ និងការកំណត់បញ្ហាទាន់ពេលវេលា ដើម្បីដោះស្រាយជាបន្ទាន់ និងសមស្រប
- ការបែងចែកធនធានចាំបាច់សម្រាប់ទ្រទ្រង់ការអនុវត្តផែនការយុទ្ធសាស្ត្រនេះ
- ការលើកកម្ពស់ភាពម្ចាស់ការរបស់អាជ្ញាធរពាក់ព័ន្ធលើផែនការយុទ្ធសាស្ត្រនេះ
- ការកំណត់ឲ្យបានច្បាស់ពីការទទួលខុសត្រូវ និងគណនេយ្យភាពរបស់ក្រសួងស្ថាប័នដែលអនុវត្តផែនការសកម្មភាព
- កិច្ចសហប្រតិបត្តិការរវាងស្ថាប័នអន្តរជាតិ និងដៃគូអភិវឌ្ឍដែលផ្តល់ជំនួយបច្ចេកទេស និងជំនួយក្នុងទម្រង់ផ្សេងៗតាមការចង្អុលទិសរបស់អាជ្ញាធរពាក់ព័ន្ធ និង
- ការរៀបចំមូលដ្ឋានរឹងមាំសម្រាប់ការអភិវឌ្ឍសមត្ថភាព។

VIII. បញ្ហាប្រឈមបន្ថែមទៀតដែលគួរចាប់អារម្មណ៍ រួមមាន៖

- ការសម្របតាមស្តង់ដាអន្តរជាតិក្នុងការត្រួតពិនិត្យដោយផ្អែកលើហានិភ័យ ស្របតាមការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ និងការពង្រឹងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរពាក់ព័ន្ធដើម្បីជួយសម្រួលដល់ការចែករំលែកព័ត៌មាន និងគ្រប់គ្រងវិបត្តិដែលអាចកើតមានឡើងប្រកបដោយប្រសិទ្ធភាព
- ការរៀបចំក្របខ័ណ្ឌស្ថាប័នសម្រាប់បញ្ញត្តិកម្ម និងត្រួតពិនិត្យវិស័យហិរញ្ញវត្ថុទាំងមូល ក៏ដូចជាការធ្វើបច្ចុប្បន្នកម្មក្របខ័ណ្ឌច្បាប់ជាធរមាន ទាមទាររយៈពេលច្រើនឆ្នាំដើម្បីទទួលបានការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ
- តម្រូវការពង្រឹងសមត្ថភាពបច្ចេកទេសជំនាញក្នុងវិស័យគន្លឹះ ដើម្បីឈានឲ្យទាន់ការកើនឡើងនៃភាពប្រទាក់ក្រឡាក្នុងវិស័យធនាគារ មូលបត្រ និងវិស័យធានារ៉ាប់រង ក៏ដូចជាការកើនឡើងហានិភ័យថ្មីៗដែលអាចគំរាមកំហែងដល់ស្ថិរភាពហិរញ្ញវត្ថុ
- តម្រូវការនូវជំនាញបច្ចេកទេសល្អ និងការត្រួតពិនិត្យដែលមានគុណភាព ព្រមទាំងការសម្របសម្រួលល្អដើម្បីវាយតម្លៃ និងដោះស្រាយហានិភ័យទីផ្សារ ហានិភ័យប្រតិបត្តិការ និងហានិភ័យសន្ទនីយភាពជាដើម

- ការបង្កើនការយល់ដឹងឲ្យបានស៊ីជម្រៅពីហានិភ័យ និងសមត្ថភាពក្នុងការធ្វើសុភវិនិច្ឆ័យសម្រាប់មន្ត្រីត្រួតពិនិត្យគ្រប់ថ្នាក់
- ការបង្កើតយន្តការលើកទឹកចិត្ត ដើម្បីរក្សាទុកមន្ត្រីជំនាញដែលទទួលបានការបណ្តុះបណ្តាលពីអាជ្ញាធរបញ្ញត្តិកម្មនានា ដើម្បីទប់ទល់នឹងតម្រូវការខ្ពស់ពីវិស័យឯកជន
- ការអនុវត្តតាមស្តង់ដាអន្តរជាតិ ដើម្បីធ្វើសុខដុមនីយកម្ម និងជំរុញសមាហរណកម្មប្រព័ន្ធហិរញ្ញវត្ថុកម្ពុជាជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ាន
- ការអនុវត្តបទប្បញ្ញត្តិនានាឲ្យមានប្រសិទ្ធភាព សំដៅពង្រឹងគុណភាពទិន្នន័យ តម្លាភាពអភិបាលកិច្ចសាជីវកម្ម ក្រមសីលធម៌វិជ្ជាជីវៈ ការបើកចំហព័ត៌មានចំពោះទីផ្សារ និងសាធារណជន និងការប្រកួតប្រជែងស្មើភាពក្នុងវិស័យហិរញ្ញវត្ថុ និង
- ការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិនៅក្នុងសេដ្ឋកិច្ច និងតាមដានហានិភ័យពាក់ព័ន្ធ។

## គ. គោលដៅនិងយុទ្ធសាស្ត្រ

IX. យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥នេះ មានគោលដៅអភិវឌ្ឍវិស័យហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ដោយផ្អែកលើគោលការណ៍ទីផ្សារ ហើយមានលក្ខណៈពិពិធភាព ភាពរឹងមាំ និងបរិយាបន្នដែលផ្តល់លទ្ធភាពទូលំទូលាយក្នុងការបំពេញតម្រូវការសេវាហិរញ្ញវត្ថុនៅក្នុងប្រទេស ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងប្រសិទ្ធភាព បង្កើនចំណូលរបស់ប្រជាជន កាត់បន្ថយភាពក្រីក្រ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការធ្វើសមាហរណកម្មសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅក្នុងតំបន់។

X. ដើម្បីសម្រេចគោលដៅខាងលើនេះ រាជរដ្ឋាភិបាលនឹងតម្រូវឲ្យអាជ្ញាធរហិរញ្ញវត្ថុមានការកែសម្រួលនូវក្របខ័ណ្ឌស្ថាប័ន ដើម្បីសម្របតាមការវិវត្តថ្មីៗនៃវិស័យហិរញ្ញវត្ថុ។ ដោយសារប្រតិបត្តិការរវាងវិស័យធនាគារ វិស័យធានារ៉ាប់រង និងវិស័យមូលបត្រ មានភាពប្រទាក់ក្រឡាគ្នា អាជ្ញាធរហិរញ្ញវត្ថុត្រូវធានាឲ្យបាននូវការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព តាមរយៈការបង្កើតឲ្យមានយន្តការសហប្រតិបត្តិការរវាងអាជ្ញាធរពាក់ព័ន្ធ។

XI. រាជរដ្ឋាភិបាលនឹងរៀបចំឡើងវិញនូវក្របខ័ណ្ឌច្បាប់ជាធរមានទាំងឡាយដែលមានអសង្គតិភាពជាមួយគ្នា និងមិនទាន់ត្រឹមត្រូវតាមស្តង់ដាអន្តរជាតិ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏នឹងរៀបចំឲ្យមានយន្តការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ដើម្បីជៀសវាងភាពត្រួតគ្នានៃការគ្រប់គ្រង និងការត្រួតពិនិត្យនៅក្នុងវិស័យហិរញ្ញវត្ថុ។

XII. ក្របខ័ណ្ឌគ្រប់គ្រងវិបត្តិកំពុងត្រូវបានអភិវឌ្ឍនិងតម្រូវឲ្យមានការធ្វើតេស្តប្រចាំគ្រា ដើម្បីឲ្យស្របតាមស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា និងដោះស្រាយហានិភ័យថ្មីៗដែលអាចកើតមានឡើងពីការកើនឡើងនៃភាពប្រទាក់ក្រឡាគ្នានៅក្នុងវិស័យហិរញ្ញវត្ថុ។ ដោយសារកម្រិត

ដុល្លារូបនីយកម្មខ្ពស់ ការយកចិត្តទុកដាក់ខ្ពស់លើហានិភ័យជាប្រព័ន្ធពិតជាមានសារៈសំខាន់។ ការបង្កើតក្រុមការងារស្ថិរភាពហិរញ្ញវត្ថុរបស់ធនាគារជាតិនៃកម្ពុជា និងប្រព័ន្ធផ្ដល់ព័ត៌មានជាមុននៅក្នុងប្រព័ន្ធធនាគារ នឹងរួមចំណែកកំណត់អត្តសញ្ញាណហានិភ័យនានា។ ចំណែកឯគណៈកម្មាធិការស្ថិរភាពហិរញ្ញវត្ថុថ្នាក់ជាតិ នឹងត្រូវបានបង្កើតឡើង។

XIII. ផ្អែកទៅលើគោលដៅរយៈពេលវែងរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ការបន្តអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយភាពប្រុងប្រយ័ត្ន និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ទីផ្សារពិតជាចាំបាច់នាទសវត្សរ៍ខាងមុខ។ ដោយសារឧបករណ៍រូបិយវត្ថុនៅមានកម្រិត ធនាគារជាតិនៃកម្ពុជាចាំបាច់ត្រូវអភិវឌ្ឍឧបករណ៍ថ្មីៗ កសាងសមត្ថភាពផ្ទៃក្នុង និងបង្កើនស្វ័យភាពក្នុងការរៀបចំ និងអនុវត្តគោលនយោបាយរូបិយវត្ថុ ដើម្បីធានាបាននូវស្ថិរភាពរូបិយវត្ថុ ស្ថិរភាពហិរញ្ញវត្ថុ និងកំណើនសេដ្ឋកិច្ច។

XIV. អនុវិស័យធនាគារនៅតែបន្តគ្របដណ្ដប់វិស័យហិរញ្ញវត្ថុទាំងមូល និងនៅតែជាផ្នែកមួយសំខាន់ក្នុងវិស័យ។ អាទិភាពក្នុងវិស័យធនាគារ រួមមាន ការរក្សាស្ថិរភាពរូបិយវត្ថុ ស្ថិរភាពហិរញ្ញវត្ថុ ការជំរុញបរិយាបន្នហិរញ្ញវត្ថុ និងការលើកកម្ពស់អនុលោមភាពតាមគោលការណ៍គ្រឹះរបស់គណៈកម្មាធិការបាសែលលើការត្រួតពិនិត្យធនាគារ។

XV. ចក្ខុវិស័យសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ គឺសំដៅជំរុញបរិយាបន្នហិរញ្ញវត្ថុ ដែលមានន័យថាជួយឲ្យប្រជាពលរដ្ឋក្រីក្រអាចទទួលបានសេវាហិរញ្ញវត្ថុក្នុងតម្លៃសមស្រប ដើម្បីបង្កើនចំណូល និងកាត់បន្ថយភាពក្រីក្រ។ គោលដៅនៅទសវត្សរ៍ខាងមុខ គឺបន្តអភិវឌ្ឍវិស័យនេះ ដើម្បីផ្ដល់សេវាហិរញ្ញវត្ថុឲ្យកាន់តែទូលំទូលាយដល់ប្រជាពលរដ្ឋដែលមានចំណូលទាប។

XVI. យុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍវិស័យធានារ៉ាប់រង គឺបន្តអនុវត្តផែនការសកម្មភាពដែលមានចែងនៅក្នុងចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ ក៏ដូចជាបង្កើតផលិតផលថ្មីៗ និងពង្រីកការប្រើប្រាស់ផលិតផលដែលមានស្រាប់ ព្រមទាំងពង្រឹងបទប្បញ្ញត្តិ និងសមត្ថភាពត្រួតពិនិត្យស្របតាមឧត្តមានុវត្តភាព។

XVII. ទីផ្សារមូលបត្រដែលត្រូវបានដាក់ឲ្យដំណើរការជាផ្លូវការ កាលពីខែកក្កដា ឆ្នាំ២០១១ គឺជាចំណុចចាប់ផ្ដើមមួយដ៏សំខាន់នៃយុទ្ធសាស្ត្រធ្វើពិពិធកម្មវិស័យហិរញ្ញវត្ថុ។ យុទ្ធសាស្ត្របច្ចុប្បន្នមានផែនការសកម្មភាពជាច្រើនដែលលើកទឹកចិត្តដល់ការចុះបញ្ជី និងដើម្បីសម្រេចបានសមិទ្ធផលច្រើននៅក្នុងទីផ្សារមូលបត្រ។ គណៈកម្មការមូលបត្រកម្ពុជាកំពុងបំពេញការងារឲ្យសម្រេចបានតាមគោលដៅកំណត់របស់វេទិកាទីផ្សារមូលធនអាស៊ាន និងកំពុងរៀបចំការវាយតម្លៃលើគោលការណ៍ស្នូលរបស់អង្គការអន្តរជាតិនៃគណៈកម្មការមូលបត្រ ក៏ដូចជាអនុវត្តជំហានបន្តបន្ទាប់ដើម្បីក្លាយជាសមាជិក។

XVIII. ប្រព័ន្ធទូទាត់និងផាត់ទាត់ បាននិងកំពុងអភិវឌ្ឍដើម្បីលើកកម្ពស់ការភ្ជាប់បណ្តាញ បង្កើនសេវាដល់អតិថិជន និងគាំទ្រដល់ប្រតិបត្តិការមូលបត្ររដ្ឋនាពេលអនាគត។ ការប្រើប្រាស់ស្តង់ដា និងប្រព័ន្ធរួម មានសារៈសំខាន់ក្នុងការកាត់បន្ថយការចំណាយ និងសម្របសម្រួលដល់ការអភិវឌ្ឍ។ បណ្ណដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ បណ្ណឥណពន្ធ និងប្រព័ន្ធធនាគារតាមទូរស័ព្ទចល័ត និងតាមអ៊ីនធឺណិត កំពុងត្រូវបានដាក់ឲ្យប្រើប្រាស់។ ទន្ទឹមនេះ ដើម្បីធានាឲ្យបានឧត្តមានុវត្តភាព ធនាគារជាតិនៃកម្ពុជានឹងដាក់ឲ្យប្រើប្រាស់ប្រព័ន្ធទូទាត់ដុលភ្លាមៗ (RTGS) ផងដែរ។

XIX. ឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥នេះ ដាក់ចេញនូវផែនការសកម្មភាពក្នុងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងវិស័យធនាគារនិងវិស័យពាក់ព័ន្ធផ្សេងទៀត ដូចជា៖

- ការកសាងសមត្ថភាពដើម្បីធ្វើការតាមដាននិងត្រួតពិនិត្យគួបសរុប
- ការការពារប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុពីការប្រើប្រាស់ជាមធ្យោបាយសម្រាប់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និង
- ការលើកកម្ពស់អភិបាលកិច្ចល្អ គុណភាពទិន្នន័យ ប្រព័ន្ធគណនេយ្យ និងសវនកម្ម ក៏ដូចជាការវាយតម្លៃលើអចលនទ្រព្យ សេវាកម្មអចលនទ្រព្យ និងទីផ្សារអចលនវត្ថុ។

XX. ជារួម យុទ្ធសាស្ត្រកំណែទម្រង់និងផែនការសកម្មភាពសម្រាប់វិស័យនីមួយៗ មានសារៈសំខាន់ និងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ។ រាជរដ្ឋាភិបាលទទួលស្គាល់ថា ភាពយឺតយ៉ាវក្នុងការសម្រេចគោលដៅរបស់វិស័យណាមួយ នឹងអាចបង្អាក់ដល់ដំណើរការកំណែទម្រង់នៅក្នុងវិស័យផ្សេងទៀត។ យោងតាមបទពិសោធនៃការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុកន្លងមក ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរពាក់ព័ន្ធ ស្ថាប័នអន្តរជាតិ និងដៃគូអភិវឌ្ឍ គឺជាកត្តាសំខាន់ដើម្បីធានាឲ្យបានជោគជ័យក្នុងកំណែទម្រង់។ ការតាមដានជាទៀងទាត់ពីវឌ្ឍនភាពនៃកម្មវិធីកំណែទម្រង់ និងបញ្ហាប្រឈមថ្មីៗដែលកើតមានពីការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃទីផ្សារហិរញ្ញវត្ថុត្រូវធ្វើឡើងឲ្យទាន់ពេលវេលា និងមានផែនការសមស្រប។

## ជំពូកទី៣
## វិស័យមិនមែនធនាគារ

### I. ទីផ្សារមូលធន

### ក.ពិជ្ជភាពទូទៅ

**៩៩-** គណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**) ដែលជានិយ័តករមូលបត្រ ត្រូវបានបង្កើតឡើងនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨ ក្រោមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។ ចំណែកឯ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) ត្រូវបានបង្កើតឡើងដោយការរួមទុនគ្នារវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ នឹងបានដាក់សម្ពោធជាផ្លូវការនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១។ ចាប់តាំងពីពេលដាក់ឲ្យដំណើរការមក ទាំង **គ.ម.ក.** និង **ផ.ម.ក.** ប្រតិបត្តិមុខងាររបស់ខ្លួនដោយរលូន និងគួរឲ្យជឿទុកចិត្ត ដោយគ្មានបញ្ហាគួរឲ្យកត់សម្គាល់ណាមួយកើតឡើងនោះទេ។

**១០០-** ទីផ្សារមូលបត្រមានវឌ្ឍនភាពប្រកបដោយស្ថិរភាព ក៏ប៉ុន្តែទីផ្សារនេះកំពុងស្ថិតនៅក្នុងដំណាក់កាលអភិវឌ្ឍ និងកសាងសមត្ថភាព។

### ខ. វឌ្ឍនភាពនិងសមិទ្ធផល

**១០១-** ច្បាប់ បទប្បញ្ញត្តិនានា និងវិធានចុះបញ្ជីត្រូវបានដាក់ឲ្យអនុវត្ត ដើម្បីគ្រប់គ្រងមូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល ព្រមទាំងឧបករណ៍ដែលអាចបំលែងទៅជាមូលបត្រផ្សេងៗទៀតបាន ឬឧបករណ៍និស្សន្ទដែលធ្វើការបោះផ្សាយលក់ជាសាធារណៈ និងចុះបញ្ជីនៅលើទីផ្សារ។ ការជួញដូរនៅលើ ផ.ម.ក. បានចាប់ផ្តើម នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ ជាមួយនឹងការចុះបញ្ជីរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលជាសហគ្រាសសាធារណៈ។ រោងចក្រកាត់ដេរដែលកាន់កាប់ដោយវិស័យឯកជន គឺក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ីនធីណេស៊ិនណាល់ (Grand Twins International) បានចុះបញ្ជីជួញដូរនៅលើទីផ្សារនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤។ ចំណែកឯការចុះបញ្ជីរបស់សហគ្រាសទី៣ កំពង់ផែស្វយតភ្នំពេញ ដែលជាសហគ្រាសសាធារណៈ បានធ្វើឡើងនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ ហើយតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ជាក្រុមហ៊ុនចុះបញ្ជីទី៤ បានធ្វើឡើងនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦។ ព្រមជាមួយគ្នានេះ ក៏មានក្រុមហ៊ុនជាច្រើនទៀតដែលកំពុងរៀបចំខ្លួនដើម្បីចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា។

**១០២- ផែនការដើម្បីបង្កើនការចុះបញ្ជីនៅលើទីផ្សារ:** ការបង្កើនចំនួនក្រុមហ៊ុនចុះបញ្ជីជួញដូរនៅលើទីផ្សារត្រូវបានផ្តោតការយកចិត្តទុកដាក់ខ្ពស់តាមរយៈការអភិវឌ្ឍ និងការអនុវត្តផែនការជំរុញការចុះ

បញ្ជីនៅលើទីផ្សារ។ ការផ្ដល់ការលើកទឹកចិត្តនានាដល់ក្រុមហ៊ុនចុះបញ្ជីជួញដូរនៅលើទីផ្សារ ដូចជាការលើកទឹកចិត្តផ្នែកពន្ធដារក្នុងវិស័យមូលបត្រ ត្រូវបានដាក់ឲ្យអនុម័ត និងផ្សព្វផ្សាយព្រមជាមួយនឹងការដាក់ឲ្យអនុវត្តកម្មវិធីជំរុញការយល់ដឹងជាសាធារណៈ។ ការសម្របសម្រួលដើម្បីជំរុញឲ្យមានក្រុមហ៊ុនចុះបញ្ជីជួញដូរច្រើននៅលើទីផ្សារ និងមកពីវិស័យចម្រុះ ត្រូវបានធ្វើឡើងប្រកបដោយកិច្ចខិតខំប្រឹងប្រែងខ្ពស់។ វិធាននិងប្រព័ន្ធសម្រាប់ជួញដូរ ត្រូវបានអភិវឌ្ឍឲ្យប្រសើរឡើង នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៤ ដើម្បីជួយសម្រួលដល់ការជួញដូរជានិរន្តរ៍ បន្ថែមទៅលើការជួញដូរថ្លៃតែមួយ និងការជួញដូរមុនការទូទាត់។ **គ.ម.ក.** បានធ្វើវិសោធនកម្មបទប្បញ្ញត្តិ នៅក្នុងខែកញ្ញា ឆ្នាំ២០១៥ ដើម្បីលើកទឹកចិត្តដល់ក្រុមហ៊ុនធ្វើការចុះបញ្ជីជួញដូរនៅលើទីផ្សារ ដោយធ្វើការបែងចែកទីផ្សារជាពីរប្រភេទ (ទីផ្សារគោល (Main Board) សម្រាប់សហគ្រាសធុនធំ និងទីផ្សារកំណើន (Growth Board) សម្រាប់សហគ្រាសធុនតូច និងមធ្យម) តាមរយៈការផ្ដល់ភាពងាយស្រួល ក្នុងការចូលទីផ្សារសម្រាប់សហគ្រាសធុនតូច និងមធ្យម និងកាត់បន្ថយលក្ខខណ្ឌអប្បបរមា ព្រមទាំងលក្ខខណ្ឌតម្រូវលើរបាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ។

**១០៣- ក្របខ័ណ្ឌបទប្បញ្ញត្តិ:** អនុក្រឹត្យចំនួន១និងប្រកាសចំនួន១៨ ត្រូវបានអនុម័តក្នុងរយៈពេល ២ (ពីរ) ឆ្នាំកន្លងទៅនេះ។ ទន្ទឹមនឹងនេះដែរ សេចក្ដីព្រាងអនុក្រឹត្យចំនួន១និងសេចក្ដីព្រាងប្រកាសចំនួន២០ផ្សេងទៀតកំពុងស្ថិតនៅក្នុងដំណាក់កាលស្នើសុំការអនុម័ត ឬរៀបចំជាសេចក្ដីព្រាង ក្នុងនោះរួមមាន សេចក្ដីព្រាងអនុក្រឹត្យស្ដីពីបុននីតិសម្បទា និងការជម្រះបញ្ជីក្នុងវិស័យមូលបត្រ ក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់ភ្នាក់ងារវាយតម្លៃលទ្ធភាពសង និងក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់ទីផ្សារសញ្ញាបណ្ណសាជីវកម្ម គម្រោងវិនិយោគរួម ព្រមទាំងការឲ្យខ្ចី និងការខ្ចីមូលបត្រដែលពាក់ព័ន្ធជាមួយនឹងការជួញដូរ និងការទូទាត់។ **គ.ម.ក.** បានធ្វើស្វ័យវាយតម្លៃស្របតាមគោលការណ៍ IOSCO ដូចបានកំណត់នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០។ នៅខែកក្កដា ឆ្នាំ២០១៤ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា និងគណៈកម្មការមូលបត្រកម្ពុជា បានចុះអនុស្សរណៈនៃការយោគយល់គ្នាស្ដីពីការត្រៀមបង្ការ ការទប់ស្កាត់ និងការគ្រប់គ្រងវិបត្តិហិរញ្ញវត្ថុកម្ពុជា។

**១០៤- អ្នកចូលរួមនៅក្នុងទីផ្សារ:** កាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០១០ **គ.ម.ក.** បានផ្ដល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រចំនួន១៥ ក្រុមហ៊ុន។ **គ.ម.ក.** ក៏បានផ្ដល់ការទទួលស្គាល់ដល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ភ្នាក់ងារទូទាត់ ក្រុមហ៊ុនគណនេយ្យជំនាញផ្ដល់សេវាក្នុងវិស័យមូលបត្រ និងសវនករឯករាជ្យ និងក្រុមហ៊ុនវាយតម្លៃផ្ដល់សេវាក្នុងវិស័យមូលបត្រ។ នាពេលបច្ចុប្បន្ននេះ ក្រុមហ៊ុនមូលបត្រមានចំនួន១២ ដែលរួមមានក្រុមហ៊ុនធានាទិញចំនួន៦ ក្រុមហ៊ុនពាណិជ្ជករមូលបត្រចំនួន១ ឈ្មួញជើងសាមូលបត្រចំនួន៣ និងអ្នកផ្ដល់ប្រឹក្សាវិនិយោគចំនួន២។ ក្នុងឆ្នាំ២០១៤ និងឆ្នាំ២០១៥ បុគ្គលចំនួន១១៨ រូបបានប្រឡងជាប់ទទួលស្គាល់គុណវុឌ្ឍិដែលរៀបចំដោយ **គ.ម.ក.**។

**១០៥- ការយល់ដឹងនិងការអប់រំជាសាធារណៈ:** **គ.ម.ក.** បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយវិទ្យាស្ថានហិរញ្ញវត្ថុកម្ពុជា ក្នុងខែមករា ឆ្នាំ២០១១ ដើម្បីផ្តល់ការបណ្តុះបណ្តាល និងអប់រំពាក់ព័ន្ធនឹងមូលបត្រដល់សាធារណជន។ ក្នុងរយៈពេល២ឆ្នាំចុងក្រោយនេះ **គ.ម.ក.** បានធ្វើសិក្ខាសាលាស្តីពី "ការយល់ដឹងពីទីផ្សារមូលបត្រនៅកម្ពុជា" នៅ ២៥រាជធានីខេត្ត ដល់រដ្ឋបាលរាជធានីខេត្ត។ ព្រមជាមួយគ្នានេះ **គ.ម.ក.** ក៏បានធ្វើការយ៉ាងជិតស្និទ្ធជាមួយ **ផ.ម.ក.** និងក្រុមហ៊ុនមូលបត្រ ផ្សព្វផ្សាយពីមូលបត្រដល់សាធារណជន តាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងការរៀបចំសិក្ខាសាលាតាមសាកលវិទ្យាល័យសមាគមធុរកិច្ច ក្រុមហ៊ុនសក្តានុពល និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ។ **គ.ម.ក.** ក៏បានបង្កើតមជ្ឈមណ្ឌលទទួលពាក្យបណ្តឹងនៅក្នុង **គ.ម.ក.** ផ្ទាល់ដើម្បីទទួលពាក្យបណ្តឹងពីសាធារណជនពាក់ព័ន្ធនឹងវិស័យមូលបត្រ។

**១០៦- ការពង្រឹងការអនុវត្តបទប្បញ្ញត្តិ:** នៅឆ្នាំ២០១៥ **គ.ម.ក.** បានអនុវត្តចំណាត់ការផ្លូវច្បាប់ចំពោះក្រុមហ៊ុនចំនួន១៥ ដែលធ្វើអាជីវកម្មលើឧបករណ៍និស្សន្ទដោយគ្មានអាជ្ញាបណ្ណ ព្រមទាំងបានចេញលិខិតផ្លូវការ ផ្អាកសកម្មភាពអាជីវកម្មពាក់ព័ន្ធនឹងគម្រោងវិនិយោគរួម ដោយគ្មានអាជ្ញាបណ្ណដល់ក្រុមហ៊ុនចំនួន២។

**១០៧- ការធ្វើសមាហរណកម្មហិរញ្ញវត្ថុអាស៊ាន:** **គ.ម.ក.** ជាអ្នកចូលរួមយ៉ាងសកម្មក្នុងវេទិកាទីផ្សារមូលធនអាស៊ាន (ACMF) និងក្រុមការងាររបស់វេទិកានេះ។ ក្រុមការងារនេះផ្តោតជាសំខាន់ទៅលើការធ្វើសុខដុមនីយកម្មនៃច្បាប់និងបទប្បញ្ញត្តិក្នុងស្រុក និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីផ្សារក្នុងទស្សនៈឆ្ពោះទៅរកសមាហរណកម្មទីផ្សារទុនក្នុងតំបន់។ **គ.ម.ក.** កំពុងសិក្សាពីបទដ្ឋានគតិយុត្ត ដើម្បីកំណត់ពីផ្នែកដែលត្រូវធ្វើសុខដុមនីយកម្ម ផ្នែកត្រូវផ្លាស់ប្តូរ ដើម្បីសម្រួលដល់ការបោះផ្សាយលក់មូលបត្រឆ្លងដែន និងការទទួលស្គាល់រួមក្នុងតំបន់។ តំណភ្ជាប់ទីផ្សារ អាចនឹងត្រូវបង្កើតឡើងនៅពេលដែលប្រតិបត្តិការទីផ្សារឈានដល់កម្រិតមួយ ដែលអាចទ្រទ្រង់ថ្លៃហេដ្ឋារចនាសម្ព័ន្ធទាំងនេះ។ ការធ្វើឲ្យប្រសើរឡើងនូវការជាត់ទាត់ នឹងជួយសម្រួលដល់ការជាត់ទាត់នៃការចុះបញ្ជីឆ្លងដែន។ កម្ពុជានឹងទទួលបានផលប្រយោជន៍ពីការគាំទ្រការកសាងសមត្ថភាព ដែលប្រទេសជាសមាជិកនឹងជួយដល់កម្ពុជា ដើម្បីអាចបំពេញទៅតាមការធ្វើសមាហរណកម្មបទដ្ឋានរបស់វេទិកាទីផ្សារមូលធនអាស៊ាន។

**១០៨- ការកសាងសមត្ថភាព:** គំនិតផ្តួចផ្តើមរបស់ **គ.ម.ក.** ពាក់ព័ន្ធនឹងការកសាងសមត្ថភាព អភិបាលកិច្ច និងការអប់រំ រួមមាន (១) ការផ្តល់ការបណ្តុះបណ្តាលដល់អ្នកសារព័ត៌មាន (២) ការកសាងសមត្ថភាពសម្រាប់មន្ត្រី **គ.ម.ក.** តាមរយៈការចូលរួមក្នុងកម្មវិធីផ្សេងៗដូចជា ការអនុវត្តការងារដល់ទីកន្លែង ការចូលរួមក្នុងសិក្ខាសាលា និងកម្មវិធីបណ្តុះបណ្តាលនៅបរទេស។ **គ.ម.ក.** ក៏បានផ្តល់ការបណ្តុះបណ្តាលផ្ទៃក្នុងដោយមានកិច្ចសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលអន្តរជាតិ ដូចជា មជ្ឈមណ្ឌលតូរ៉ុនតូ គំនិតផ្តួចផ្តើមសម្រាប់ការបណ្តុះបណ្តាលដល់និយតករហិរញ្ញវត្ថុ (FRTI) វិទ្យាស្ថានមូលបត្រថៃ

(TSI) និងអ្នកជំនាញការបរទេស។ បន្ថែមលើនេះទៅទៀត **គ.ម.ក.** បានត្រៀមនូវកញ្ចប់មូលនិធិសម្រាប់អាហារូបករណ៍អ្នកវិភាគហិរញ្ញវត្ថុជំនាញ (CFA) សម្រាប់មន្ត្រីរបស់ខ្លួនចំនួន៣រូប។

## គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

**១០៩-** បញ្ហាប្រឈមនាពេលបច្ចុប្បន្នសម្រាប់កិច្ចអភិវឌ្ឍទីផ្សារមូលបត្រ គឺការសម្រេចបាននូវសកម្មភាពផ្សេងៗ ដើម្បីគាំទ្រគំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុទាំងមូល។ ការធ្វើទំនើបកម្ម និងការអភិវឌ្ឍទីផ្សារមូលបត្រក្នុងស្រុកចាំបាច់ ត្រូវផ្តោតជាសំខាន់លើការផ្តល់នូវ៖ (១) សន្ទនីយភាពនៅក្នុងទីផ្សារ (២) ភាពសាមញ្ញ និងភាពដែលអាចបត់បែនបាន (៣) ការកាត់បន្ថយថ្លៃនៃការចូលទៅកាន់ទីផ្សារ (៤) ការរៀបចំ និងការដាក់ឲ្យអនុវត្តបទប្បញ្ញត្តិដ៏សមរម្យមួយ ដែលឆ្លើយតបទៅនឹងស្ថានភាពទីផ្សារ (៥) ការអប់រំវិនិយោគិន និង (៦) ប្រសិទ្ធភាពនៃប្រព័ន្ធ និងបទដ្ឋានដើម្បីគាំទ្រដល់ការអភិវឌ្ឍថ្មីៗ។ កម្ពុជានឹងទទួលបាននូវផលចំណេញពីផែនការ និងបទដ្ឋានដែលរៀបចំដោយក្រុមការងាររបស់ស្ថាប័នពាក់ព័ន្ធនៅក្នុងក្របខ័ណ្ឌអាស៊ាន។

## ឃ. យុទ្ធសាស្ត្រនិងផែនការអនាគត

**១១០-** ប្រទេសកម្ពុជាមានឱកាសវិនិយោគនិងសន្សំក្នុងស្រុកតិចតួចសម្រាប់ប្រជាជន។ ដូច្នេះ ប្រជាជនរក្សាទុកសាច់ប្រាក់ដោយខ្លួនឯង ដាក់ប្រាក់បញ្ញើនៅធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ឬវិនិយោគទៅក្រៅប្រទេស។ គោលដៅនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលផ្តោតលើការបង្វែរប្រាក់សន្សំក្នុងស្រុកទៅជាការវិនិយោគក្នុងស្រុក កាត់បន្ថយការពឹងផ្អែកលើប្រភពមូលនិធិក្រៅប្រទេស និងកាត់បន្ថយលំហូរប្រាក់សន្សំក្នុងស្រុកទៅវិនិយោគក្រៅប្រទេស។ ដូច្នេះទីផ្សារមូលបត្រក្នុងស្រុកដែលមានភាពរស់រវើក និងប្រសិទ្ធភាពជាតម្រូវការចាំបាច់ ដើម្បីអនុវត្តគោលនយោបាយនេះ។

**១១១-** ជាផ្នែកមួយនៃការជំរុញរបស់រាជរដ្ឋាភិបាល ក្នុងការពង្រីកការប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុ **គ.ម.ក.** នឹងជំរុញការចុះបញ្ជីក្រុមហ៊ុន សម្រាប់ការវិនិយោគសាធារណៈ។ អនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងមូលបត្រ **គ.ម.ក.** នឹងជំរុញប្រតិបត្តិការនៃគ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ និងគម្រោងវិនិយោគរួម ដែលបង្កើតមូលនិធិវិនិយោគរួម និងធ្វើការវិនិយោគមូលនិធិទាំងនោះក្នុងរយៈពេលវែងដូចជា៖ មូលនិធិធានារ៉ាប់រង មូលនិធិសោធននិវត្តនិងមូលនិធិសង្គមផ្សេងទៀត។ ច្បាប់ស្តីពីបរធនបាលកិច្ច ដែលនឹងត្រូវអនុម័តក្នុងរយៈពេលខ្លីខាងមុខ នឹងគាំទ្រដល់ការអភិវឌ្ឍនេះ។ សកម្មភាពវិនិយោគប្រកបដោយវិជ្ជាជីវៈ នឹងត្រូវបានលើកទឹកចិត្ត ដោយអាចនឹងមានមូលនិធិរដ្ឋាភិបាលត្រូវបានដាក់ឲ្យស្ថិតក្រោមបរធនបាល និងយកទៅវិនិយោគ ដោយអនុលោមតាមលិខិតបរធនបាលកិច្ច ដែលបានព្រមព្រៀងគ្នា។

**១១២-** រាជរដ្ឋាភិបាល មានបំណងជំរុញការអភិវឌ្ឍ និងពង្រីកវិសាលភាពវិស័យមូលបត្រដោយធ្វើការជម្រុះចេញនូវឧបសគ្គសម្រាប់ការចុះបញ្ជីលក់មូលបត្ររបស់ស្ថាប័នហិរញ្ញវត្ថុមួយចំនួនធំ។ **គ.ម.ក.** ស្នើសុំរាជរដ្ឋាភិបាលផងដែរ ដើម្បីពន្លឿនការអភិវឌ្ឍ និងធ្វើពិពិធកម្មវិស័យមូលបត្រ ដោយលើកទឹកចិត្ត ឬតម្រូវឲ្យសហគ្រាសទាំងនោះធ្វើការចុះបញ្ជីលក់មូលបត្រ។ ស្ថាប័នពាក់ព័ន្ធដទៃទៀតដែលកំពុងស្វែងរកការចុះបញ្ជីលក់មូលបត្រ ក៏គួរទទួលបានការអនុញ្ញាតផងដែរ តាមរយៈការបង្កើនដើមទុន និងទុនបម្រុងរបស់ស្ថាប័ន ការបោះផ្សាយលក់មូលបត្រជាសាធារណៈ (មិនតិចជាង២០%នៃមូលធនភាគទុនិកសរុបរបស់ស្ថាប័ន) ឬការរៀបចំសម្រាប់វិនិយោគិនដែលកំពុងកាន់កាប់មូលបត្រ លក់ចំណែកមូលបត្រកម្មសិទ្ធិរបស់ខ្លួនបាន ។

**១១៣- គ.ម.ក.** នឹង (១) ធ្វើការរួមគ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីតាមដានទៅលើជម្រើសសម្រាប់ការចុះបញ្ជីលក់មូលបត្ររបស់សហគ្រាសសាធារណៈបន្ថែម ឬបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែមរបស់សហគ្រាសសាធារណៈ រួមមាន ការពិនិត្យមើលឡើងវិញទៅលើភ្នាក់ងារ ដើម្បីពិនិត្យមើលលទ្ធភាពរបស់សហគ្រាសសាធារណៈ និងផ្តោតសំខាន់ទៅលើការគ្រប់គ្រង ការរៀបចំសម្រាប់ការចុះបញ្ជីមូលបត្រកម្មសិទ្ធិបន្ថែម (២) ពិនិត្យឡើងវិញ និងរៀបចំចំណាត់ការសមស្របសម្រាប់ការខ្ចី និងការឲ្យខ្ចីមូលបត្រ ដោយការពិចារណាលើលទ្ធភាពបង្កើតសាជីវកម្មហិរញ្ញវត្ថុមូលបត្រ និង (៣) ធ្វើការរួមគ្នាជាមួយភ្នាក់ងារ និងភាគីពាក់ព័ន្ធ ដើម្បីជាជំនួយក្នុងការបង្កើតទីផ្សាររូបវន្ត សម្រាប់ទីផ្សារខុម៉ូឌីធីនៅក្នុងប្រទេសកម្ពុជា ដើម្បីគាំទ្រដល់ការអភិវឌ្ឍទីផ្សារខុម៉ូឌីធី និងទីផ្សារឧបករណ៍និស្សន្ទនៅពេលអនាគត។ ជំហាននៃការអភិវឌ្ឍបន្ទាប់អាចពាក់ព័ន្ធនឹងការពង្រីកក្របខ័ណ្ឌសម្រាប់ឧបករណ៍និស្សន្ទ គ្របដណ្តប់ដល់ទីផ្សារឧបករណ៍និស្សន្ទ និងទីផ្សារកិច្ចសន្យាអុបសិន និងកិច្ចសន្យានិស្សន្ទដែលគាំទ្រដល់ការកំណត់ថ្លៃ និងការគ្រប់គ្រងហានិភ័យ។

**១១៤-** ដើម្បីផ្តល់ភាពកាន់តែងាយស្រួលចំពោះការចូលទៅកាន់ទីផ្សារមូលបត្រ **គ.ម.ក.**នឹង ៖ (១) ពិនិត្យឡើងវិញ និងរៀបចំសម្រួលនីតិវិធី និងបទប្បញ្ញត្តិសម្រាប់ការចុះបញ្ជីរបស់សហគ្រាសធុនតូច និងមធ្យម (២) ពិនិត្យទៅលើយោបល់ក្នុងការសម្រួលមាតិកានៃឯកសារផ្តល់ព័ត៌មាន និងកែសម្រួលនូវបទប្បញ្ញត្តិ និងនីតិវិធីសម្រាប់ការបោះផ្សាយលក់មូលបត្រក្នុងចំនួនតិច និងការចុះបញ្ជីលក់មូលបត្ររបស់ស្ថាប័នហិរញ្ញវត្ថុឲ្យកាន់តែមានភាពសាមញ្ញ និងងាយស្រួល និង (៣) ធ្វើការស្រាវជ្រាវ និងបង្កើតក្របខ័ណ្ឌគតិយុត្តសម្រាប់ក្រោដហ្វាន់ឌីង និងផ្តល់អាជ្ញាបណ្ណដល់អ្នកផ្តល់សេវា និងវេទិកាក្រោដហ្វាន់ឌីងជាមួយនឹងការបន្តពិនិត្យកិច្ចការពារវិនិយោគិន និងការតភ្ជាប់ទីផ្សារ។

**១១៥-** ដើម្បីធ្វើឲ្យប្រសើរឡើងចំពោះការលើកទឹកចិត្តការចូលរួមនៅក្នុងទីផ្សារមូលបត្រ **គ.ម.ក.** នឹងធ្វើការជាមួយអគ្គនាយកដ្ឋានពន្ធដារ ដើម្បីពិនិត្យឡើងវិញលើអនុក្រឹត្យស្តីពីពន្ធដារ ដែលរួមបញ្ចូលទាំងការពិនិត្យឡើងវិញពីបញ្ហាពន្ធដារ ដែលក្រុមហ៊ុនមានចំណាប់អារម្មណ៍ចុះបញ្ជីជួញដូរនៅលើ

ទីផ្សារមូលបត្រកំពុងជួបប្រទះ និងការពិចារណាលើការផ្តល់នូវផលប្រយោជន៍សម្រាប់ក្រុមហ៊ុនចុះបញ្ជី ដែលអាចនឹងស្មើ ឬដូចនឹងការលើកទឹកចិត្ត ដែលផ្តល់ទៅឲ្យគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ (QIP)។ **គ.ម.ក.** នឹងធ្វើការស្រាវជ្រាវពីការលើកទឹកចិត្តមិនមែនពន្ធដារ និងដាក់ឲ្យអនុវត្តគោលនយោបាយលើកទឹកចិត្តមិនមែនពន្ធដារ។ **គ.ម.ក.** នឹងពិនិត្យឡើងវិញ ដើម្បីឲ្យច្បាស់ថាច្បាប់ ឬបទប្បញ្ញត្តិ ដែលគ្របដណ្តប់វិស័យមូលបត្ររួមបញ្ចូលការប្រឆាំងអំពើពុករលួយ។

**១១៦-** ដើម្បីជំរុញស្ថិរភាព និងទំនុកចិត្តក្នុងទីផ្សារ **គ.ម.ក.** នឹង (១) ធ្វើបច្ចុប្បន្នកម្ម និងអនុវត្តកម្មវិធីបណ្តុះបណ្តាលវិនិយោគិន និងបញ្ជ្រាបការយល់ដឹងដល់សាធារណជន តាមរយៈយោបល់ និងតម្រូវ-ការអភិវឌ្ឍទីផ្សារ/តម្រូវការទីផ្សារ និងសហការជាមួយក្រសួងអប់រំយុវជន និងកីឡា លើការបញ្ចូលមូលដ្ឋានគ្រឹះហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាជាតិ (២) គាំទ្រសមាហរណកម្មហិរញ្ញវត្ថុអាស៊ាន តាមរយៈការពិនិត្យ និងបន្ស៊ីបទប្បញ្ញត្តិចុះបញ្ជីលក់មូលបត្រ និងទីផ្សារមូលបត្រជាមួយបទដ្ឋាន និងគោលការណ៍របស់អាស៊ាន រួមទាំង បទប្បញ្ញត្តិស្តីពីការដោះស្រាយវិវាទ និងសហការដើម្បីឆ្ពោះទៅដល់ការទទួលស្គាល់គ្នាទៅវិញទៅមកលើការផ្តល់អាជ្ញាបណ្ណដល់អ្នកចូលរួមក្នុងទីផ្សារមូលបត្រ (៣) សហការជាមួយក្រុមប្រឹក្សាជាតិគណនេយ្យ ដើម្បីពង្រឹងការត្រួតពិនិត្យក្រុមហ៊ុនគណនេយ្យជំនាញ ដែលទទួលបានការទទួលស្គាល់ក្នុងការផ្តល់សេវាក្នុងវិស័យមូលបត្រ (៤) បំពេញការងារពាក់ព័ន្ធនឹងការដោះស្រាយវិវាទដោយយោងតាមបទដ្ឋានអាស៊ាន និងគោលការណ៍ណែនាំ ក្នុងការគាំទ្រការបោះផ្សាយ និងការចុះបញ្ជីលក់មូលបត្រឆ្លងដែន ព្រមទាំងពិនិត្យកែសម្រួលបទប្បញ្ញត្តិ និងនីតិវិធីដោះស្រាយវិវាទផ្លូវការ (៥) ពង្រឹងកិច្ចសហប្រតិបត្តិការ តាមរយៈការចុះអនុស្សរណៈយោគយល់គ្នា សម្រាប់ការចែករំលែកព័ត៌មាន និងសហប្រតិបត្តិការនៃប្រព័ន្ធផាត់ទាត់និងទូទាត់ ជាមួយនឹងធនាគារជាតិនៃកម្ពុជា និងពង្រឹងភាពជាដៃគូ និងសហប្រតិបត្តិការទៅវិញទៅមកជាមួយនឹងនិយតករ និងផ្សារមូលបត្របរទេស (៦) បន្តផ្សព្វផ្សាយ និងផ្តល់ការបណ្តុះបណ្តាលស្តីពីអភិបាលកិច្ចសាជីវកម្ម និងបទដ្ឋានអភិបាលកិច្ច និង (៧) ដឹកនាំការវាយតម្លៃអំពីលទ្ធភាពក្នុងការចូលជាសមាជិក IOSCO។

**១១៧-** ដើម្បីបន្តការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ **គ.ម.ក.** នឹង (១) បញ្ចប់ការរៀបចំបទប្បញ្ញត្តិសម្រាប់សញ្ញាប័ណ្ណសាជីវកម្ម និងឧបករណ៍និស្សន្ទ (២) បន្តការរៀបចំបទប្បញ្ញត្តិ សម្រាប់គម្រោងវិនិយោគរួមក្នុងនោះរួមទាំងការត្រួតពិនិត្យមូលនិធិ និងបុគ្គលគ្រប់គ្រងមូលនិធិ ព្រមទាំងប្រតិបត្តិការបរធនបាលកិច្ច និង (៣) ពិនិត្យឡើងវិញ និងធ្វើឲ្យប្រាកដថាច្បាប់ ឬបទប្បញ្ញត្តិក្នុងវិស័យមូលបត្រមានចែងអំពីកាតព្វកិច្ចពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលមានសង្គតិភាពជាមួយនឹងច្បាប់ និងប្រកាស ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

# ឧបសម្ព័ន្ធទី ៥

# ពុទ្ធិមូលបត្រលេខ ៤៦

# ចេញផ្សាយឆ្នាំ២០២០

ពុទ្ធិមូលបត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ ៤៦ ចេញផ្សាយ ឆ្នាំ២០២០

# ទិញ-លក់ភាគហ៊ុនងាយស្រួលតាមរយៈប្រព័ន្ធជួញដូរចល័ត (Mobile Trading System)

ប្រព័ន្ធជួញដូរចល័ត (Mobile Trading System) គឺជាការភ្ជាប់ការវិនិយោគទៅនឹងបច្ចេកវិទ្យាជឿនលឿននៃប្រព័ន្ធជួញដូរតាមទូរស័ព្ទ (MTS) ដែលជាប្រព័ន្ធថ្មីបង្កើតឡើងដោយក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ តាមរយៈប្រព័ន្ធនេះ វិនិយោគិនអាចធ្វើការជួញដូរភាគហ៊ុនបានយ៉ាងឆាប់រហ័ស មានភាពងាយស្រួល ប្រកបដោយសុវត្ថិភាព និងមានប្រសិទ្ធិភាព។ MTS ត្រូវបានបំពាក់ដោយមុខងារផ្សេងៗគ្នាដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ អាចដាក់បញ្ជាដោយខ្លួនឯងបានគ្រប់ទីកន្លែង រួមទាំងអាចតាមដានពីស្ថានភាពទីផ្សារបច្ចុប្បន្ន ពិនិត្យមើលការបញ្ជាជួញដូរកន្លងមក ពិនិត្យមើលសមតុល្យគណនី និងព័ត៌មានផ្ទាល់ខ្លួន ជាពិសេសទទួលបានព័ត៌មានថ្មីៗ និងទិន្នន័យនានាដែលជាជំនួយក្នុងការវិនិយោគបន្ថែមទៀត ដោយគ្រាន់តែធ្វើការតភ្ជាប់នឹងប្រព័ន្ធអ៊ីនធឺណេតតាមរយៈ smart phones ឬ tablets។



MTS ត្រូវបានបង្កើតឡើងដោយ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងផ្តល់ឱ្យវិនិយោគិនប្រើប្រាស់តាមរយៈក្រុមហ៊ុនមូលបត្រដែលបានចុះឈ្មោះផ្តល់សេវាកម្ម MTS ទៅកាន់វិនិយោគិនរបស់ខ្លួន។ វិនិយោគិនដែលចង់ដំណើរការគណនី MTS តម្រូវឱ្យមានគណនីជួញដូរមួយនៅក្រុមហ៊ុនមូលបត្រណាមួយដែលជាសមាជិក ផ.ម.ក.។

### តើវិនិយោគិនអាចធ្វើអ្វីបានជាមួយ MTS?

- ការដាក់បញ្ជាទិញ/លក់
- ការកែប្រែ និងលុបចោលបញ្ជា
- ការពិនិត្យមើលបញ្ជា និងកំណត់ត្រានៃការជួញដូរកន្លងមក
- ការពិនិត្យមើលសមតុល្យក្នុងគណនីជួញដូរ
- ការពិនិត្យមើលភាពចំណេញ/ខាតនៃមូលបត្រកាន់កាប់បច្ចុប្បន្ន និងប្រតិបត្តិការកន្លងមក
- ការតាមដានស្ថានភាពទីផ្សារ
- ការស្វែងរកព័ត៌មាន និងសេចក្តីជូនដំណឹងផ្សេងៗដែលពាក់ព័ន្ធ
- ការស្នើដកប្រាក់។

រាល់បញ្ជាទាំងឡាយត្រូវឆ្លងកាត់ប្រព័ន្ធដាក់បញ្ជារបស់ក្រុមហ៊ុនមូលបត្រមុននឹងចូលទៅប្រព័ន្ធទទួលបញ្ជារបស់ទីផ្សារ លើសពីនេះទៅទៀតវិនិយោគិនអាចលុបបញ្ជា ឬកែប្រែបញ្ជាដែលបានបញ្ជូនរួច ព្រមទាំងស្នើសុំដាក់ប្រាក់ចូល និងដកប្រាក់ចេញនៅក្នុងគណនីជួញដូររបស់ខ្លួន។

ក្នុងគោលដៅជំរុញការប្រើប្រាស់ MTS មានភាពទូលំទូលាយ វិនិយោគិនត្រូវបានផ្តល់ជូនការលើកទឹកចិត្តដោយប្រើសេវាកម្មនេះដោយឥតគិតថ្លៃសម្រាប់រយៈពេលមួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់ឱ្យដំណើរការ MTS ជាផ្លូវការតទៅ។

Connecting investment to advanced technology, Mobile Trading System (MTS) is a newly-developed system implemented by Cambodia Securities Exchange, through which investors could trade stocks in a fast, secure and convenient way. MTS is equipped with various functions allowing users from anywhere to place orders by themselves, view current and historical market data as well as trading account data via smart phones or tablets that are connected to the Internet.

MTS is developed by Cambodia Securities Exchange and provided to investors through brokers who have successfully subscribed to provide MTS service to their investors.

### What investors can do with MTS?

- Placing Bid/Ask Order
- Correcting and Cancelling Order
- Order and Historical Trade Inquiry
- Cash and Securities Balance Inquiry
- Profit/Loss Evaluation of Current and Historical Holding Securities Inquiry
- Market Situation Monitoring
- Disclosure and Other Related News Inquiry
- Making Cash Withdrawal Request.

For the purpose of promoting the use of the MTS broadly, investors will not be charged for using the service for one year from the date of the official MTS launch.

អត្ថបទ៖ លី វិមល

ប្រភព: CSX

# ឧបសម្ព័ន្ធទី ៦

# ទម្រង់ពាក្យស្នើសុំលេខ

# អត្តសញ្ញាណវិនិយោគិន

# សម្រាប់នីតិបុគ្គល

គណៈកម្មការមូលបត្រកម្ពុជា
**Securities and Exchange Commission of Cambodia**

ទម្រង់ ខ
**FORM B**

រូបថត ៤x៦ របស់អ្នកតំណាង ថតក្នុងរយៈពេល ៦ខែចុងក្រោយ
Photograph of representative taken within the last six months, 4x6

# ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន
# INVESTOR IDENTIFICATION NUMBER APPLICATION FORM
## សម្រាប់នីតិបុគ្គល
## FOR INSTITUTIONAL INVESTOR

## ក. ព័ត៌មានរបស់នីតិបុគ្គល
## A. Institutional Information

ឈ្មោះនីតិបុគ្គល (អក្សរខ្មែរ)
Name of Institution (Khmer) ..............................

ឈ្មោះនីតិបុគ្គល (អក្សរឡាតាំង)
Name of Institution (Latin) ..............................

ថ្ងៃ ខែ ឆ្នាំចុះបញ្ជីពាណិជ្ជកម្ម
Date of Registration | D | D | M | M | Y | Y | Y | Y |

ថ្ងៃ ខែ ឆ្នាំផុតសុពលភាពវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
Expiry Date of Company Registration Certificate | D | D | M | M | Y | Y | Y | Y |

ថ្ងៃ ខែ ឆ្នាំផុតសុពលភាពអាជ្ញាប័ណ្ណធ្វើអាជីវកម្ម (បើមាន)
Expiry Date of Company License (If applicable) | D | D | M | M | Y | Y | Y | Y |

សញ្ញាតិនីតិបុគ្គល
Nationality of Institution
☐ សញ្ជាតិខ្មែរ Cambodian
☐ សញ្ជាតិបរទេស (សូមបញ្ជាក់សញ្ជាតិ) Foreigner (Please Specify Nationality) ..............................

ប្រភេទអាជីវកម្ម
Type of Business ..............................

អាសយដ្ឋាននីតិបុគ្គល
Address of Institution
អគារលេខ No. .............. ផ្លូវ Street ..............................
☐ ឃុំ / Commune / ☐ សង្កាត់ Sangkat ..............................
☐ ស្រុក / District / ☐ ក្រុង / Town/ ☐ ខណ្ឌ Khan ..............................
☐ ខេត្ត / Province/ ☐ រាជធានី Capital ..............................
ប្រទេស Country ..............................

លេខអត្តសញ្ញាណកម្មសារពើពន្ធ (បើមាន)
Taxpayer Identification Number (If applicable) ..............................

### ឯកសារធនាគាររបស់នីតិបុគ្គល
### BANKING REFERENCE

ឈ្មោះធនាគារ
Bank Name ..............................

លេខគណនីធនាគារ
Account Number ..............................

## ខ. បុគ្គលចុះហត្ថលេខាក្នុងនាមនីតិបុគ្គល ឬ អ្នកតំណាង
## B. AUTHORIZED PERSON TO SIGN ON BEHALF OF INSTITUTION OR REPRESENTATIVE

នាមត្រកូល (អក្សរខ្មែរ)
Surname (Khmer) .............................. (អក្សរឡាតាំង) (Latin) ..............................

នាមខ្លួន (អក្សរខ្មែរ)
Given Name (Khmer) .............................. (អក្សរឡាតាំង) (Latin) ..............................

ថ្ងៃ ខែ ឆ្នាំកំណើត
Date of Birth | D | D | M | M | Y | Y | Y | Y |

ភេទ
Gender ☐ ប្រុស Male ☐ ស្រី Female

លក្ខន្តិកៈគ្រួសារ
Marital Status ☐ នៅលីវ Single ☐ មានគ្រួសារ Married ☐ លែងលះ Divorced

សញ្ជាតិ
Nationality
☐ សញ្ជាតិខ្មែរ Cambodian
☐ សញ្ជាតិបរទេស (សូមបញ្ជាក់សញ្ជាតិ) Foreigner (Please Specify Nationality) ..............................

ប្រភេទបណ្ណសម្គាល់អត្តសញ្ញាណ
Identification Type
☐ លេខអត្តសញ្ញាណប័ណ្ណ (សម្រាប់ខ្មែរ) Identification card Number ( For Cambodian) ..............................
☐ លេខលិខិតឆ្លងដែន (សម្រាប់បរទេស) Passport Number (For Foreigner) ..............................

### ១. អាសយដ្ឋានទំនាក់ទំនងរបស់បុគ្គលចុះហត្ថលេខាក្នុងនាមនីតិបុគ្គល ឬអ្នកតំណាង
### 1. Contact Address of the Authorized Person or Representative

អាសយដ្ឋានទំនាក់ទំនងក្នុងព្រះរាជាណាចក្រកម្ពុជា
Contact Address in Cambodia

អគារលេខ No. .............. ផ្លូវ Street ..............................
☐ ឃុំ/ Commune/ ☐ សង្កាត់ Sangkat ..............................
☐ ស្រុក / District / ☐ ក្រុង/ Town/ ☐ ខណ្ឌ Khan ..............................
☐ ខេត្ត / Province/ ☐ រាជធានី Capital ..............................

លេខទូរសព្ទលើតុ
Telephone .............................. លេខទូរសព្ទដៃ Mobile ..............................

អ៊ីម៉ែល
E-mail ..............................

អាសយដ្ឋានទំនាក់ទំនងក្រៅប្រទេស (សម្រាប់វិនិយោគិនដែលមិនមានទីលំនៅអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជា)
Contact Address in Your Country (For investor who does not have permanent address in Cambodia)

អគារលេខ No. ____ ផ្លូវ Street ____ ឃុំ Commune ____

☐ ស្រុក / District / ☐ ក្រុង Town ____ ☐ ខេត្ត / Province/ ☐ រាជធានី Capital ____

ប្រទេស Country ____ លេខទូរសព្ទលើតុ Telephone ____

អ៊ីម៉ែល E-mail ____ លេខទូរសព្ទដៃ Mobile ____

## ២. ព័ត៌មានអំពីមុខរបរ
## 2. Occupation

មុខរបរបច្ចុប្បន្ន Present Occupation ____ រយៈពេលនៃអតីតភាពការងារ Length of Work ____

ឈ្មោះកន្លែងធ្វើការ Name of Organization ____ ប្រភេទអាជីវកម្ម Type of Business ____

អាសយដ្ឋានកន្លែងធ្វើការ Address of Workplace ____

## ៣. ព័ត៌មានអំពីការសិក្សា
## 3. Educational Background

ផ្នែក Field ____

## ៤. បុគ្គលអាចទំនាក់ទំនងបានក្នុងករណីចាំបាច់ (ផ្សេងពីអ្នកតំណាងខាងលើ )
## 4. Contact Person when necessary ( Besides the representative above)

ឈ្មោះ Name ____ ភេទ Gender ____ ទូរសព្ទ Mobile ____

អាសយដ្ឋានស្នាក់នៅ Home address ____

## ៥. ចំណេះដឹងលើការវិនិយោគក្នុងវិស័យមូលបត្រ
## 5. Knowledge in Securities Investment

☐ ល្អណាស់ Very good ☐ ល្អ Good ☐ តិចតួច Limited ☐ គ្មាន Nothing

## ៦. ឯកសារភ្ជាប់សម្រាប់ការស្នើសុំលេខអត្តសញ្ញាណវិនិយោគិន
## 6. Enclosed Documents To Apply For Investor Identification Number

- ☐ អត្តសញ្ញាណបណ្ណរបស់អ្នកតំណាងថតចម្លងមានបញ្ជាក់ត្រឹមត្រូវ (ករណីសញ្ជាតិខ្មែរ) Certify true copy of Identification Card of Representative (For Cambodian)
- ☐ លិខិតផ្ទេរសិទ្ធិអ្នកតំណាង Power of Attorney
- ☐ លិខិតឆ្លងដែនរបស់អ្នកតំណាងថតចម្លងមានបញ្ជាក់ត្រឹមត្រូវ (ករណីមិនមែនសញ្ជាតិខ្មែរ) Certify true copy of Passport of Representative (For Foreigner)
- ☐ លក្ខន្តិកៈក្រុមហ៊ុនថតចម្លងមានបញ្ជាក់ត្រឹមត្រូវ Certify true copy of Articles of Association
- ☐ អាជ្ញាបណ្ណធ្វើអាជីវកម្មរបស់នីតិបុគ្គលថតចម្លងមានបញ្ជាក់ត្រឹមត្រូវ (បើមាន) Certify true copy of Company License (If any)
- ☐ វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែមថតចម្លងមានបញ្ជាក់ត្រឹមត្រូវ (បើមាន) Certify true copy of Value Added Tax Certificate (If applicable)
- ☐ វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មរបស់នីតិបុគ្គលថតចម្លងមានបញ្ជាក់ត្រឹមត្រូវ Certify true copy of Company Registration Certificate
- ☐ ផ្សេងៗ (សូមបញ្ជាក់) Other (Please Specify) ____

**ខ្ញុំសូមធានាចំពោះមុខច្បាប់ថាព័ត៌មានដែលបំពេញខាងលើរួមទាំងឯកសារភ្ជាប់ពិតជាត្រឹមត្រូវមែន**

I hereby take full responsibility against the law of the Kingdom of Cambodia, that all above information and documents enclosed are true and correct.

ថ្ងៃទី ខែ ឆ្នាំ : Date: D D M M Y Y Y Y

ហត្ថលេខា និងឈ្មោះរបស់អ្នកតំណាង Signature and Name of Representative ____ ឬ Or

ត្រាសម្គាល់នីតិបុគ្គល Seal of the Institution

ស្នាមមេដៃស្តាំរបស់អ្នកតំណាង Right Thumb Fingerprint of Representative

## គ. សម្រាប់ក្រុមហ៊ុនមូលបត្រ (ករណីដាក់ពាក្យស្នើសុំតាមរយៈក្រុមហ៊ុនមូលបត្រ)
## C. FOR SECURITIES FIRM (APPLYING VIA SECURITIES FIRM)

ឈ្មោះក្រុមហ៊ុនមូលបត្រ Name of Securities Firm ____

ឈ្មោះភ្នាក់ងារក្រុមហ៊ុនមូលបត្រ Name of Securities Representative ____

យោបល់របស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ Comment of Securities Representative ____

ហត្ថលេខារបស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ Signature of Securities Representative ____ ថ្ងៃទី ខែ ឆ្នាំ : Date: D D M M Y Y Y Y

## ឃ. សម្រាប់គណៈកម្មការមូលបត្រកម្ពុជា
## D. FOR THE SECC'S USE ONLY

យោបល់របស់មន្ត្រីគ.ម.ក. ÷
SECC Comments :

# ឧបសម្ព័ន្ធទី ៧

# ទម្រង់ពាក្យស្នើសុំលេខ

# អត្តសញ្ញាណវិនិយោគិន

# សម្រាប់រូបវ័ន្តបុគ្គល

គណៈកម្មការមូលបត្រកម្ពុជា
Securities and Exchange Commission of Cambodia

ទម្រង់ ក
FORM A

រូបថត ៤x៦ របស់រូបវន្តបុគ្គល ថតចំពីមុខក្នុងរយៈពេល ៦ខែចុងក្រោយ
Photograph of investor taken within the last six months, 4x6

# ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន
# INVESTOR IDENTIFICATION NUMBER APPLICATION FORM
## សម្រាប់រូបវន្តបុគ្គល
## FOR INDIVIDUAL INVESTOR

## ក. ព័ត៌មានផ្ទាល់ខ្លួន
## A. PERSONAL INFORMATION

នាមត្រកូល (អក្សរខ្មែរ) Surname (Khmer) ........ (អក្សរឡាតាំង) (Latin) ........

នាមខ្លួន (អក្សរខ្មែរ) Given Name (Khmer) ........ (អក្សរឡាតាំង) (Latin) ........

ថ្ងៃ ខែ ឆ្នាំកំណើត Date of Birth | D | D | M | M | Y | Y | Y | Y |

ភេទ Gender: ☐ ប្រុស Male ☐ ស្រី Female

លក្ខន្តិកៈគ្រួសារ Marital Status: ☐ នៅលីវ Single ☐ មានគ្រួសារ Married ☐ លែងលះ Divorced

សញ្ជាតិ Nationality: ☐ សញ្ជាតិខ្មែរ Cambodian ☐ សញ្ជាតិបរទេស (សូមបញ្ជាក់សញ្ជាតិ) Foreigner (Please Specify Nationality) ........

ក្នុងករណីជនបរទេសសូមបញ្ជាក់ Foreigner Please Specify: ☐ និវាសនជន Resident ☐ អនិវាសនជន Non Resident

ប្រភេទបណ្ណសម្គាល់អត្តសញ្ញាណ Identification Type:
☐ លេខអត្តសញ្ញាណប័ណ្ណ (សម្រាប់ខ្មែរ) Identification card Number ( For Cambodian) ........
☐ លេខលិខិតឆ្លងដែន (សម្រាប់បរទេស) Passport Number (For Foreigner) ........

កាលបរិច្ឆេទផុតសុពលភាពអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន Expiry Date of Identification card/Passport | D | D | M | M | Y | Y | Y | Y |

លេខអត្តសញ្ញាណកម្មសារពើពន្ធ (បើមាន) Taxpayer Identification Number (If applicable) ........

### ១. អាសយដ្ឋានទំនាក់ទំនង
### 1. Contact Address

អាសយដ្ឋានទំនាក់ទំនងក្នុងព្រះរាជាណាចក្រកម្ពុជា
Contact Address in Cambodia

អគារលេខ No. ........ ផ្លូវ Street ........ ☐ ឃុំ / Commune / ☐ សង្កាត់ Sangkat ........

☐ ស្រុក / District / ☐ ក្រុង / Town/ ☐ ខណ្ឌ Khan ........ ☐ ខេត្ត / Province/ ☐ រាជធានី Capital ........

លេខទូរសព្ទលើតុ Telephone ........ លេខទូរសព្ទដៃ Mobile ........

អ៊ីម៉ែល E-mail ........

អាសយដ្ឋានទំនាក់ទំនងក្រៅប្រទេស (សម្រាប់វិនិយោគិនដែលមិនមានទីលំនៅអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជា)
Contact Address in Your Country (For investor who does not have permanent address in Cambodia)

អគារលេខ No. ........ ផ្លូវ Street ........ ឃុំ Commune ........

☐ ស្រុក / District / ☐ ក្រុង Town ........ ☐ ខេត្ត / Province/ ☐ រាជធានី Capital ........

ប្រទេស Country ........ លេខទូរសព្ទលើតុ Telephone ........

អ៊ីម៉ែល E-mail ........ លេខទូរសព្ទដៃ Mobile ........

### ២. ព័ត៌មានអំពីមុខរបរ
### 2. Occupation

មុខរបរបច្ចុប្បន្ន Present Occupation ........ រយៈពេលនៃអតីតភាពការងារ Length of Work ........

ឈ្មោះកន្លែងធ្វើការ Name of Organization ........ ប្រភេទអាជីវកម្ម Type of Business ........

អាសយដ្ឋានកន្លែងធ្វើការ Address of Workplace ........

**៣. ព័ត៌មានអំពីការសិក្សា**
3. Educational Background

ផ្នែក
Field ..............................

**៤. បុគ្គលទំនាក់ទំនង**
4. Contact Person

បុគ្គលដែលអាចទំនាក់ទំនងបានក្នុងករណីចាំបាច់
Contact person when necessary

ឈ្មោះ
Name .............................. ភេទ
Gender .......... ទូរសព្ទ
Mobile ..........

អាសយដ្ឋានស្នាក់នៅ
Home address ..............................

**៥. ចំណេះដឹងលើការវិនិយោគក្នុងវិស័យមូលបត្រ**
5. Knowledge in Securities Investment

☐ ល្អណាស់ Very good ☐ ល្អ Good ☐ តិចតួច Limited ☐ គ្មាន Nothing

**៦. ឯកសារធនាគាររបស់បុគ្គលដាក់ពាក្យស្នើសុំ**
6. Banking Reference

ឈ្មោះធនាគារ
Bank Name ..............................

លេខគណនីធនាគារ
Account Number ..............................

**៧. ឯកសារភ្ជាប់សម្រាប់ការស្នើសុំលេខអត្តសញ្ញាណវិនិយោគិន**
7. Enclosed Documents to Apply for Investor Identification Number

☐ អត្តសញ្ញាណប័ណ្ណថតចម្លងមានបញ្ជាក់ត្រឹមត្រូវ (ករណីសញ្ជាតិខ្មែរ)
Certify true copy of ID Card (For Cambodian)

☐ លិខិតឆ្លងដែនថតចម្លងមានបញ្ជាក់ត្រឹមត្រូវ (ករណីមិនមែនសញ្ជាតិខ្មែរ)
Certify true copy of Passport (For Foreigner)

☐ ផ្សេងៗ (សូមបញ្ជាក់)
Other (Please Specify) ..............................

**ខ្ញុំសូមធានាចំពោះមុខច្បាប់ថាព័ត៌មានដែលបំពេញខាងលើរួមទាំងឯកសារភ្ជាប់ពិតជាត្រឹមត្រូវមែន**

I hereby take full responsibility against the law of the Kingdom of Cambodia, that all above information and documents enclosed are true and correct.

ថ្ងៃទី ខែ ឆ្នាំ :
Date: | D | D | M | M | Y | Y | Y | Y |

ហត្ថលេខា
Signature ______________________ ឬ or

ស្នាមមេដៃស្តាំ
Right Thumb Fingerprint

## ខ. សម្រាប់ក្រុមហ៊ុនមូលបត្រ (ករណីដាក់ពាក្យស្នើសុំតាមរយៈក្រុមហ៊ុនមូលបត្រ)
## B. FOR SECURITIES FIRM (APPLYING VIA SECURITIES FIRM)

ឈ្មោះក្រុមហ៊ុនមូលបត្រ
Name of Securities Firm ..............................

ឈ្មោះភ្នាក់ងារក្រុមហ៊ុនមូលបត្រ
Name of Securities Representative ..............................

យោបល់របស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ
Comment of Securities Representative ..............................

ហត្ថលេខារបស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ
Signature of Securities Representative ______________________

ថ្ងៃទី ខែ ឆ្នាំ :
Date: | D | D | M | M | Y | Y | Y | Y |

## គ. សម្រាប់គណៈកម្មការមូលបត្រកម្ពុជា
## C. FOR THE SECC'S USE ONLY

យោបល់របស់មន្ត្រីគ.ម.ក. ÷
SECC Comments :

..............................

..............................